**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# នីតិវិធីជំនុំជម្រះលើកទី១

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ កញ្ញា **ឈៀង សៀងហ៊ុង**

កញ្ញា **សុទ្ធ ម៉ីធិញ**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ **ញឹក ឧត្តី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី **២៤**

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# **សេចក្តីថ្លែងអំណរគុណ**

នាងខ្ញុំឈ្មោះ **ឈៀវ សៀវហ៊ុង** និងនាងខ្ញុំ **សុទ្ធ ម៉ីធិញ** ជានិស្សិតថ្នាក់ បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី ២៤ ឆ្នាំសិក្សា ២០២០-២០២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

សូមថ្លែងនូវកតញ្ញូតាធម៌ និងថ្លែងអំណរគុណចំពោះ **លោកឪពុក និងអ្នកម្តាយ** យ៉ាងជ្រាលជ្រៅគ្មានអ្វីប្រៀបផ្ទឹម ដែលបានចិញ្ចឹមបីបាច់ ថែរក្សា តាំងពីតូចរហូតដល់ធំ និងបានចំណាយទាំងថវិកា សម្ភារៈ ព្រមទាំងកម្លាំងកាយ ចិត្ត ដើម្បីផ្គត់ផ្គង់ការសិក្សារបស់កូន តាំងពីបឋមសិក្សារហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រ ដោយមិនខ្លាចនឿយហត់ និងភាពលំបាក។ យ៉ាងណាគោលបំណងតែមួយគត់របស់អ្នកមានគុណទាំងពី គឺចង់ឃើញកូនៗ មានអនាគតល្អ។

សូមថ្លែងអំណរគុណចំពោះ **ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង និងសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ** ដែលបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីផ្តល់នូវការអប់រំ ចំណេះដឹង ព្រមទាំងបទពិសោធន៍ សីលធម៌ក្នុងការរស់នៅ និងដំបូន្មានដ៏ល្អជាច្រើន រួមទាំងការជួយពន្យល់ណែនាំ យ៉ាងយកចិត្តទុកដាក់បំផុត ដើម្បីឱ្យយើងខ្ញុំបានបញ្ចប់ការសិក្សាប្រកបដោយភាពជោគជ័យ ជាពិសេសសូមថ្លែងអំណរគុណយ៉ាងក្រៃលែងចំពោះ **លោកសាស្ត្រាចារ្យជំនួយ ញឹក ឧុធី** ដែលលោកបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការដឹកនាំ ណែនាំបង្ហាត់បង្ហាញ ពន្យល់ រំលឹក និងលើកទឹកចិត្តដល់យើងខ្ញុំទាំងពីរ ក្នុងដំណើរការនៃការសរសេរសារណានេះឡើង ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ។

ជាចុងក្រោយ យើងខ្ញុំសូមបួងសួងដល់វត្ថុស័ក្តសិទ្ធិផងទាំងពួងដែលមាននៅលើលោកនេះឱ្យជួយតាមថែរក្សា **លោកអ្នកមានគុណទាំងពីរ** និងសាស្ត្រាចារ្យទាំងអស់ ដែលបង្រៀននៅ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ឱ្យជួបនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានឆ្លងកាត់ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ អស់រយៈពេល ៤ ឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នូវមុខវិជ្ជាជាច្រើនដែលទាក់ទងនឹងវិស័យច្បាប់នៅក្នុងប្រទេសកម្ពុជា ហើយជាពិសេសទាក់ទងនឹង ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ដែលធ្វើឱ្យយើងខ្ញុំទាំងពីរបានទទួលចំណេះដឹងយ៉ាងទូលំទូលាយ ប្រកបដោយភាពច្បាស់លាស់ ក្រោមការយកចិត្តទុកដាក់ពីសំណាក់ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ ។ ដោយមានការជ្រោមជ្រែង និងការយកចិត្តទុកដាក់ដ៏ខ្ពង់ខ្ពស់ក្នុងការបង្ហាត់បង្រៀនអស់ពីកម្លាំងកាយចិត្តទាំងអស់នេះហើយ ទើបធ្វើឱ្យយើងខ្ញុំទាំងពីរអាចឈានមកដល់ការចងក្រងសារណាថ្នាក់បរិញ្ញាបត្រជំនាន់ទី២៤ និងដើម្បីចូលរួមចំណែកក្នុងការចែករំលែកចំណេះដឹងមួយចំនួនដល់និស្សិតជំនាន់ក្រោយផង។ ក្នុងការសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ យើងខ្ញុំបានសម្រេចចិត្តជ្រើសរើសប្រធានបទមួយ ដែលមានជាប់ទាក់ទងយ៉ាងច្រើនលើសលប់ទៅនឹងក្រមនីតិវិធីរដ្ឋប្បវេណី ដែលមានប្រធានបទ "**នីតិវិធីជំនុំជម្រះលើកទី១**" យកមកធ្វើការបង្ហាញ ហើយប្រធានបទនេះជាផ្នែកមួយនៃនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ហើយក៏ជានីតិវិធីដែលសំខាន់ណាស់នៅក្នុងរឿងក្តីរដ្ឋប្បវេណី ដើម្បីយល់ដឹងឲ្យកាន់តែច្បាស់អំពីលំហូរនីតិវិធីនៃការដោះស្រាយវិវាទរដ្ឋប្បវេណី តាមរយៈប្រព័ន្ធតុលាការ។

យើងខ្ញុំសង្ឃឹមថា សារណានេះនឹងក្លាយជាឯកសារជំនួយស្មារតី និងជាឯកសារសម្រាប់សិក្សាស្រាវជ្រាវរបស់មិត្តនិស្សិតបាន យើងខ្ញុំបានព្យាយាមយ៉ាងសកម្មក្នុងការស្រាវជ្រាវឯកសារដែលមានខ្លឹមសារពាក់ព័ន្ធនឹងប្រធានបទមួយនេះតាមរយៈ ច្បាប់ដែលចូលជាធរមាន សៀវភៅ ឯកសារមួយចំនួនទៀតដែលរៀបរៀងដោយក្រសួងយុត្តិធម៌ យោបល់របស់អ្នកវិជ្ជាជីវៈផ្នែកច្បាប់ដែលធ្លាប់អនុវត្តកន្លងមក និងអ៊ីនធើណេត ឬវេបសាយជាច្រើនទៀត ដែលសុទ្ធសឹងតែជាឯកសារដែលអាចយកមកធ្វើជាមូលដ្ឋានក្នុងការសិក្សាស្រាវជ្រាវបាន។ ជាពិសេស ចំពោះលទ្ធផលនៃសារណាបញ្ចប់ការសិក្សាមួយនេះ យើងខ្ញុំសង្ឃឹមថា ស្នាដៃរបស់យើងខ្ញុំនឹងអាចក្លាយជាឯកសារមួយដ៏សំខាន់សម្រាប់ទុកជាឯកសារជំនួយស្មារតីដល់និស្សិតផ្នែកនីតិសាស្ត្រជំនាន់ក្រោយទាំងអស់ រួមទាំងប្រជាពលរដ្ឋទូទាំងប្រទេសផងដែរដោយអាចជួយសម្រួលដល់ការសិក្សាស្រាវជ្រាវលើប្រធានបទ ឬបញ្ហាផ្សេងៗដែលមានខ្លឹមសារពាក់ព័ន្ធ ដើម្បីជួយស្វែងរកដំណោះស្រាយតាមផ្លូវច្បាប់។

យ៉ាងណាមិញ យើងខ្ញុំក៏សូមអភ័យទោសទុកជាមុននូវរាល់កំហុសខុសឆ្គងទាំងឡាយដោយប្រការណាមួយដោយអចេតនានូវពាក្យពេចន៍ ក៏ដូចជាអក្ខរាវិរុទ្ធទាំងឡាយដែលមាននៅក្នុងកិច្ចការស្រាវជ្រាវមួយនេះ ហើយយើងខ្ញុំនឹងទទួលស្វាគមន៍ជានិច្ចនូវរាល់ការរិះគន់ក្នុងន័យស្ថាបនានូវចំណេះដឹងរបស់យើងខ្ញុំ ដើម្បីបំពេញចំណុចខ្វះខាតទាំងនោះឱ្យមកជាល្អគ្រប់ជ្រុងជ្រោយវិញ។

# មាតិកា


**ទំព័រ**

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**ពាក្យបណ្តឹង និងការពិនិត្យពាក្យបណ្តឹង**

**ផ្នែកទី១. អំពីពាក្យបណ្តឹង** ........ ៣

**កថាភាគទី១. អត្ថន័យនៃពាក្យបណ្តឹង** ........ ៣

**កថាភាគទី២. ប្រភេទនៃបណ្តឹង** ........ ៣

១. បណ្តឹងទាមទារឱ្យផ្តល់តាវកាលិក ........ ៣

២. បណ្តឹងទាមទារឱ្យបញ្ជាក់ ........ ៥

៣. បណ្តឹងទាមទារឱ្យបង្កើត កែប្រែ ឬរំលត់ទំនាក់ទំនងគតិយុត្ត ........ ៧

**កថាភាគទី៣. ការសរសេរពាក្យបណ្តឹង** ........ ៩

១. ចំណុចដែលចាំបាច់ត្រូវសរសេរក្នុងពាក្យបណ្តឹង ........ ៩

២. ចំណុចដែលគប្បីសរសេរក្នុងពាក្យបណ្តឹង ........ ១១

**កថាភាគទី៤. ការដាក់ពាក្យបណ្តឹង** ........ ១៣

**កថាភាគទី៥. ការទទួលពាក្យបណ្តឹង** ........ ១៤

១. នីតិវិធីនៃការទទួលពាក្យបណ្តឹង ........ ១៤

២. ឯកសារភ្ជាប់ជាមួយពាក្យបណ្តឹង ........ ១៥

៣. ប្រាក់ប្រដាប់ក្តី ........ ១៦

៣.១. ពន្ធដាក់ពាក្យសុំ ........ ១៦

៣.២. ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ ........ ១៧

៣.៣. ប្រាក់ប្រដាប់ក្តីភាគី ........ ១៨

៣.៤. បន្ទុកនៃប្រាក់ប្រដាប់ក្តី ........ ១៨

**កថាភាគទី៦. ការបែកចែករឿងក្តី** ........ ១៩

១. ការបែងចែករឿងក្តីតាមលំដាប់ដែលបានកំណត់ ........ ១៩

២. ការបែងចែករឿងក្តីទៅឱ្យចៅក្រមម្នាក់ ឬក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ................................ ១៩
**ផ្នែកទី២. ការពិនិត្យពាក្យបណ្តឹង** ........................................................................................ ២០
**កថាភាគទី១. របៀបពិនិត្យពាក្យបណ្តឹង** ........................................................................... ២០
**កថាភាគទី២. ដីកាសម្រេចបង្គាប់ឱ្យកែតម្រូវ និងដីកាសម្រេចលើកពាក្យបណ្តឹងចោល** ... ២១
១. ដីកាសម្រេចបង្គាប់ឱ្យកែតម្រូវ .................................................................................. ២១
២. ដីកាសម្រេចបង្គាប់ឱ្យលើកពាក្យបណ្តឹងចោល ......................................................... ២១
**កថាភាគទី៣. ការបញ្ជូនពាក្យបណ្តឹង** ................................................................................ ២២

## ជំពូកទី២

## ការត្រៀមសម្រាប់ការទាញហេតុផល

**ផ្នែកទី១. គោលបំណងនៃការត្រៀមសម្រាប់ការទាញហេតុផល** ................................. ២៣
**កថាភាគទី១. អត្ថន័យ និងភាពចាំបាច់** ........................................................................... ២៣
**កថាភាគទី២. សិទ្ធិរបស់ចៅក្រម** ..................................................................................... ២៤
**កថាភាគទី៣. សិទ្ធិរបស់ភាគី** ............................................................................................ ២៥
**ផ្នែកទី២. សកម្មភាពក្នុងការត្រៀមសម្រាប់ការទាញហេតុផល** ........................................ ២៦
**កថាភាគទី១. ការសាកល្បងផ្សះផ្សា** .................................................................................. ២៨
**កថាភាគទី២.ករណីការផ្សះផ្សាមិនបានសម្រេច** .............................................................. ២៩
**កថាភាគទី៣. ការថ្លែងពាក្យបណ្តឹង** .................................................................................. ២៩
**កថាភាគទី៤. ការកំណត់ចំណុចវិវាទ** ................................................................................ ៣២
**កថាភាគទី៥. ការស្នើសុំពិនិត្យភស្តុតាង** ............................................................................ ៣៥
**ផ្នែកទី៣. ការបញ្ចប់នៃការត្រៀមសម្រាប់ការទាញហេតុផល** ........................................... ៣៦
**កថាភាគទី១. កំណត់ហេតុស្តីពីការត្រៀមសម្រាប់ការទាញហេតុផល** ..................... ៣៦
**កថាភាគទី២. អានុភាពនៃការបញ្ចប់ការត្រៀមសម្រាប់ការទាញហេតុផល** ............ ៣៧

## ជំពូកទី៣

## ការទាញហេតុផលដោយផ្ទាល់មាត់

**ផ្នែកទី១. គោលបំណងនៃការទាញហេតុផលដោយផ្ទាល់មាត់** .................................... ៣៨

**កថាភាគទី១. អត្ថន័យ និងភាពចាំបាច់**............................................................. ៣៨

**កថាភាគទី២. សិទ្ធិរបស់ចៅក្រម** ................................................................... ៣៩

**កថាភាគទី៣. សិទ្ធិរបស់ភាគី**............................................................................ ៤០

**ផ្នែកទី២. សកម្មភាពក្នុងការទាញហេតុផលដោយផ្ទាល់មាត់**........................................ ៤០

**កថាភាគទី១. ការថ្លែងអំពីលទ្ធផលនៃការត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់** ..៤២

**កថាភាគទី២. ការពិនិត្យភស្តុតាង** ...................................................................... ៤៤

១. ប្រភេទនៃភស្តុតាង ........................................................................................ ៤៥

២. ការថែរក្សាការពារភស្តុតាង.............................................................................. ៤៨

២.១. ភាពចាំបាច់នៃការថែរក្សាការពារភស្តុតាង ........................................................ ៤៨

២.២. ការចាប់ផ្តើមនីតិវិធី.................................................................................. ៤៨

២.៣. ការធ្វើការពិនិត្យភស្តុតាង ............................................................................ ៤៩

២.៤. ការប្រើលទ្ធផលនៃការពិនិត្យភស្តុតាង ............................................................. ៥០

**ផ្នែកទី៣. ការបញ្ចប់នៃការទាញហេតុផលដោយផ្ទាល់មាត់**.......................................... ៥១

**កថាភាគទី១. ការទាញហេតុផលចុងក្រោយ** ......................................................... ៥១

**កថាភាគទី២. អានុភាពនៃការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់**................. ៥២

**សេចក្តីសន្និដ្ឋាន**............................................................................................... ៥៤

**អនុសាសន៍**........................................................................................................ ៥៦

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ក្រមនីតិវិធីរដ្ឋប្បវេណី គឺជាច្បាប់ដ៏ចាំបាច់ក្នុងការកំណត់អំពីបែបបទដែលតុលាការ ក៏ដូចជាភាគីនៃរឿងក្តីត្រូវប្រតិបត្តិតាមនៅក្នុងដំណើរការនៃការដោះស្រាយវិវាទផ្នែករដ្ឋប្បវេណី ដើម្បីឱ្យការដោះស្រាយវិវាទមានភាពឆាប់រហ័ស និងទទួលបានយុត្តិធម៌ដល់គូភាគី។ នៅក្នុងការដោះស្រាយវិវាទផ្នែករដ្ឋប្បវេណី ភាគីនៃវិវាទមានជម្រើសជាច្រើនក្នុងការដោះស្រាយ ពោលគឺភាគីអាចធ្វើការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ឬក៏ធ្វើការដោះស្រាយវិវាទតាមរយៈប្រព័ន្ធតុលាការដែលជាការដោះស្រាយវិវាទដោយបង្ខំ។ ម្យ៉ាងទៀតការស្រាវជ្រាវប្រធានបទមួយនេះទៀតសោត គឺផ្តោតសំខាន់លើលំហូរនីតិវិធីនៃការដោះស្រាយរឿងក្តីរដ្ឋប្បវេណី ដែលប្រព្រឹត្តទៅដោយគ្មានការដាក់ពាក្យបណ្តឹងផ្សេងៗ ក្រៅពីបណ្តឹងដើមនោះទេ ពោលគឺ ជាលំហូរនីតិវិធីមួយដែលប្រព្រឹត្តទៅដោយមិនមានឧបសគ្គអ្វីនោះឡើយ ពោលគឺ ចាប់តាំងពីការដាក់ពាក្យបណ្តឹង រហូតដល់ចេញសាលក្រមចុងក្រោយ។ ទោះបីជាមានច្បាប់គ្រប់គ្រងយ៉ាងណាក៏ដោយ ក៏ជម្លោះនៅតែកើតមានឡើងជៀសមិនផុតដែលជាហេតុនាំឱ្យមានការកើតទុកមិនសុខចិត្តបែបនេះក៏ដោយ ទើបស្ថាប័នតុលាការមានតួនាទីសំខាន់ណាស់លើការដោះស្រាយវិវាទទាំងឡាយ។

ជាក់ស្តែង ដូចជានៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងផ្ទាល់ គឺយើងមាននូវស្ថាប័នតុលាការដែលជាស្ថាប័នឯករាជ្យមួយ និងមានអំណាចដាច់ដោយឡែកក្នុងការអនុវត្តច្បាប់នានា ដែលបានចូលជាធរមាន ដោយបានអនុម័តដោយរដ្ឋសភា និងធ្វើការត្រួតពិនិត្យដោយព្រឹទ្ធសភា ហើយត្រូវបានព្រះមហាក្សត្រប្រកាសឱ្យប្រើជាសាធារណៈទូទាំងប្រទេស។ ជាការពិតណាស់ ច្បាប់ដ៏សំខាន់មួយចំនួនដែលព្រះរាជាណាចក្រកម្ពុជា កំពុងតែអនុវត្តសព្វថ្ងៃនេះ និងមានទំនាក់ទំនងសំខាន់បំផុតសម្រាប់ការរស់នៅរបស់ប្រជាពលរដ្ឋក្នុងការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក ធ្វើអាជីវកម្ម ពាណិជ្ជកម្ម និងការធ្វើសកម្មភាព ឬទំនាក់ទំនងគតិយុត្តផ្សេងៗ គឺមានដូចជា ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី និងច្បាប់ផ្សេងៗទៀត។ល។

ដោយហេតុថា ប្រធានបទរបស់យើងខ្ញុំផ្តោតលើនីតិវិធីបណ្តឹងដែលត្រូវបានប្រើប្រាស់ច្រើននៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ម្យ៉ាងទៀតការដោះស្រាយវិវាទតាមរយៈប្រព័ន្ធតុលាការមានលក្ខណៈស្មុគស្មាញ ដែលតម្រូវឲ្យភាគីមានការយល់ដឹងផ្នែកច្បាប់ច្រើន ទើបក្នុងពេលដោះស្រាយវិវាទរដ្ឋប្បវេណីតាមរយៈប្រព័ន្ធតុលាការ ចៅក្រម ក្រឡាបញ្ជី មេធាវី និងភាគី ត្រូវគោរពតាមវិធាននៃក្រមនីតិវិធីរដ្ឋប្បវេណីឲ្យបានល្អ។ គួរបញ្ជាក់ផងដែរថា នៅក្នុងរឿងក្តីរដ្ឋប្បវេណីមាននីតិវិធីច្រើនដូចជា នីតិវិធីបណ្តឹង នីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិច នីតិវិធីដាស់តឿន នីតិវិធីអនុវត្តដោយបង្ខំ និងនីតិវិធីរក្សាការពារជាដើម ដោយពេលនេះយើងខ្ញុំធ្វើការបកស្រាយដោយផ្តោតសំខាន់លើនីតិវិធីបណ្តឹង ឬនីតិវិធីជំនុំជម្រះលើកទី១តែប៉ុណ្ណោះ។ ដូច្នេះហើយ ការស្រាវជ្រាវលើប្រធានបទ

នីតិវិធីជំនុំជម្រះលើកទី១ នេះ យើងខ្ញុំធ្វើការស្រាវជ្រាវតែលើលំហូរនីតិវិធីជំនុំជម្រះលើកទី១ ដែលធ្វើនៅក្នុងនីតិវិធីបណ្ដឹងធម្មតាតែប៉ុណ្ណោះ។

ដើម្បីយល់ច្បាស់ពីប្រធានបទមួយនេះ យើងស្វែងរកចំណោទបញ្ហាមួយចំនួនដូចខាងក្រោម៖

- **តើពាក្យបណ្ដឹងគេត្រូវសរសេរយ៉ាងដូចម្ដេច?**
- **តើការដាក់ពាក្យបណ្ដឹង និងទទួលពាក្យបណ្ដឹងប្រព្រឹត្តទៅយ៉ាងដូចម្ដេចខ្លះ?**
- **តើការត្រៀមសម្រាប់ការទាញហេតុផលប្រពឹត្តទៅយ៉ាងដូចម្ដេចខ្លះ?**
- **តើការប្រកាសសាលក្រមប្រព្រឹត្តទៅយ៉ាងដូចម្ដេចខ្លះ?**

ចំពោះប្រធានបទនេះ យើងខ្ញុំសិក្សាទៅលើនីតិវិធីជំនុំជម្រះលើកទី១ ដែលមាននៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី និងការអនុវត្តជាក់ស្ដែងក្នុងសង្គម។ ក្រមនីតិវិធីរដ្ឋប្បវេណី គឺជាកូនសោរយ៉ាងសំខាន់ដែលត្រួសត្រាយផ្លូវសម្រាប់នីតិវិធីនៃបណ្ដឹង។ ការសិក្សាស្រាវជ្រាវ គឺពិតណាស់តែងតែជួបការលំបាក ព្រោះយើងត្រូវការចំណាយពេលវេលាច្រើន ចំណាយកម្លាំងកាយចិត្ត ក៏ដូចជាថវិកាជាដើម ជាពិសេសគឺត្រូវមានការព្យាយាមបន្ថែមទៀតផងដែរ ទើបការសិក្សាស្រាវជ្រាវរបស់យើងទទួលបានជោគជ័យ។ បើទោះបីជាមានការលំបាកយ៉ាងណាក៏ដោយ ក៏យើងខ្ញុំនៅតែខិតខំជម្នះឱ្យទាល់តែបាន ពីព្រោះថាការសិក្សាស្រាវជ្រាវប្រធានបទនេះ គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់យើងខ្ញុំ។ ការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ បានធ្វើឡើងចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ រហូតដល់ថ្ងៃទី ១០ ខែសីហា ឆ្នាំ២០២៤។

ដើម្បីឆ្លើយតបទៅនឹងចំណោទបញ្ហាគតិយុត្តខាងលើ និងដើម្បីធ្វើការសិក្សាឱ្យបានគ្រប់ជ្រុងជ្រោយ និងកាន់តែមានភាពស៊ីជម្រៅ ហើយច្បាស់លាស់ទៀតចំពោះនីតិវិធីជំនុំជម្រះលើកទី ១ នេះ យើងខ្ញុំបានធ្វើការបែងចែកជា **០៣ ជំពូក** ដែលក្នុងនោះរួមមាន៖

**ជំពូកទី ១** ៖ ពាក្យបណ្ដឹង និងការពិនិត្យពាក្យបណ្ដឹង

**ជំពូកទី ២** ៖ ការត្រៀមសម្រាប់ការទាញហេតុផល

**ជំពូកទី ៣** ៖ ការទាញហេតុផលដោយផ្ទាល់មាត់។

# ជំពូកទី១

# ពាក្យបណ្តឹង និង

# ការពិនិត្យពាក្យបណ្តឹង

# ជំពូកទី១

# ពាក្យបណ្តឹង និងការពិនិត្យពាក្យបណ្តឹង

## ផ្នែកទី១.អំពីពាក្យបណ្តឹង

### កថាភាគទី១. អត្ថន័យនៃពាក្យបណ្តឹង

បណ្តឹង ជាសកម្មភាពទាមទារមួយដែលដើមចោទ (អ្នកប្តឹងគេ) បានធ្វើចំពោះចុងចម្លើយ (អ្នកដែលត្រូវបានគេប្តឹង) ទៅកាន់តុលាការនៃការជំនុះជម្រះលើកទី១ដែលមានសមត្ថកិច្ចដោយបានលើកឡើងនូវការអះអាងអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តតាមផ្លូវច្បាប់ (ច្បាប់សារធាតុ)។

បណ្តឹងរដ្ឋប្បវេណី គឺជាសិទ្ធិមួយដែលច្បាប់ទទួលស្គាល់សម្រាប់បុគ្គលឯកជនអាចជារូបវន្តបុគ្គល ឬជានីតិបុគ្គល ក្នុងការធ្វើបណ្តឹងទៅស្ថាប័នតុលាការឱ្យជួយដោះស្រាយនូវបញ្ហាដែលកើតមានឡើង ក្នុងគោលបំណងទាមទារឱ្យតុលាការចេញសាលក្រមតាមទាមទារ ដោយផ្អែកតាមភស្តុតាង និងគតិយុត្តច្បាប់។

### កថាភាគទី២. ប្រភេទនៃបណ្តឹង

ប្រភេទនៃបណ្តឹងអាចបែងចែកចេញជាច្រើនប្រភេទ ដោយផ្អែកតាមស្ថានភាពនៃអង្គហេតុដែលបានកើតឡើង ឬទៅតាមបទដ្ឋាននីមួយៗ ដែលជាមូលហេតុធ្វើឱ្យមានការលំបាកនៅក្នុងការកំណត់។ ដូច្នេះហើយទើបគេបានធ្វើការកំណត់បែងចែកប្រភេទនៃបណ្តឹង ចែកចេញទៅជា ៣ ប្រភេទ ដែលមានដូចខាងក្រោមនេះ៖

-បណ្តឹងទាមទារឱ្យផ្តល់តាវកាលិក

-បណ្តឹងទាមទារឱ្យបញ្ជាក់

-បណ្តឹងទាមទារឱ្យបង្កើត កែប្រែ ឬរំលត់ទំនាក់ទំនងគតិយុត្ត។

### ១. បណ្តឹងទាមទារឱ្យផ្តល់តាវកាលិក

បណ្តឹងទាមទារឱ្យផ្តល់តាវកាលិក គឺជាបណ្តឹងមួយដែលទាមទារឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យចុងចម្លើយផ្តល់តាវកាលិកកំណត់មួយដោយផ្អែកលើការអះអាងអំពីអត្ថិភាពនៃសិទ្ធិទាមទារឱ្យផ្តល់តាវកាលិក តាមផ្លូវច្បាប់សារធាតុដែលបានកំណត់នៅក្នុងការទាមទារតាមផ្លូវបណ្តឹង។ ខ្លឹមសារនៃតាវកាលិកវិញ តាមធម្មតាក្រៅពីការបង់ប្រាក់កំណត់មួយ ដូចការទាមទាររបស់ដើមចោទ អាចមានករណីច្រើនដូចជា ការទាមទារឱ្យប្រគល់អចលនវត្ថុ ការទាមទារឱ្យប្រគល់ចលនវត្ថុ និងការទាមទារឱ្យធ្វើសកម្មភាពណាមួយ ឬការទាមទារមិនឲ្យធ្វើសកម្មភាពណាមួយ។

ឧទាហរណ៍១ ៖ បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ចំនួន ១០.០០០ (ដប់ពាន់) ដុល្លារអាមេរិក

ឧទាហរណ៍២ ៖ បង្គាប់ឱ្យចុងចម្លើយប្រគល់រថយន្ត

ឧទាហរណ៍៣ ៖ បង្គាប់ឱ្យចុងចម្លើយត្រូវធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិនៃដី **(អ)** មកឱ្យដើមចោទ

ឧទាហរណ៍៤ ៖ បង្គាប់ឱ្យចុងចម្លើយផ្អាកការសាងសង់របង។

បណ្ដឹងទាមទារឱ្យផ្ដល់តាវកាលិក អាចជាបណ្ដឹងទាមទារឱ្យផ្ដល់តាវកាលិកនាពេលបច្ចុប្បន្ន ឬនាពេលអនាគត។ បណ្ដឹងទាមទារឱ្យផ្ដល់តាវកាលិកនាពេលបច្ចុប្បន្ន គឺជាការទាមទាររបស់ដើមចោទអំពីសិទ្ធិដែលពេលត្រូវអនុវត្តបានមកដល់។ ឧទាហរណ៍ ៖ បង្គាប់ឱ្យចុងចម្លើយរុះរើអាគារចេញពីដី **(អ)** ដោយផ្អែកលើអំឡុងពេលនៃសិទ្ធិជួលត្រូវបានបញ្ចប់។

បណ្ដឹងទាមទារឱ្យផ្ដល់តាវកាលិកនាពេលអនាគត គឺជាការទាមទាររបស់ដើមចោទអំពីសិទ្ធិដែលពេលអនុវត្តមិនទាន់បានមកដល់ ប៉ុន្តែមានភាពចាំបាច់ធ្វើការទាមទារជាមុនបើមិនអញ្ចឹងនោះទេ នឹងនាំឱ្យខូចប្រយោជន៍របស់អ្នកមានសិទ្ធិ ដែលមិនអាចស្ដារឡើងវិញបាន ពីព្រោះអាចព្យាករណ៍ជាមុនបានថា នៅពេលកាតព្វកិច្ចនោះក្លាយជាស្ថាពរ ក៏កូនបំណុលមិនអនុវត្ត ហេតុនេះបណ្ដឹងទាមទារឱ្យផ្ដល់តាវកាលិកនាពេលអនាគត ចាំបាច់ត្រូវមានផលប្រយោជន៍ពិសេសនៃបណ្ដឹង។ ឧទាហរណ៍ ៖ **ក** កូនបំណុល **ខ** ម្ចាស់បំណុល អំឡុងពេលខ្ចី ០៣ ឆ្នាំ ចំនួនប្រាក់កម្ចី ១០០,០០០ (មួយរយពាន់)ដុល្លាអាមេរិក។ កំណត់ពេលសង គឺនៅថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០២២ ប៉ុន្តែនៅឆ្នាំ២០២១ កូនបំណុលបានធ្វើអន្តោប្រវេសន៍ទាំងគ្រួសារ ហេតុនេះទោះបីជាអំឡុងពេលត្រូវសងមិនទាន់មកដល់ក៏ដោយ ក៏ **ខ** អាចទាមទារឱ្យ **ក** សងបានផងដែរ។

ក្នុងការសម្រេចសេចក្ដី បើតុលាការទទួលស្គាល់សិទ្ធិអត្ថិភាពនៃការទាមទារឱ្យផ្ដល់តាវកាលិកដែលបានអះអាងដោយដើមចោទតុលាការត្រូវចេញសាលក្រមបង្គាប់ឱ្យចុងចម្លើយត្រូវផ្ដល់តាវកាលិក ដែលមានខ្លឹមសារកំណត់ដូចការទាមទាររបស់ដើមចោទ សាលក្រមប្រភេទនេះ ហៅថា សាលក្រមបង្គាប់ឱ្យផ្ដល់តាវកាលិក។ សាលក្រមបង្គាប់ឱ្យផ្ដល់តាវកាលិកដែលមានអានុភាពអនុវត្តដោយបង្ខំ ហៅថា«លិខិតអនុវត្ត» ហេតុនេះនៅពេលយកសាលក្រមប្រភេទនេះទៅអនុវត្ត តម្រូវឱ្យមានស្ថាប័នរដ្ឋជាអ្នកចាត់ចែង ហៅថា «ស្ថាប័នអនុវត្ត»។ នៅក្នុងស្ថាប័នអនុវត្តមានអង្គភាពពីរ ទី១ អាជ្ញាសាលា ទី២ តុលាការអនុវត្ត។ ស្ថាប័នអាជ្ញាសាលា ជាស្ថាប័នទទួលបន្ទុកអនុវត្តដោយបង្ខំពាក់ព័ន្ធនឹងការរឹបអូសចលនវត្ថុ ការប្រគល់វត្ថុ និងការស្រាវជ្រាវស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុដែលត្រូវបានរឹបអូស ជាអាទិ៍។ តុលាការអនុវត្ត ជាស្ថាប័នទទួលបន្ទុកអនុវត្តដោយបង្ខំពាក់ព័ន្ធនឹងការរឹបអូសអចលនវត្ថុ និងសិទ្ធិលើបំណុល ជាអាទិ៍។

ទោះបីជាសាលក្រមផ្តល់តាវកាលិកមានអានុភាពអនុវត្តដោយបង្ខំក៏ដោយ ប៉ុន្តែដើម្បីអនុវត្តដោយបង្ខំលុះត្រាតែភ្ជាប់នូវរូបមន្តអនុវត្ត និងត្រូវនឹងប្រភេទណាមួយនៃលិខិតអនុវត្ត[1]។

សាលក្រមបង្គាប់ឱ្យផ្តល់តាវកាលិក ភាគីអាចសុំឱ្យអនុវត្តដោយបង្ខំបាន ដើម្បីអាចឱ្យដើមចោទសម្រេចគោលបំណងនៃការទាមទារ លើកលែងតែតាវកាលិកដែលមានលក្ខណៈជាការបង្ហាញឆន្ទៈ(សាលក្រមចាត់ទុកថាបង្ហាញឆន្ទៈ) ដូចជា ករណីទាមទារឱ្យចុះបញ្ជីដីធ្លី ជាអាទិ៍។

ក្នុងករណីតុលាការមិនទទួលស្គាល់នូវការទាមទារដែលអះអាងដោយដើមចោទ តុលាការត្រូវចេញសាលក្រមដែលមានខ្លឹមសារថា **ច្រានចោលការទាមទាររបស់ដើមចោទ**។ សាលក្រមបែបនេះ ពុំមានអានុភាពអនុវត្តនោះទេ ប៉ុន្តែមានអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុដែលកំណត់ជាស្ថាពរអំពីនត្ថិភាពនៃសិទ្ធិទាមទារឱ្យផ្តល់តាវកាលិករបស់ដើមចោទ។

### ២.បណ្តឹងទាមទារឱ្យបញ្ជាក់

បណ្តឹងទាមទារឱ្យបញ្ជាក់ គឺជាបណ្តឹងដែលទាមទារឱ្យតុលាការចេញសាលក្រមបញ្ជាក់នូវអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដោយផ្អែកលើការអះអាងរបស់ដើមចោទនូវសិទ្ធិ ឬទំនាក់ទំនងគតិយុត្តកំណត់មួយដែលជាការទាមទារតាមផ្លូវបណ្តឹង។

ក្នុងចំណោមនោះ បណ្តឹងដែលអះអាងនូវអត្ថិភាពនៃសិទ្ធិជាអាទិ៍ គេហៅថា បណ្តឹងទាមទារឱ្យបញ្ជាក់ដោយសកម្ម ហើយបណ្តឹងដែលអះអាងនូវនត្ថិភាពនៃសិទ្ធិនោះ គេហៅថា បណ្តឹងទាមទារឱ្យបញ្ជាក់អកម្ម។

ឧទាហរណ៍១ ៖ ដើមចោទទាមទារឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារបញ្ជាក់ថាដី **(អ)** ដូចមានកំណត់នៅក្នុងបញ្ជីឧបសម្ព័ន្ធជាកម្មសិទ្ធិរបស់ដើមចោទ(បញ្ជាក់អំពីអត្ថិភាពនៃកម្មសិទ្ធិ)។

ឧទាហរណ៍២៖ ដើមចោទទាមទារឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារបញ្ជាក់ថា ដើមចោទមិនមានករណីយកិច្ចបង់ប្រាក់ទៅឱ្យចុងចម្លើយ ដូចមានកំណត់នៅក្នុងបញ្ជីឧបសម្ព័ន្ធនៃសិទ្ធិលើបំណុល (បញ្ជាក់អំពីនត្ថិភាពនៃសិទ្ធិលើបំណុល)។

ឧទាហរណ៍៣៖ ដើមចោទទាមទារឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារបញ្ជាក់ថា ដើមចោទមានសិទ្ធិជួលនៅលើដីដូចមានកំណត់នៅក្នុងបញ្ជីឧបសម្ព័ន្ធ(បញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិជួល)។

[1]មាត្រា ៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ឧទាហរណ៍៤៖ ដើមចោទទាមទារឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារបញ្ជាក់ថា ដើមចោទមានសិទ្ធិសេរភាពនៅលើដីដូចមានកំណត់នៅក្នុងបញ្ជីឧបសម្ព័ន្ធ(បញ្ជាក់អំពីនត្ថិភាពនៃសេរភាព)។

កម្មវត្ថុនៃបណ្តឹងទាមទារឱ្យបញ្ជាក់ ត្រូវតែជាការអះអាងអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តជាក់ស្តែង។ បណ្តឹងទាមទារឱ្យបញ្ជាក់ គឺបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាព ឬទំនាក់ទំនងគតិយុត្តតែប៉ុណ្ណោះ ប៉ុន្តែក្នុងករណីពិសេស អាចបញ្ជាក់អំពីភាពត្រឹមត្រូវនៃឯកសារស្តីពីទំនាក់ទំនងគតិយុត្តជាអាទិ៍ ក្នុងគោលដៅបញ្ជាក់អំពីឆន្ទៈរបស់ជនដែលបានធ្វើលិខិតនោះ ហើយជាលទ្ធផលនៃការបញ្ជាក់នាំឱ្យភាគីលែងមានវិវាទ។

ឧទាហរណ៍១៖ បណ្តឹងទាមទារឱ្យបញ្ជាក់អំពីភាពត្រឹមត្រូវនៃការធ្វើឯកសារកិច្ចសន្យា ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៦ រវាងដើមចោទ **ក** និងចុងចម្លើយ **ខ**។

ការទាមទារនៅក្នុងបណ្តឹងទាមទារឱ្យបញ្ជាក់ ត្រូវតែជាការអះអាងអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត «នាពេលបច្ចុប្បន្ន» ហើយជាបណ្តឹងដែលត្រូវបានធ្វើឡើងដើម្បីការពារផលប្រយោជន៍របស់ភាគី ក្នុងគោលបំណងដោះស្រាយវិវាទជាក់លាក់ណាមួយ ហេតុនេះមិនអាចធ្វើបណ្តឹងទាមទារឱ្យបញ្ជាក់អំពីមោឃភាពច្បាប់ អនុក្រឹត្យ ប្រកាស ឬសេចក្តីសម្រេចផ្នែករដ្ឋបាលបានឡើយ។

ឧទាហរណ៍២ ៖ ដើមចោទទាមទារឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារថាបញ្ជាក់អំពីមោឃភាពនៃច្បាប់ស្តីពីភតិសន្យាពិសេស។ ការទាមទារបែបនេះគឺខុសច្បាប់។

បណ្តឹងទាមទារឱ្យបញ្ជាក់មិនអាចបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុនោះទេ ហើយភាគីក៏មិនអាចទាមទារឱ្យបញ្ជាក់អំពីសុពលភាព ឬមោឃភាពនៃបទដ្ឋានគតិយុត្ត។

ទោះបីជាអាចធ្វើបណ្តឹងទាមទារឱ្យបញ្ជាក់ក៏ដោយ ប៉ុន្តែលុះត្រាតែការបញ្ជាក់នោះមានផលប្រយោជន៍បណ្តឹងជាក់ស្តែង ដោយអាចប្រើសាលក្រមដើម្បីដោះស្រាយតាមច្បាប់ និងអាចបញ្ចប់វិវាទជាក់ស្តែងរបស់ភាគី បើមិនអញ្ចឹងនោះទេ ចាត់ទុកថាគ្មានផលប្រយោជន៍នៃបណ្តឹង ហេតុនេះទោះបីជាបណ្តឹងបញ្ជាក់នេះត្រូវបានដាក់ក៏តុលាការនឹងចេញសាលក្រមលើកចោលបណ្តឹង ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់។

ក្នុងការសម្រេចសេចក្តី បើតុលាការទទួលស្គាល់សិទ្ធិអត្ថិភាពនៃការទាមទារឱ្យបញ្ជាក់ដែលបានអះអាងដោយដើមចោទ តុលាការត្រូវចេញសាលក្រមដែលមានខ្លឹមសារកំណត់ដូចការទាមទាររបស់ដើមចោទ សាលក្រមប្រភេទនេះ ហៅថា សាលក្រមទាមទារឱ្យបញ្ជាក់។

សាលក្រមទាមទារឱ្យបញ្ជាក់ ភាគីមិនអាចសុំឲ្យអនុវត្តដោយបង្ខំបាន ដោយសារខ្លឹមសារនៃការសម្រេចនេះ គ្មានអានុភាពអនុវត្តដោយបង្ខំ គឺជាការសម្រេចអំពីទំនាក់ទំនងគតិយុត្ត ឬសិទ្ធិសារធាតុរបស់ភាគីតែប៉ុណ្ណោះ។ ក្នុងករណីតុលាការមិនទទួលស្គាល់នូវការទាមទារដែលអះអាងដោយដើមចោទ តុលាការត្រូវចេញសាលក្រមដែលមានខ្លឹមសារថា ច្រានចោលការទាមទាររបស់ដើមចោទ។ សាលក្រមបែបនេះ ពុំមានអានុភាពអនុវត្តនោះទេ ប៉ុន្តែមានអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុដែលកំណត់ជាស្ថាពរអំពីនត្ថិភាព នៃសិទ្ធិទាមទារឱ្យបញ្ជាក់របស់ដើមចោទ។

សាលក្រមទាមទារឱ្យបញ្ជាក់ ក៏អនុវត្តចំពោះការទាមទារអកម្ម ដូចជាបញ្ជាក់អំពីនត្ថិភាពនៃសិទ្ធិលើបំណុលជាអាទិ៍ ដោយបញ្ជាក់ថាកូនបំណុលមិនមានកាតព្វកិច្ចសងប្រាក់ចុងចម្លើយ។ ខ្លឹមសារនៃការបញ្ជាក់នេះ ក៏មានអានុភាពនៃអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុចំពោះការវិនិច្ឆ័យថា «ដើមចោទពុំមានកាតព្វកិច្ចចំពោះចុងចម្លើយ»។ ចំពោះចុងចម្លើយសាលក្រមប្រភេទនេះ ជាសាលក្រមបញ្ជាក់ជាស្ថាពរនូវនត្ថិភាពនៃសិទ្ធិលើបំណុល។ សាលក្រមនេះ ពុំមានអានុភាពអនុវត្តដោយបង្ខំនោះទេ ហើយក៏មិនអាចក្លាយជាលិខិតអនុវត្ត និងមិនមានភាពចាំបាច់ក្នុងការអនុវត្តដោយបង្ខំឡើយ។ សាលក្រមទាំងឡាយណាដែល មិនស្ថិតក្នុងមាត្រា ៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណីដែលចែងអំពីប្រភេទនៃលិខិតអនុវត្ត គឺមិនអាចយកសាលក្រមទាំងនោះទៅអនុវត្តដោយបង្ខំឡើយ ហេតុនេះមិនមានភាពចាំបាច់សុំរូបមន្តអនុវត្តនោះទេ។

### ៣.បណ្តឹងទាមទារឱ្យបង្កើត កែប្រែ ឬរំលត់ទំនាក់ទំនងគតិយុត្ត

បណ្តឹងទាមទារឱ្យបង្កើត កែប្រែ ឬរំលត់ទំនាក់ទំនងគតិយុត្ត គឺជាបណ្តឹងដែលទាមទារឱ្យតុលាការចេញសាលក្រមប្រកាសបង្កើតជាថ្មីនូវទំនាក់ទំនងគតិយុត្ត(ការបង្កើត ការកែប្រែ ឬការរំលត់) ដោយផ្អែកលើការអះអាងអំពីអត្ថិភាពនៃសិទ្ធិបង្កើត ឬអំពីមូលហេតុនៃការបង្កើតទំនាក់ទំនងគតិយុត្តកំណត់មួយដែលជាការទាមទារតាមផ្លូវបណ្តឹង។

ជាទូទៅ ច្បាប់ទទួលស្គាល់នូវការបង្កើតទំនាក់ទំនងគតិយុត្តថ្មីដោយផ្អែកលើឆន្ទៈរបស់ភាគី ប៉ុន្តែស្ថានភាពមួយចំនួន ការបង្ហាញឆន្ទៈរបស់ភាគីមិនមានលក្ខណៈគ្រប់គ្រាន់ និងសមរម្យនោះទេ ដោយត្រូវតម្រូវឱ្យមានការអន្តរាគមន៍របស់តុលាការ តាមរយៈពាក្យបណ្តឹងរបស់ភាគី ដែលមានប្រយោជន៍ក្នុងការកំណត់ទំនាក់ទំនងគតិយុត្តថ្មីនោះ។

បណ្តឹងទាមទារឱ្យបង្កើត កែប្រែ ឬរំលត់ទំនាក់ទំនងគតិយុត្ត អាចជាបណ្តឹងឋានៈបុគ្គល ឬទំនាក់ទំនងគតិយុត្តថ្មីទាំងឡាយណា ដែលច្បាប់សារធាតុតម្រូវឱ្យមានអន្តរាគមន៍របស់តុលាការក្នុងការបង្កើត កែប្រែ ឬរំលត់ទំនាក់ទំនងគតិយុត្តជាអាទិ៍។

ឧទាហរណ៍១៖ បណ្ដឹងទាមទារលែងលះ បណ្ដឹងទាមទារលុបចោល ឬមោឃភាពនៃអាពាហ៍ពិពាហ៍

ឧទាហរណ៍២៖ ការទាមទារឱ្យបែងចែកកម្មវត្ថុនៃកម្មសិទ្ធិអវិភាគ

ឧទាហរណ៍៣៖ ការទាមទារឱ្យលុបចោលនូវអំពើនាំឱ្យខូចប្រយោជន៍

ឧទាហរណ៍៤៖ ដើមចោទទាមទារឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារថា បន្ថយថ្លៃឈ្នួល

ឧទាហរណ៍៥៖ បណ្ដឹងកាត់កាល់(ទំនាក់ទំនងឳពុកម្ដាយ កូនចិញ្ចឹម)

ឧទាហរណ៍៦៖ បណ្ដឹងទាមទារឱ្យទទួលស្គាល់

ឧទាហរណ៍៧៖ បណ្ដឹងបដិសេធបិតុភាព។

ការទាមទារតាមផ្លូវបណ្ដឹងនៃបណ្ដឹងទាមទារឱ្យបង្កើត កែប្រែ ឬរំលត់ទំនាក់ទំនងគតិយុត្ត ត្រូវអះអាងអំពីសិទ្ធិបង្កើត កែប្រែ ឬរំលត់ទំនាក់ទំនងគតិយុត្ត ដែលបានកំណត់ជាក់លាក់ណាមួយជាអាទិ៍ ឬអះអាងអំពីអត្ថិភាពមូលហេតុនៃការបង្កើត កែប្រែ ឬរំលត់ទំនាក់ទំនងគតិយុត្ត។

បណ្ដឹងទាមទារឱ្យបង្កើត កែប្រែ ឬរំលត់ទំនាក់ទំនងគតិយុត្ត ជាទូទៅពាក់ព័ន្ធនឹងទំនាក់ទំនងញាតិសន្តតិកម្ម និងមានទំនាក់ទំនងជាមួយនឹងតតិយជន ហេតុនេះបណ្ដឹងបែបនេះអាចត្រូវបានទទួលស្គាល់ លុះត្រាតែមានកំណត់ជាក់លាក់នៅក្នុងបទដ្ឋានគតិយុត្តជាធរមាន។

សិទ្ធិបង្កើត កែប្រែ ឬរំលត់ទំនាក់ទំនងគតិយុត្តដែលទាមទារនេះ មិនអាចបង្ហាញត្រឹមឆន្ទៈរបស់ភាគីនោះទេ ដើម្បីបង្កើតអានុភាព ច្បាប់សារធាតុតម្រូវឱ្យធ្វើការទាមទារតាមផ្លូវបណ្ដឹង ដោយមានអន្តរាគមន៍របស់តុលាការ ដោយហេតុថា សិទ្ធិ ឬទំនាក់ទំនងគតិយុត្តទាំងនេះ មានលក្ខណៈលើសពីផលប្រយោជន៍របស់ភាគី ឬមានផលប្រយោជន៍របស់តតិយជន ឬមានផលប្រយោជន៍សាធារណៈ ជាអាទិ៍។

ក្នុងការសម្រេចសេចក្ដី បើតុលាការទទួលស្គាល់សិទ្ធិអត្ថិភាពនៃការទាមទារឱ្យបង្កើត កែប្រែ ឬរំលត់ទំនាក់ទំនងគតិយុត្ត ដែលបានអះអាងដោយដើមចោទ តុលាការត្រូវចេញសាលក្រមដែលមានខ្លឹមសារកំណត់ដូចការទាមទាររបស់ដើមចោទ សាលក្រមប្រភេទនេះ ហៅថា សាលក្រមទាមទារឱ្យបង្កើត កែប្រែ ឬរំលត់ទំនាក់ទំនងគតិយុត្ត។ សាលក្រមប្រភេទនេះ មានអានុភាពប្រតិសកម្ម ឬមានអានុភាពឆ្ពោះទៅអនាគត (សាលក្រមលុបចោលអាពាហ៍ពិពាហ៍ ជាអាទិ៍)។ សាលក្រមប្រភេទនេះមានអានុភាពប្រតិសកម្ម ឬឆ្ពោះទៅអនាគតត្រូវកំណត់ដោយច្បាប់សារធាតុ[2]។

---

[2] សៀវភៅមេរៀនស្ដីពីនីតិវិធីបណ្ដឹងរបស់លោកមេធាវី អ៊ីវ ប៉ូលី

សាលក្រមទាមទារឱ្យបង្កើត កែប្រែ ឬរំលត់ទំនាក់ទំនងគតិយុត្ត សម្រាប់ករណីជាក់លាក់មួយចំនួនមានអានុភាពចំពោះតតិយជន ដូចជា សាលក្រមលែងលះ ជាអាទិ៍។

សាលក្រមទាមទារឱ្យបង្កើត កែប្រែ ឬរំលត់ទំនាក់ទំនងគតិយុត្ត ភាគីមិនអាចសុំឱ្យអនុវត្តដោយបង្ខំបានទេ ដោយសារខ្លឹមសារនៃការសម្រេចនេះ គ្មានអានុភាពអនុវត្តដោយបង្ខំ គឺជាការសម្រេចអំពីទំនាក់ទំនងគតិយុត្ត ឬសិទ្ធិសារធាតុរបស់ភាគីតែប៉ុណ្ណោះ។ ក្នុងករណីតុលាការមិនទទួលស្គាល់នូវការទាមទារដែលអះអាងដោយដើមចោទ តុលាការត្រូវចេញសាលក្រមដែលមានខ្លឹមសារថា ច្រានចោលការទាមទាររបស់ដើមចោទ។ សាលក្រមបែបនេះ ពុំមានអានុភាពអនុវត្តនោះទេ ប៉ុន្តែមានអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុដែលកំណត់ជាស្ថាពរអំពីនត្ថិភាពនៃសិទ្ធិទាមទាររបស់ដើមចោទ។

## កថាភាគទី៣. ការសរសេរពាក្យបណ្ដឹង

### ១. ចំណុចដែលចាំបាច់ត្រូវសរសេរក្នុងពាក្យបណ្ដឹង

ពាក្យបណ្ដឹង ត្រូវធ្វើជាលាយលក្ខណ៍អក្សរដាក់ទៅតុលាការ ហើយចំណុចដែលត្រូវសរសេរនៅក្នុងពាក្យបណ្ដឹងត្រូវអនុលោមតាមមាត្រា ៧៥ កថាខណ្ឌទី ២ ចំណុច "ក និងខ" នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ផ្អែកតាមមាត្រានេះ នៅក្នុងពាក្យបណ្ដឹងចាំបាច់ត្រូវសរសេរនូវចំណុចដូចខាងក្រោម៖

#### ក.អត្តសញ្ញាណរបស់ភាគី

ក្នុងពាក្យបណ្ដឹងត្រូវសរសេរឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគីឱ្យបានច្បាស់លាស់។ ការសរសេរឈ្មោះ និងអាសយដ្ឋានរបស់ភាគីឱ្យបានច្បាស់លាស់ត្រឹមត្រូវ គឺជាភាពចាំបាច់សម្រាប់បញ្ជាក់អំពីអត្តសញ្ញាណរបស់ភាគីព្រមទាំងសម្រាប់ធ្វើការបញ្ជូនពាក្យបណ្ដឹង និងឯកសារផ្សេងៗទៅភាគីចុងចម្លើយ[3]។ ភាគីមានដូចជា ដើមចោទ និងចុងចម្លើយជាដើម។

-ក្នុងករណីភាគីនៃបណ្ដឹងជារូបវន្តបុគ្គលចាំបាច់ត្រូវសរសេរអំពីឈ្មោះ និងអាសយដ្ឋានរបស់ភាគីនៅក្នុងពាក្យបណ្ដឹង។

-ក្នុងករណីភាគីនៃបណ្ដឹង គឺជាជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព ដូចជាអនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ ក្រៅពីឈ្មោះ និងអាសយដ្ឋានរបស់ភាគី ចាំបាច់ត្រូវសរសេរអំពីឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។ អ្នកតំណាងដែលច្បាប់បានកំណត់របស់អនីតិជន

[3]មាត្រា ៧៥ កថាខណ្ឌទី២ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

គឺអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ចំណែកឯអ្នកតំណាងដែលច្បាប់បានកំណត់របស់ជននៅក្រោមអាណាព្យាបាលទូទៅ គឺអ្នកអាណាព្យាបាលទូទៅ។

-ក្នុងករណីភាគីនៃបណ្តឹងជានីតិបុគ្គល ចាំបាច់ត្រូវសរសេរនាមករណ៍ និងអាសយដ្ឋានរបស់នីតិបុគ្គល ហើយឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងនីតិបុគ្គល។ អ្នកតំណាងឱ្យនីតិបុគ្គល គឺជាបុគ្គលដែលមានកំណត់នៅក្នុងលក្ខន្តិកៈជាអាទិ៍។ អ្នកតំណាងនីតិបុគ្គលអនុវត្តសិទ្ធិដូចអ្នកតំណាងដែលច្បាប់កំណត់ផងដែរ។

### ខ. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ

ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ ជាចំណុចដែលចាំបាច់ត្រូវសរសេរនៅក្នុងពាក្យបណ្តឹងមានន័យថា នៅក្នុងពាក្យបណ្តឹងយ៉ាងហោចណាស់ ដើមចោទត្រូវតែសរសេរនូវចំណុចទាំងនេះ ដើម្បីឱ្យតុលាការបានដឹងថា ដើមចោទចង់ទាមទារអ្វី? ផ្អែកលើសិទ្ធិសារធាតុ? ការទាមទារនេះ ជាការទាមទាររបស់នរណាចំពោះនរណា? ការសរសេរអំពីខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារនៅក្នុងពាក្យបណ្តឹងនឹងនាំឱ្យតុលាការអាចកំណត់អំពីភាគីនៃបណ្តឹង (នរណាទាមទារចំពោះនរណា) និងសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលមានកំណត់នៅក្នុងច្បាប់សារធាតុ (គោលបំណងដែលដើមចោទចង់បាន និងមូលដ្ឋាននៃការទាមទារ)។

- **ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ**

ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ ជាចំណុចដើមចោទចង់ឲ្យតុលាការសរសេរក្នុងសេចក្តីសម្រេចបញ្ចប់នៃសាលក្រម (បើតុលាការទទួលស្គាល់ការទាមទារ សេចក្តីសម្រេចបញ្ចប់នឹងមានខ្លឹមសារដូចគ្នានឹងចំណុចស្តីពីខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ ដែលសរសេរនៅក្នុងពាក្យបណ្តឹង)។

ហេតុនេះ ដើមចោទត្រូវសរសេរបញ្ជាក់ឲ្យបានច្បាស់លាស់អំពីខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់ដែលខ្លួនទាមទារតាមរយៈពាក្យបណ្តឹង។ ចំណុចដែលត្រូវសរសេរនៅក្នុងខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ គឺការទាមទាររបស់ដើមចោទដូចជា ទាមទារប្រាក់ ប្រគល់វត្ថុ ឲ្យធ្វើ ឬមិនឲ្យធ្វើសកម្មភាពមួយទាមទារលែងលះ ឬទាមទារទទួលស្គាល់កូន ជាដើម។ ការទាមទារដែលមានកំណត់នៅក្នុង

ពាក្យបណ្ដឹង ជាការកំណត់អំពីទំហំនៃការវិនិច្ឆ័យ និងសម្រេចសេចក្ដីតាមរយៈសាលក្រម ហេតុនេះ តុលាការមិនអាចសម្រេចលើសពីអ្វីដែលភាគីមិនបានសុំនោះទេ។

ដើម្បីសរសេរនូវខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញបានត្រឹមត្រូវ និងមានភាពច្បាស់លាស់ និងអាចអនុវត្តបាន គប្បីស្វែងយល់អំពីប្រភេទនៃបណ្ដឹង មិនគួរសរសេរអំពីលក្ខណៈសារធាតុនៃសិទ្ធិចូលក្នុងចំណុចស្ដីពីខ្លឹមសារនៃសាលក្រម ដែលដើមចោទទាមទារឱ្យតុលាការចេញឡើយ ហើយធ្វើយ៉ាងណាឱ្យចំណុចនេះមានភាពច្បាស់លាស់ ងាយស្រួលយល់ និងអនុវត្តបានជាសត្យានុម័ត។

- **អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ**

ការទាមទារ គឺជាការអះអាងអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តតាមផ្លូវច្បាប់ដែលបានកំណត់មួយរបស់ដើមចោទចំពោះចុងចម្លើយ ហេតុនេះអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ គឺជាអង្គហេតុដែលបង្ហាញអំពីមូលដ្ឋាននៃការទាមទាររបស់ដើមចោទ និងបញ្ជាក់ថាសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលជាមូលដ្ឋាននៃការទាមទារនោះបានកើតឡើង។ ឧទាហរណ៍៖ ប្រសិនបើនៅក្នុងពាក្យបណ្ដឹងសរសេរថាដើមចោទទាមទារឱ្យចុងចម្លើយបង់ប្រាក់ចំនួន ១០.០០០(ដប់ពាន់)ដុល្លារអាមេរិក នោះតុលាការនឹងមិនដឹងថាដើមចោទទាមទារដោយប្រើសិទ្ធិអ្វីនោះទេ ពីព្រោះការទាមទារប្រាក់ ១០.០០០(ដប់ពាន់)ដុល្លារអាមេរិក អាចជាការទាមទារដែលកើតចេញពីការលក់ទិញ ឬប្រាក់កម្ចី ឬកិច្ចសន្យាជួល ឬកិច្ចសន្យាម៉ៅការ ឬអំពើអនីត្យានុកូល ឬសេចក្ដីចម្រើនដោយឥតហេតុជាអាទិ៍ ហេតុនេះ ការកំណត់ថា តើការទាមទារនោះផ្អែកលើសិទ្ធិទាមទារអ្វី ត្រូវពិនិត្យមើលលើអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ។

**២. ចំណុចដែលគប្បីសរសេរក្នុងពាក្យបណ្ដឹង**

ក្រៅពីខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ ដើមចោទគប្បីសរសេរនូវអង្គហេតុដែលជាមូលហេតុនៃការទាមទារ និងអង្គហេតុសំខាន់ៗក្នុងចំណោមអង្គហេតុដែលជាមូលហេតុនៃការទាមទារនៅក្នុងពាក្យបណ្ដឹងរួមទាំងភស្តុតាង។

**ក. អង្គហេតុដែលជាមូលហេតុនៃការទាមទារ**

ទោះបីជាការទាមទារ ត្រូវបានបញ្ជាក់តាមរយៈអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារក៏ដោយ ក៏តុលាការមិនអាចដឹងបានថា តើការទាមទារនោះមានមូលហេតុយ៉ាងណា ហេតុនេះដើមចោទចាំបាច់ត្រូវអះអាងថា មានមូលហេតុនៃការទាមទាររបស់ខ្លួន ហើយប្រសិនបើដើមចោទមិនបានអះអាងនូវចំណុចនេះទេ នាំឱ្យពុំមានការពន្យល់អំពីមូលហេតុនៃការទាមទារឡើយ។

ប្រសិនបើដើមចោទទាមទារឱ្យចុងចម្លើយបង់ប្រាក់ ១០០.០០០(មួយរយពាន់) ដុល្លារអាមេរិក ហើយបញ្ជាក់ថា ជាការទាមទារផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ អង្គហេតុនេះមិនគ្រប់គ្រាន់ទេក្នុងការបញ្ជាក់អំពីមូលហេតុនៃការទាមទារ ពីព្រោះយើងមិនដឹងថា តើមានការព្រមព្រៀងគ្នាប្រគល់ប្រាក់ជាក់ស្តែងឬយ៉ាងណា? តើកំណត់ពេលសងបានមកដល់ហើយឬនៅ? ហេតុនេះហើយ ត្រូវអះអាងនូវអង្គហេតុដែលជាមូលហេតុនៃការទាមទារ។ អង្គហេតុដែលជាមូលហេតុនៃការទាមទារ គឺមានសរសេរនៅក្នុងច្បាប់សារធាតុ ពីព្រោះច្បាប់សារធាតុមានសរសេរថា ប្រសិនបើបំពេញលក្ខខណ្ឌនាំឱ្យសិទ្ធិនិងកាតព្វកិច្ចកើតឡើង មានន័យថា ដើមចោទមានមូលហេតុនៃការទាមទារ (សិទ្ធិ) របស់ខ្លួនដោយអះអាងអំពីលក្ខខណ្ឌត្រូវបានបំពេញ។ ដើម្បីទាមទារឱ្យសងប្រាក់កម្ចីផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ ដើមចោទត្រូវអះអាងអង្គហេតុដែលជាមូលហេតុនៃការទាមទារទី១ ការព្រមព្រៀងឱ្យខ្ចីនិងសងវិញ ទី២ ការប្រគល់ប្រាក់ និងទី៣ កំណត់ពេលសងបានមកដល់ហេតុនេះ ដើមចោទអះអាងអំពីសិទ្ធិរបស់ខ្លួនតាមរយៈការអះអាងនូវលក្ខខណ្ឌទាំងនេះ។

ការសរសេរអំពីអង្គហេតុដែលជាមូលហេតុនៃការទាមទារ គឺជាការពន្យល់តុលាការអំពីមូលហេតុនៃការទាមទារ ហើយដើម្បីឱ្យតុលាការអាចទទួលស្គាល់នូវអង្គហេតុទាំងនោះបាន ចាំបាច់ត្រូវផ្អែកលើភស្តុតាងហេតុនេះ ដើមចោទត្រូវបញ្ជាក់ភស្តុតាងតាមចំណុចនីមួយៗនៃអង្គហេតុដែលជាមូលហេតុនៃការទាមទារ។

### ខ. អង្គហេតុសំខាន់ៗ ក្នុងចំណោមអង្គហេតុដែលជាមូលហេតុនៃការទាមទារ

ជាអង្គហេតុប្រយោល មានន័យថា ក្នុងករណីភាគីមិនអាចបញ្ជាក់ភស្តុតាងចំពោះអង្គហេតុដែលជាមូលហេតុនៃការទាមទារ (អង្គហេតុផ្ទាល់) ការប្រើប្រាស់អង្គហេតុប្រយោល គឺជាមធ្យោបាយមួយដែលអាចឲ្យតុលាការជឿថា មានអង្គហេតុដោយផ្ទាល់។ ប្រសិនបើដើមចោទបានអះអាងអង្គហេតុដែលជាមូលហេតុនៃការទាមទារ និងបញ្ជាក់ភស្តុតាងចំពោះអង្គហេតុទាំងនោះ ពុំមានភាពចាំបាច់ត្រូវធ្វើការអះអាងអំពីអង្គហេតុសំខាន់ៗក្នុងចំណោមអង្គហេតុដែលជាមូលហេតុនៃការទាមទារនោះទេ។ ការអះអាងអំពីអង្គហេតុសំខាន់ៗ ក្នុងចំណោមអង្គហេតុដែលជាមូលហេតុនៃការទាមទារ មិនមែនជាចំណុចដែលដាច់ខាតត្រូវសរសេរនៅក្នុងពាក្យបណ្តឹងនោះទេ មានន័យថា ទោះបីជាដើមចោទមិនបានសរសេរអំពីអង្គហេតុសំខាន់ៗក្នុងចំណោមអង្គហេតុដែលជាមូលហេតុនៃការទាមទារនៅក្នុងពាក្យបណ្តឹងក៏ដោយ ពាក្យបណ្តឹងនោះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ ហើយអាចបន្តនីតិវិធីទៅមុខបាន ប៉ុន្តែប្រសិនបើដើមចោទបានអះអាងអំពីមូលហេតុនៃការទាមទារដោយគ្មានភស្តុតាងផ្ទាល់ដើម្បីបញ្ជាក់ នោះតុលាការនឹងមានចម្ងល់ តើពិតជាមានអង្គហេតុដូចការអះអាងរបស់ដើមចោទ ឬទេ? ហេតុនេះ ក្នុងករណីពុំមានភស្តុតាងផ្ទាល់ដើម្បីបញ្ជាក់នូវអង្គហេតុដែលជាមូលហេតុនៃការទាមទារទេ (អង្គហេតុផ្ទាល់) ការអះអាងនូវអង្គហេតុប្រយោល និងបញ្ជាក់ភស្តុតាងប្រយោលអាចឱ្យតុលាការទទួលស្គាល់អំពីអង្គហេតុដែលជាមូលហេតុនៃការទាមទារបាន។

## កថាភាគទី៤. ការដាក់ពាក្យបណ្តឹង

នីតិវិធីរដ្ឋប្បវេណីនៅតុលាការត្រូវចាប់ផ្តើមនៅពេលដែលមានការដាក់ពាក្យបណ្តឹង។ ពាក្យបណ្តឹងដែលបានចាត់ទុកថាបានដាក់នៅពេលដែលដើមចោទនោះបានដាក់ពាក្យបណ្តឹងនោះនៅតុលាការ ហើយត្រូវបានបុគ្គលិកផ្នែករដ្ឋបាលទទួលពាក្យបណ្តឹងរដ្ឋប្បវេណីបោះត្រា និងចុះលេខចូលថាបានទទួល។

បណ្តឹងត្រូវធ្វើជាលាយលក្ខណ៍អក្សរទៅតុលាការ[4] លើកលែងតែមានបញ្ញត្តិផ្សេង ដែលច្បាប់អនុញ្ញាតឲ្យធ្វើដោយផ្ទាល់មាត់ ជាក់ស្តែងក្នុងមាត្រា២២៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ អនុញ្ញាតឲ្យធ្វើបណ្តឹងដោយផ្ទាល់មាត់ក្នុងករណីដែលបណ្តឹងនៃរឿងក្តីដែលមានចំនួនទឹកប្រាក់តិច[5]។

បានន័យថា ជាគោលការណ៍ការដាក់ពាក្យបណ្តឹងត្រូវធ្វើឡើងដោយដើមចោទទៅតុលាការដែលត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ស្របតាមបញ្ញត្តិនៃមាត្រា ៧៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី លើកលែងតែរឿងក្តីដែលមានចំនួនទឹកប្រាក់តិច គឺអាចដាក់ពាក្យបណ្តឹងដោយផ្ទាល់មាត់បាន។ ការប្តឹង គឺជាសកម្មភាពមួយដែលទាមទារឱ្យបំពេញនូវលក្ខខណ្ឌជាក់លាក់មួយជាកំណត់ ដោយការប្រគល់ពាក្យបណ្តឹងដែលភ្ជាប់ជាមួយលក្ខខណ្ឌទម្រង់ ដើម្បីឱ្យមានភាពច្បាស់លាស់នូវអង្គហេតុនៃការធ្វើបណ្តឹងទៅតាមនីតិវិធី។

ពាក្យបណ្តឹងមានអានុភាព នៅពេលដែលការបញ្ជូនពាក្យបណ្តឹងបានទៅដល់ចុងចម្លើយ ពោលគឺមិនមែននៅពេលដាក់ពាក្យបណ្តឹងនោះទេ មានន័យថា ស្ថានភាពដែលតុលាការត្រូវការធ្វើការជំនុំជម្រះ និងចេញសាលក្រម នឹងកើតឡើងរវាងដើមចោទ និងចុងចម្លើយជាកំណត់។

នៅក្នុងអានុភាពនៃការដាក់ពាក្យបណ្តឹង នាំឱ្យបង្កើតមាននូវអានុភាពសំខាន់ជាងគេ គឺ**ការហាមឃាត់បណ្តឹងជាន់គ្នា**[6]។ ការហាមឃាត់បណ្តឹងជាន់គ្នា ជាការហាមនូវការដាក់ពាក្យបណ្តឹងក្រោយដែលមានខ្លឹមសារដូចគ្នា នឹងបណ្តឹងដែលបានដាក់មុន ហើយកំពុងត្រូវបានតុលាការចាត់ការ (ភាគីដូចគ្នា សិទ្ធិ ឬទំនាក់ទំនងគតិយុត្តតាមផ្លូវច្បាប់សារធាតុ ដែលត្រូវបានអះអាងក្នុងការទាមទារតាមផ្លូវបណ្តឹងដូចគ្នា ទោះបីជាឋានៈរបស់ដើមចោទ និងចុងចម្លើយផ្ទុយគ្នាក៏ដោយ)។ ក្នុងករណីណាដែលមានបណ្តឹងជាន់គ្នា តុលាការអាចលើកចោលបណ្តឹងនោះ ដោយសាលក្រមដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់[7]។

[4]មាត្រា ៧៥ កថាខណ្ឌទី១ និងមាត្រា ៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[5]មាត្រា ២២៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[6]មាត្រា ៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[7]មាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

## កថាភាគទី៥. ការទទួលពាក្យបណ្ដឹង

បច្ចុប្បន្នស្ថាប័នតុលាការមាននូវលេខាធិកាដ្ឋាន ដែលជាអង្គការសម្រាប់ជំនួយដល់ការងាររដ្ឋបាល របស់ស្ថាប័នតុលាការហើយការងាររដ្ឋបាលទាំងអស់នោះ ក៏មានចំណុចដែលពាក់ព័ន្ធនឹងការទទួលពាក្យបណ្ដឹងនេះ។

ក្រឡាបញ្ជីត្រូវទទួលពាក្យបណ្ដឹងពីមន្ត្រីដែលទទួលបន្ទុកផ្នែករដ្ឋបាល ដោយបោះត្រាបញ្ជាក់ថ្ងៃ ខែ ឆ្នាំ ដែលបានទទួលពាក្យបណ្ដឹងនោះ ដើម្បីបញ្ជាក់ឱ្យបានច្បាស់ថាអំពីកាលបរិច្ឆេទនៃការដាក់ពាក្យបណ្ដឹង ចូលមកតុលាការ[8]។

ក្រឡាបញ្ជីត្រូវបែងចែកសំណុំរឿងនៃបណ្ដឹងទៅតាមចៅក្រមដែលទទួលបន្ទុកនូវរឿងក្ដីនោះ តាមលំដាប់នៃការបែងចែករឿងក្ដីដែលកំណត់ប្រចាំឆ្នាំជាមុនដោយប្រធានតុលាការ[9]។

បណ្ដឹងត្រូវចាប់ផ្ដើមដោយការដាក់ពាក្យបណ្ដឹង ប៉ុន្តែមុនពេលពាក្យបណ្ដឹងត្រូវបានបញ្ជូនទៅចុងចម្លើយ អានុភាពនៃបណ្ដឹងមានចំពោះតែដើមចោទ និងតុលាការតែប៉ុណ្ណោះ។ នីតិវិធីចាប់ផ្ដើមនៅពេលដែលចុងចម្លើយបានទទួលការបញ្ជូនពាក្យបណ្ដឹង ពេលនោះទំនាក់ទំនងគតិយុត្តរវាង ដើមចោទ ចុងចម្លើយ និងតុលាការបានកើតឡើង ហេតុនេះ មុនពេលបង្កើតឱ្យមានទំនាក់ទំនងគតិយុត្តចំពោះចុងចម្លើយ តុលាការត្រូវមានភាពចាំបាច់ត្រូវធ្វើការពិនិត្យពាក្យបណ្ដឹងជាមុនសិន ហើយដំណាក់កាលនៃការពិនិត្យពាក្យបណ្ដឹង ជាដំណាក់កាលសំខាន់ក្នុងការសម្រេចថា តើអាចបន្តនីតិវិធីទៅមុខបានដែរឬយ៉ាងណា។

### ១. នីតិវិធីនៃការទទួលពាក្យបណ្ដឹង

នៅពេលដែលមានការដាក់ពាក្យបណ្ដឹងនៅតុលាការ ជាក់ស្ដែងដែលអនុវត្តប្រចាំថ្ងៃនៅសាលាដំបូងរាជធានីភ្នំពេញ អ្នកមានភារៈទទួលពាក្យបណ្ដឹងអនុវត្តតាមជំហានដូចខាងក្រោម៖

(ក) មន្ត្រីរដ្ឋបាលផ្នែកទទួលបន្ទុកពាក្យបណ្ដឹងរដ្ឋប្បវេណី ជាអ្នកវាយត្រាលើពាក្យបណ្ដឹងដែលបានទទួល ហើយចុះកាលបរិច្ឆេទនៃការទទួល និងចុះលេខរៀងនៅក្នុងសៀវភៅទទួលពាក្យបណ្ដឹងរួមទាំងចេញបង្កាន់ដៃបង់ប្រាក់ផងដែរ។

ទន្ទឹមនឹងនេះ មុនពេលទទួលពាក្យបណ្ដឹងមកធ្វើចំណាត់ការដូចខាងលើ មន្ត្រីរដ្ឋបាលផ្នែកទទួលបន្ទុកពាក្យបណ្ដឹងគួរពិនិត្យមើលពាក្យបណ្ដឹងមួយភ្លែតសិន ហើយបើសិនមានការខ្វះខាតមន្ត្រីរដ្ឋបាលផ្នែក

[8]មាត្រា ២៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[9]មាត្រា ២៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ទទួលបន្ទុកពាក្យបណ្តឹង គប្បីពន្យល់ឱ្យអ្នកដាក់ពាក្យបណ្តឹងធ្វើការកែតម្រូវពីចំណុចខ្វះខាតនោះសិន។ ចំណុចដែលមន្ត្រីរដ្ឋបាលផ្នែកទទួលបន្ទុកពាក្យបណ្តឹង គប្បីពន្យល់ដល់អ្នកដាក់ពាក្យអំពីការសរសេរបណ្តឹងត្រឹមត្រូវតាមមាត្រា ៧៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី (១. ចំណុចត្រូវសរសេរក្នុងពាក្យបណ្តឹងខាងលើ) និង (២. សមត្ថកិច្ចសាលាជំនុំជម្រះក្តីនៃតុលាការដែលទទួលពាក្យបណ្តឹង[10])។

(ខ) មន្ត្រីរដ្ឋបាលនោះ ត្រូវបញ្ជូនពាក្យបណ្តឹងទៅឱ្យប្រធានតុលាការ។

(គ) ប្រធានតុលាការ ចារឈ្មោះចៅក្រម ទទួលបន្ទុកតាមលំដាប់បន្ទាប់ដែលបានកំណត់លើសាមីនៃពាក្យបណ្តឹងនោះ ហើយមន្ត្រីរដ្ឋបាលនោះត្រូវយកសាមីនៃពាក្យបណ្តឹងនោះ ទៅឱ្យក្រឡាបញ្ជីរដ្ឋបាលនៃបន្ទប់ចៅក្រមទទួលបន្ទុកនោះ។

(ឃ) ក្រឡាបញ្ជីរដ្ឋបាលនោះ ត្រូវទទួលសាមីនៃពាក្យបណ្តឹងនោះ ហើយយកទៅឱ្យចៅក្រមទទួលបន្ទុកនោះ និងចៅក្រមនោះត្រូវចារឈ្មោះក្រឡាបញ្ជីណាជាអ្នកកាន់ពាក្យបណ្តឹងនោះ(រឿងក្តី)លើសាមីនៃពាក្យបណ្តឹងនោះ។

(ង) ក្រឡាបញ្ជីរដ្ឋបាលនោះ ត្រូវយកសាមីពាក្យបណ្តឹងចុះក្នុងសៀវភៅទទួលពាក្យបណ្តឹងរបស់ខ្លួន។

### ២. ឯកសារភ្ជាប់ជាមួយពាក្យបណ្តឹង

ការដាក់ពាក្យបណ្តឹង ត្រូវមានឯកសារភ្ជាប់មកជាមួយពាក្យបណ្តឹង ដោយសារឯកសារដែលភ្ជាប់មកជាមួយ គឺបញ្ជាក់ឱ្យបានច្បាស់លាស់នូវក្នុងបណ្តឹង។

ដោយយោងតាមមាត្រា ៧៥ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី គឺទាក់ទងទៅនឹងអ្នកដាក់ពាក្យបណ្តឹង ហើយអ្នកដាក់ពាក្យបណ្តឹងមានច្រើនប្រភេទ ដូចជា ភាគី អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកតំណាងនៃនីតិបុគ្គល និងអ្នកតំណាងដោយអាណត្តិ។ ដូច្នេះ ប្រសិនបើអ្នកតំណាងទាំងនោះ ត្រូវបានម្ចាស់បណ្តឹងប្រគល់សិទ្ធិឱ្យដូចនេះ ត្រូវតែមានលិខិតបញ្ជាក់សិទ្ធិតំណាងនោះ ហើយសិទ្ធិតំណាងនោះមានខាងក្រោម ៖

(ក) បើជាអ្នកតំណាងដែលច្បាប់បានកំណត់ ដូចជា ឪពុកម្តាយ តំណាងឱ្យកូនជា អនីតិជន ឬអ្នកអាណាព្យាបាល គឺលិខិតបញ្ជាក់សិទ្ធិនោះ ដោយជាលាយលក្ខណ៍អក្សរ[11]។ បើជាឪពុកម្តាយ លិខិតបញ្ជាក់

[10]មាត្រា ៨ និងមាត្រា ៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[11]មាត្រា ៣៥ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

នោះអាចជាសំបុត្រកំណើតរបស់កូន សៀវភៅគ្រួសារ សៀវភៅស្នាក់នៅជាដើម។ បើជាអាណាព្យាបាល លិខិតបញ្ជាក់សិទ្ធិតំណាង គឺជាសេចក្តីសម្រេចរបស់តុលាការ។

(ខ) បើជាអ្នកតំណាងនៃនីតិបុគ្គល ត្រូវអនុវត្តដូចអ្នកតំណាងដែលច្បាប់បានកំណត់គឺ លិខិតបញ្ជាក់សិទ្ធិនោះ ដោយជាលាយលក្ខអក្សរ[12]។

(គ) អ្នកតំណាងដោយអាណត្តិ ត្រូវមានលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ និងលិខិតតំណាងដោយអាណត្តិ[13]។

ម៉្យាងវិញទៀត ក្រៅពីឯកសារដែលបានរៀបរាប់ខាងលើក៏មានឯកសារភ្ជាប់ជាមួយពាក្យបណ្តឹងផងដែរ ដូចជា ឯកសារភស្តុតាង(ឯកសារថតចម្លងពីច្បាប់ដើម)សម្រាប់ធ្វើការទាមទារ និងឯកសារពាក់ព័ន្ធផ្សេងទៀត (ឯកសារថតចម្លង)។

**៣. ប្រាក់ប្រដាប់ក្តី**

ប្រាក់ប្រដាប់ក្តី គឺជាពន្ធដែលភាគីត្រូវធ្វើនៅពេលធ្វើសកម្មភាពបណ្តឹង ដើម្បីធានាសកម្មភាពបណ្តឹង និងជាសោហ៊ុយចំណាយក្នុងនីតិវិធីបណ្តឹង។

នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ប្រាក់ប្រដាប់ក្តី ត្រូវបានបែងចែកជា ៣ ប្រភេទ គឺ ពន្ធដាក់ពាក្យសុំ ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ និងប្រាក់ប្រដាប់ក្តីភាគី។

**៣.១ ពន្ធដាក់ពាក្យសុំ**

ពន្ធដាក់ពាក្យសុំ គឺជាពន្ធដែលតុលាការតម្រូវឱ្យបង់ជាមុនដោយអ្នកដាក់ពាក្យសុំ ដូចជា ពន្ធនៃការដាក់ពាក្យបណ្តឹង ឬពាក្យសុំផ្សេងៗ (ពាក្យសុំចាត់ចែងរក្សាការពារពាក្យសុំចូលរួមអន្តរាគមន៍ជាអាទិ៍) ដែលទាក់ទងនឹងសកម្មភាពបណ្តឹង[14]។

ការគណនាពន្ធ គឺយកតម្លៃកម្មវត្ថុនៃបណ្តឹងមកធ្វើជាមូលដ្ឋាន ដូចមានចែងនៅក្នុង មាត្រា ៦១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ តម្លៃកម្មវត្ថុនៃបណ្តឹង ត្រូវបានគណនាដោយផ្អែកលើមូលដ្ឋាននៃផលប្រយោជន៍ ដែលបានទាមទារក្នុងបណ្តឹងនោះ ហើយក្នុងករណីមានការទាមទារច្រើនចំណុចក្នុងបណ្តឹងតែមួយ តម្លៃសរុបនៃការ

[12]មាត្រា ៣៥ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[13]មាត្រា ៤៥ និងមាត្រា ៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[14]មាត្រា ៦១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ទាមទារនោះត្រូវចាត់ទុកជាតម្លៃកម្មវត្ថុនៃបណ្ដឹង[15]។ ចំពោះការទាមទារលើផលសំណងនៃការខូចខាត ប្រាក់ធានាសងក្នុងករណីបំពានកិច្ចសន្យា ឬសោហ៊ុយ ដែលជាកម្មវត្ថុបន្ទាប់បន្សំនៃបណ្ដឹង មិនត្រូវបូកសរុបលើការគណនាតម្លៃកម្មវត្ថុនៃបណ្ដឹងឡើយ[16]។ ប៉ុន្តែក្នុងករណី មានការពិបាកក្នុងការគណនាតម្លៃកម្មវត្ថុនៃបណ្ដឹង តុលាការត្រូវកំណត់ តម្លៃនោះដោយឆន្ទានុសិទ្ធិ ឬប្រសិនបើតម្លៃនោះមិនអាចគណនាបានទេ នោះត្រូវចាត់ទុកថា តម្លៃកម្មវត្ថុនៃបណ្ដឹងមានចំនួនប្រាំលានប្រាំសែនរៀល[17]។

### ៣.២. ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ

ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ គឺជាប្រាក់ប្រដាប់ក្ដីត្រូវបង់ទៅតុលាការដែលភាគី ឬបុគ្គលដែលទាក់ទងនឹងរឿងក្ដី ត្រូវបង់ជាមុនសម្រាប់ការចំណាយរបស់តុលាការ ដែលធ្វើសកម្មភាពតាមនីតិវិធីនៅក្នុងបណ្ដឹងរដ្ឋប្បវេណីទៅតាមចំនួនទឹកប្រាក់ដែលកំណត់ដោយតុលាការមានៈ

(ក) ចំនួនទឹកប្រាក់ចាំបាច់ដើម្បីឱ្យតុលាការធ្វើការពិនិត្យភស្តុតាង ការបញ្ជូនឯកសារ ឬសកម្មភាពផ្សេងទៀត តាមនីតិវិធីនៃបណ្ដឹង

(ខ) ចំនួនទឹកប្រាក់ស្មើនឹងសោហ៊ុយធ្វើដំណើរ និងសោហ៊ុយស្នាក់នៅដែលចាំបាច់សម្រាប់ចៅក្រម និងក្រឡាបញ្ជី ក្នុងករណីដែលត្រូវធ្វើការពិនិត្យភស្តុតាង ការស្រាវជ្រាវអង្គហេតុ ឬសកម្មភាពផ្សេងទៀត ដែលប្រព្រឹត្តនៅក្រៅតុលាការ[18]។ ចំពោះប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ តុលាការត្រូវបង្គាប់ឱ្យភាគី ឬបុគ្គលដែលទាក់ទងនឹងរឿងក្ដីបង់ជាមុន ប៉ុន្តែប្រសិនបើសាមីខ្លួនពុំព្រមបង់ជាមុនទេ តុលាការអាចមិនធ្វើសកម្មភាពដែលចាំបាច់នោះ ឬតុលាការអាចប្រមូលពីអ្នកដែលត្រូវទទួលបន្ទុកលើការបង់ប្រាក់ប្រដាប់ក្ដីទាំងមូល អាស្រ័យលើដីកាសម្រេចរបស់តុលាការ (ករណីតុលាការធ្វើសកម្មភាពចាំបាច់នោះ ទោះបីជាភាគីមិនបង់ជាមុននូវសោហ៊ុយចំណាយក៏ដោយ)[19]។

[15]មាត្រា ៦០ កថាខណ្ឌទី១ វាក្យខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[16]មាត្រា ៦០ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[17]មាត្រា ៦០ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[18]មាត្រា ៦២ កថាខណ្ឌទី១ ចំណុច "ក" និង "ខ" នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[19]មាត្រា ៦២ កថាខណ្ឌទី៣ និងកថាខណ្ឌទី៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

### ៣.៣.ប្រាក់ប្រដាប់ក្តីភាគី

ប្រាក់ប្រដាប់ក្តីរបស់ភាគី គឺជាប្រាក់ប្រដាប់ក្តីដែលកំណត់ដោយតុលាការ ដោយពិចារណានូវលក្ខណៈនៃរឿងក្តី ឬលទ្ធភាពនៃទ្រព្យធនរបស់ភាគី ជាអាទិ៍។ សោហ៊ុយដូចមានកំណត់ខាងក្រោម ត្រូវចាត់ទុកថាជាប្រាក់ប្រដាប់ក្តីភាគី៖

ទី១ សោហ៊ុយធ្វើលិខិតបណ្តឹង ពាក្យសុំផ្សេងៗ ឬឯកសារផ្សេងៗដូចជា ឯកសារត្រៀម និងថ្លៃដាក់ឯកសារទាំងនោះទៅតុលាការ។ ឧទាហរណ៍៖ ដើមចោទពឹងអ្នករកស៊ីរៀបចំបណ្តឹង ដោយត្រូវបង់៣០ (សាមសិប)ដុល្លារអាមេរិកជាអាទិ៍ ករណីនេះ ហៅថា សោហ៊ុយធ្វើលិខិតបណ្តឹង។ សោហ៊ុយធ្វើលិខិតបណ្តឹងជាប្រាក់ប្រដាប់ក្តីភាគី។

ទី២ សោហ៊ុយធ្វើដំណើរ ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ ឬសោហ៊ុយសម្រាប់ភាគី ឬអ្នកតំណាង ដើម្បីបង្ហាញខ្លួនតាមកាលបរិច្ឆេទដែលត្រូវបានកំណត់ដោយតុលាការជាអាទិ៍។ ឧទាហរណ៍ ៖ ដើមចោទបានស្នើសុំតុលាការសាកសួរសាក្សី ថ្លៃធ្វើដំណើររបស់សាក្សីមកតុលាការ ត្រូវចំណាយប្រាក់អស់១០(ដប់)ដុល្លារអាមេរិក។ សោហ៊ុយនេះ ហៅថា ប្រាក់ប្រដាប់ក្តីភាគី។

ទី៣ សោហ៊ុយៗផ្សេងដែលតុលាការទទួលស្គាល់ថាចាំបាច់សម្រាប់អនុវត្តនីតិវិធីបណ្តឹង ជាអាទិ៍។ ឧទាហរណ៍ ៖ សោហ៊ុយសម្រាប់ការស្នើសុំចតចម្លងឯកសារព័ត៌មានសុរិយោដី សោហ៊ុយវាស់វែងដី ឬសោហ៊ុយរៀបចំនីតិវិធីជាអាទិ៍។

### ៣.៤. បន្ទុកនៃប្រាក់ប្រដាប់ក្តី

បន្ទុកនៃប្រាក់ប្រដាប់ក្តី គឺជាការកំណត់នូវកាតព្វកិច្ច ក្នុងការបង់ប្រាក់ប្រដាប់ក្តីរបស់ភាគីនៃបណ្តឹង។ ជាគោលការណ៍ ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចាញ់ក្តី ហើយក្នុងករណីភាគីចាញ់ក្តីតែមួយភាគ តុលាការត្រូវសម្រេចនូវបន្ទុកដែលភាគីម្នាក់ៗត្រូវទទួលដោយឆន្ទានុសិទ្ធិ[20]។ ប៉ុន្តែតុលាការក៏អាចឱ្យភាគីឈ្នះក្តីទទួលបន្ទុកប្រាក់ប្រដាប់ក្តីទាំងអស់ ឬមួយផ្នែកបាន ក្នុងករណីភាគីឈ្នះក្តី បានប្រព្រឹត្តសកម្មភាពបណ្តឹងណាមួយដែលមិនចាំបាច់ក្នុងការតទល់ ឬការពារខ្លួន ឬបានធ្វើឱ្យនីតិវិធីបណ្តឹងយឺតយ៉ាវ[21]។ ការសម្រេចអំពីបន្ទុកនៃប្រាក់ប្រដាប់ក្តី គឺជាការសម្រេចរបស់តុលាការនៃថ្នាក់នៃការជំនុំជម្រះក្តី នោះដោយឆន្ទានុសិទ្ធិ[22]។

[20]មាត្រា ៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[21]មាត្រា ៦៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[22]មាត្រា ៦៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ក្រោយពីពេលសេចក្តីសម្រេចអំពីបន្ទុកប្រាក់ប្រដាប់ក្តីបង្កើតអានុភាព ភាគីអាចដាក់ពាក្យសុំទៅក្រឡាបញ្ជីរបស់តុលាការនោះឱ្យកំណត់ជាស្ថាពរអំពីចំនួនប្រាក់ប្រដាប់ក្តី[23]។

ក្នុងករណីភាគីមិនសុខចិត្តនឹងការចាត់ចែងរបស់ក្រឡាបញ្ជី ក្នុងការកំណត់ចំនួនប្រាក់ប្រដាប់ក្តី ភាគីអាចធ្វើបណ្តឹងតវ៉ាចំពោះការចាត់ចែងនោះ ក្នុងអំឡុងពេល ១ សប្តាហ៍ ក្រោយពីបានទទួលដំណឹង ហើយប្រសិនបើ តុលាការទទួលស្គាល់ថា បណ្តឹងតវ៉ាចំពោះការចាត់ចែងរបស់ក្រឡាបញ្ជីមានមូលហេតុត្រឹមត្រូវ តុលាការត្រូវកំណត់ចំនួនបន្ទុកប្រាក់ប្រដាប់ក្តីដោយខ្លួនឯង[24]។

## កថាភាគទី៦. ការបែកចែករឿងក្តី

### ១. ការបែងចែករឿងក្តីតាមលំដាប់ដែលបានកំណត់

ដោយផ្អែកទៅលើតុលាការ ការបែងចែករឿងក្តី និងលំដាប់សម្រាប់ជំនួស ក្នុងករណីដែលចៅក្រមណាម្នាក់មានធុរៈត្រូវកំណត់ជាមុននៅរៀងរាល់ឆ្នាំ ដោយដីកាសម្រេចរបស់ប្រធានតុលាការ។ ដោយសារមានដីកាសម្រេចនេះចៅក្រមម្នាក់ ឬចៅក្រមប្រឹក្សាជំនុំជម្រះទទួលបន្ទុកជាស្វ័យប្រវត្តិ ដើម្បីដោះស្រាយរឿងក្តីណាមួយតាមលំដាប់សម្រាប់ចៅក្រមម្នាក់ និងលំដាប់សម្រាប់ក្រុមប្រឹក្សាជំនុំជម្រះ។

### ២. ការបែងចែករឿងក្តីទៅឱ្យចៅក្រមម្នាក់ ឬក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម

ចៅក្រមម្នាក់ ឬដោយក្រុមប្រឹក្សាជំនុំជម្រះ ជំនុំជម្រះរឿងក្តីមួយ អាស្រ័យទៅតាមប្រភេទនៃរឿងក្តីដែលច្បាប់កំណត់ឬភាពស្មុគស្មាញនៃរឿងក្តីដែលទទួលស្គាល់ដោយតុលាការ។ ការបែងចែករឿងក្តីទៅឱ្យចៅក្រមម្នាក់ ឬក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រមមានដូចក្រោម៖

(ក) រឿងក្តីដែលមានកម្មវត្ថុនៃបណ្តឹងមានតម្លៃមិនតិចជាងប្រាំលានរៀល ហើយដែលតុលាការទទួលស្គាល់ថា គួរតែត្រូវបានវិនិច្ឆ័យ និងជម្រះដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ដោយគិតពិចារណាអំពីចំនួននៃគូភាគី និងបញ្ហាផ្សេងទៀត ប្រសិនបើជារឿងក្តីដែលច្បាប់បានកំណត់ថាត្រូវធ្វើការវិនិច្ឆ័យ និងជម្រះក្តីដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម រឿងក្តីនោះត្រូវបែងចែកទៅឱ្យក្រុមប្រឹក្សាជំនុំជម្រះ ដែលមានសមាសភាពចៅក្រមចំនួន បី រូប ដោយធ្វើតាមលំដាប់នៃការបែងចែករឿងក្តីសម្រាប់ក្រុមប្រឹក្សាជំនុំជម្រះ[25]។ ក្នុងករណីនេះ ការ

---

[23]មាត្រា ៦៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[24]មាត្រា ៦៦ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[25] មាត្រា ២៣ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

សម្រេចថាតើរឿងក្តីនោះត្រូវវិនិច្ឆ័យ និងជម្រះក្តីដោយក្រុមប្រឹក្សាជំនុំជម្រះ ឬចៅក្រមម្នាក់ ត្រូវតាមដីកាសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ។

(ខ) គ្រប់រឿងក្តីទាំងអស់លើកលែងតែចំណុច (ក) ខាងលើត្រូវធ្វើការបែងចែកទៅឱ្យចៅក្រមម្នាក់ ដោយត្រូវធ្វើទៅតាមលំដាប់នៃការបែងចែករឿងក្តីសម្រាប់ចៅក្រមម្នាក់។

## ផ្នែកទី២. ការពិនិត្យពាក្យបណ្តឹង

ចៅក្រមដែលទទួលនូវការបែងចែករឿងក្តី ត្រូវពិនិត្យពាក្យបណ្តឹង។ ការពិនិត្យពាក្យបណ្តឹង គឺជាការពិនិត្យភាពស្រប ឬមិនស្របនឹងលក្ខខណ្ឌនៃទម្រង់តែប៉ុណ្ណោះ ហេតុនេះ មិនអនុញ្ញាតឱ្យតុលាការពិនិត្យថា តើការទាមទារតាមផ្លូវបណ្តឹងមានឬគ្មានមូលហេតុត្រឹមត្រូវ ឬការទាមទារស្របនឹងផលប្រយោជន៍លក្ខខណ្ឌនៃបណ្តឹងនោះទេ[26]។

តុលាការត្រូវពិនិត្យលើពាក្យបណ្តឹង ហើយការពិនិត្យនោះត្រឹមតែលក្ខខណ្ឌនៃទម្រង់តែប៉ុណ្ណោះ។ ការពិនិត្យបណ្តឹងផ្តោតទៅលើចំណុចស្តីពីភាគី ចំណុចស្តីពីខ្លឹមសារនៃសាលក្រមដែលខ្លឹមសារឱ្យតុលាការចេញ និងអង្គហេតុចាំបាច់បញ្ជាក់នៃការទាមទារ ហើយវិធីក្នុងការបញ្ជាក់ថា តើពាក្យបណ្តឹងមានបានសរសេរខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារមានភាពត្រឹមត្រូវដែរឬទេ តុលាការត្រូវប្រើវិធីបញ្ជាក់ចំនួនពីរ គឺ កំណត់ភាគី និងសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវអះអាង។ ក្នុងករណីធាតុផ្សំទាំងពីរត្រូវបានបំពេញនៅក្នុងខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ មានន័យថា ពាក្យបណ្តឹងនោះត្រូវតាមទម្រង់ ហើយតុលាការនឹងបញ្ជូនពាក្យបណ្តឹងទៅចុងចម្លើយ នាំឱ្យនីតិវិធីបណ្តឹងនឹងមានដំណើរការបន្ត។ ផ្ទុយមកវិញ ប្រសិនបើ ពាក្យបណ្តឹងសរសេរមិនបានពេញលេញដោយផ្អែកតាមមាត្រា ៧៥ កថាខណ្ឌទី២ តុលាការត្រូវបង្គាប់ឱ្យកែតម្រូវក្នុងអំឡុងពេលសមរម្យ ហើយបើភាគីមិនធ្វើការកែតម្រូវទេ តុលាការនឹងលើកពាក្យបណ្តឹងចោលដោយដីកាសម្រេច។

### កថាភាគទី១. របៀបពិនិត្យពាក្យបណ្តឹង

ក្រោយពីរឿងក្តីត្រូវបានបញ្ជូនមកចៅក្រមម្នាក់ ឬក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រមរួច ហើយចៅក្រមម្នាក់ ឬក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រមត្រូវពិនិត្យពាក្យបណ្តឹង។ ក្នុងការពិនិត្យពាក្យបណ្តឹងមានលក្ខណៈពីរប្រភេទ ដូចតទៅ ៖

---

[26]មាត្រា ៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

(ក) ការពិនិត្យពាក្យបណ្តឹងចៅក្រមម្នាក់ ឬក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រមអាចចេញដីកាបង្គាប់ឱ្យកែតម្រូវ និងចេញដីកាសម្រេចលើកពាក្យបណ្តឹងចោល បើចៅក្រមម្នាក់ ឬក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រមពិនិត្យឃើញថា ការសរសេរក្នុងពាក្យបណ្តឹងមិនទាន់គ្រប់គ្រាន់នៅឡើយ ដោយផ្អែកតាមមាត្រា ៧៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី និងដើមចោទបានបង់ពន្ធដាក់ពាក្យបណ្តឹងហើយឬនៅ។

(ខ) ការពិនិត្យពាក្យបណ្តឹង គឺដើម្បីធ្វើឱ្យនីតិវិធីរឿងក្តីឱ្យបានឆាប់រហ័ស ចៅក្រមម្នាក់ ឬក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ត្រូវពិនិត្យមើលទៅលើអង្គហេតុនៃការទាមទារ និងអង្គហេតុសំខាន់ដែលពាក់ព័ន្ធនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ និងភស្តុតាងសំខាន់ៗជាអាទិ៍ មានសរសេរ និងភ្ជាប់មកជាមួយពាក្យបណ្តឹង។ ការពិនិត្យត្រង់ចំណុចនេះ មានគោលបំណងចាត់ការរឿងក្តីឱ្យមានប្រសិទ្ធិភាពដែលធ្វើឱ្យមានលក្ខណៈងាយស្រួលដល់ការរៀបចំចំណុចវិវាទ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផងដែរ។ ការពិនិត្យពាក្យបណ្តឹងក្នុងចំណុចនេះ ទោះបីជាដើមចោទមិនព្រមកែតម្រូវក៏ដោយនូវចំណុចដែលគប្បីសរសេរ[27] ក៏ចៅក្រមម្នាក់ ឬក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រមមិនអាចលើកពាក្យបណ្តឹងចោលបានទេ។ ផ្ទុយមកវិញ ចៅក្រមម្នាក់ ឬក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រមត្រូវតែកំណត់កាលបរិច្ឆេទនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ហើយត្រូវទាមទារឱ្យដើមចោទពន្យល់បន្ថែមក្នុងកាលបរិច្ឆេទនោះប៉ុណ្ណោះ។

## កថាភាគទី២. ដីកាសម្រេចបង្គាប់ឱ្យកែតម្រូវ និងដីកាសម្រេចលើកពាក្យបណ្តឹងចោល

### ១. ដីកាសម្រេចបង្គាប់ឱ្យកែតម្រូវ

តាមបញ្ញត្តិមាត្រា ៧៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ក្នុងករណីដែលពាក្យបណ្តឹងផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី២ នៃមាត្រា៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការកំណត់អំឡុងពេលសមរម្យ និងបង្គាប់ឱ្យកែតម្រូវចំណុចខ្វះចំពោះពាក្យបណ្តឹងនោះ។ ដោយឡែកដីកាសម្រេចបង្គាប់ឱ្យកែតម្រូវ ត្រូវយកមកអនុវត្តផងដែរ ចំពោះករណីដែលដើមចោទមិនទាន់បានបង់ពន្ធសម្រាប់ដាក់ពាក្យបណ្តឹងនៅឡើយ។

### ២. ដីកាសម្រេចបង្គាប់ឱ្យលើកពាក្យបណ្តឹងចោល

តាមបញ្ញតិមាត្រា៧៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រសិនបើដើមចោទមិនបានកែតម្រូវចំណុចខ្វះតាមដីកាសម្រេចបង្គាប់ឱ្យកែតម្រូវទេ តុលាការត្រូវលើកពាក្យបណ្តឹងចោល ដោយដីកាសម្រេច។ ចំពោះដីកាសម្រេចនេះ ដើមចោទអាចប្តឹងជំទាស់បាន។

[27]មាត្រា ៧៥ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

## កថាភាគទី៣. ការបញ្ជូនពាក្យបណ្តឹង

ក្រោយពិនិត្យពាក្យបណ្តឹង ក្នុងករណីតុលាការយល់ឃើញថា ពាក្យបណ្តឹងមានភាពត្រឹមត្រូវតាមទម្រង់រួចហើយ ក្រឡាបញ្ជីត្រូវធ្វើការបញ្ជូនពាក្យបណ្តឹងជាចាំបាច់ទៅចុងចម្លើយ[28]។ ក្នុងករណីមិនអាចធ្វើការបញ្ជូនបានដោយសារតែអាសយដ្ឋានរបស់ចុងចម្លើយ ដែលមានសរសេរនៅក្នុងពាក្យបណ្តឹងមិនត្រឹមត្រូវជាដើម តុលាការត្រូវធ្វើការបង្គាប់ឱ្យកែតម្រូវ ដោយកំណត់អំឡុងពេលសមរម្យ[29]។ ឧទាហរណ៍៖ នៅផ្លូវ **យយ៥៤** ពុំមានផ្ទះលេខ **ស២៤** ទេ លេខ **ស២៤** មាននៅក្នុងផ្លូវ **យយ៥៥** ក្នុងករណីនេះ ដើមចោទត្រូវធ្វើការកែតម្រូវអាសយដ្ឋានរបស់ចុងចម្លើយទើបអាចធ្វើការបញ្ជូនបាន។ ក្នុងករណីអាសយដ្ឋានរបស់ចុងចម្លើយ ដែលបានសរសេរនៅក្នុងពាក្យបណ្តឹងមានភាពត្រឹមត្រូវ ប៉ុន្តែផ្ទះនោះជាផ្ទះដែលចុងចម្លើយជួលគេ ហើយចុងចម្លើយបានចាកចេញទៅហើយ ទោះបីជាដើមចោទខំស្វែងរកយ៉ាងណាក៏មិនឃើញ ដើមចោទអាចស្នើសុំការបញ្ជូនតាមការផ្សាយជាសាធារណៈបាន។

នៅពេលដែលចុងចម្លើយបានបញ្ជូនពាក្យបណ្តឹង ចុងចម្លើយនឹងក្លាយជាប្រធាននៃនីតិវិធីបណ្តឹង ហើយទំនាក់ទំនងគតិយុត្តរវាង តុលាការ ដើមចោទ ចុងចម្លើយនឹងកើតឡើង។ នីតិវិធីបណ្តឹងចាប់ផ្តើមដោយការដាក់ពាក្យបណ្តឹង ប៉ុន្តែពាក្យបណ្តឹងចាត់ទុកថា បានដាក់នៅពេលដែលពាក្យបណ្តឹងនោះ ត្រូវបានបញ្ជូនទៅចុងចម្លើយ ពីព្រោះទោះបីជាដើមចោទបានដាក់ពាក្យបណ្តឹងក៏ដោយ ក៏ទំនាក់ទំនងគតិយុត្តមានចំពោះតែតុលាការ និងដើមចោទតែប៉ុណ្ណោះមុនពេលការបញ្ជូនពាក្យបណ្តឹង។

នៅពេលធ្វើការបញ្ជូនពាក្យបណ្តឹង តុលាការនឹងបញ្ជូនដីកាសម្រេចកំណត់កាលបរិច្ឆេទនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង រួមទាំងដីកាសម្រេចកំណត់អំឡុងពេលដាក់ឯកសារចម្លើយ មានន័យថាចុងចម្លើយត្រូវដាក់ឯកសារចម្លើយមកតុលាការក្នុងអំឡុងពេលដែលតុលាការបានកំណត់ដែលជាទូទៅមួយសប្តាហ៍មុនចាប់ផ្តើមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។

[28]មាត្រា ៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[29]មាត្រា ៧៨ នៃក្រមនីតិវិធី នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

# ជំពូកទី២

# ការត្រៀមសម្រាប់ការ

# ទាញហេតុផល

# ជំពូកទី២

# ការត្រៀមសម្រាប់ការទាញហេតុផល

## ផ្នែកទី១. គោលបំណងនៃការត្រៀមសម្រាប់ការទាញហេតុផល

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មានគោលបំណងរៀបចំនូវការអះអាងរបស់ភាគី បំភ្លឺចំណុចវិវាទនូវរឿងក្តី និងរៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្តី ដើម្បីអាចធ្វើការវិនិច្ឆ័យរឿងក្តីនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឱ្យបានល្អិតល្អន់[30]។

### កថាភាគទី១. អត្ថន័យ និងភាពចាំបាច់

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជាដំណាក់កាលដើមមួយនៃនីតិវិធីរដ្ឋប្បវេណីដែលធ្វើឡើងដើម្បីផ្តល់ឱកាសដល់តុលាការក្នុងការរៀបចំនូវសេចក្តីអះអាងរបស់ភាគីបំភ្លឺនូវចំណុចវិវាទនៃរឿងក្តីដែលគូភាគីមិនយល់ព្រមស្របគ្នា និងរៀបចំនូវភស្តុតាងដែលទាក់ទង និងចំណុចវិវាទនៃរឿងក្តីនោះ ដើម្បីធ្វើការវិនិច្ឆ័យរឿងក្តីនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ឱ្យបានល្អិតល្អន់។ ការត្រៀមនេះធ្វើឡើង គឺដើម្បីរៀបចំនូវចំណុចវិវាទនៃរឿងក្តី និងភស្តុតាង និងដើម្បីកាត់បន្ថយនូវចំណុចវិវាទ ឬកុំឱ្យមានភាពស្មុគស្មាញលើចំណុចវិវាទ។

ជាគោលការណ៍ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មិនចាំបាច់បើកជាសាធារណៈទេ។ ប៉ុន្តែតុលាការអាចអនុញ្ញាតឱ្យអ្នកដែលតុលាការយល់ឃើញថា សមរម្យអាចចូលជាអ្នកអង្កេតការណ៍បាន ឧទាហរណ៍៖ មេធាវី សាច់ញាតិ ឬសហពន្ធ័ ជាដើម។ នីតិវិធីនេះ ត្រូវធ្វើនៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចចូលរួមបាន ព្រោះគោលគំនិតនៃមាត្រា ៣ ចំណុចទី២ នៃ ក្រមនីតិវិធីរដ្ឋប្បវេណីបានចែងថា ក្នុងករណីណាក៏ដោយតុលាការត្រូវគោរពគោលការណ៍ចំពោះមុខដែលគោលកាណ៍នេះ តុលាការត្រូវតែគោរព។

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល អាចផ្តល់ឱ្យតុលាការទទួលបាននូវព័ត៌មានទាក់ទងនឹងចំណុចវិវាទដូចតទៅ :

- ការអះអាង និងការទាមទាររបស់ភាគី
- ភាគីទទួលស្គាល់ចំណុចណាខ្លះ និងចំណុចណាខ្លះដែលមិនទទួលស្គាល់
- ចំណុចដែលមានវិវាទត្រូវបញ្ជាក់ដោយភស្តុតាងណាខ្លះ។

[30]មាត្រា ១០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ដើម្បីរៀបចំ និងគ្រប់គ្រងការអះអាងរបស់ភាគី និងបំភ្លឺនូវចំណុចវិវាទនៃរឿងក្ដីដែលគូភាគីមិនយល់ស្របគ្នានោះជាកត្តាចាំបាច់ និងសំខាន់ដែលត្រូវស្ដាប់នូវការអះអាងរបស់ភាគីទាំងពីរដោយផ្ទាល់។ អ្វីដែលភាគីទាំងពីរបាននិយាយក្នុងដំណាក់នេះគឺជាការអះអាង វាមិនមែនជាភស្ដុតាងនៃរឿងក្ដីទេ។

**កថាភាគទី២. សិទ្ធិរបស់ចៅក្រម**

នៅក្នុងការដឹកនាំនីតិវិធីឲ្យដើរទៅមុខ ព្រមទាំងចាត់ចែងនិងរៀបចំការជំនុំជម្រះឲ្យមានប្រសិទ្ធិភាព គឺជាសិទ្ធិអំណាច និងការទទួលខុសត្រូវរបស់តុលាការដែលត្រូវបានតំណាងដោយចៅក្រម ឬប្រធានក្រុមប្រឹក្សា។ ដើម្បីធ្វើឲ្យការជំនុំជម្រះលើបណ្ដឹងប្រព្រឹត្តទៅដោយឆាប់រហ័ស និងមានប្រសិទ្ធិភាពដែលសិទ្ធិអំណាចនៃការគ្រប់គ្រងលើនីតិវិធីត្រូវបានផ្ដល់ឲ្យទៅតុលាការ គេហៅបានថា សិទ្ធិអំណាចក្នុងការដឹកនាំនីតិវិធីបណ្ដឹង[31]។ នីតិវិធីនៃការជំនុំជម្រះត្រូវបានចាត់ចែង និងដឹកនាំដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ ដែលនៅក្នុងនោះប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចអនុញ្ញាតឱ្យជនណាម្នាក់និយាយបាន និងអាចហាមជនដែលមិនស្ដាប់បញ្ជារបស់ខ្លួនមិនឱ្យនិយាយបាន[32]។ ក្នុងករណីពាក្យបណ្ដឹងមានចំណុចខ្វះខាត តុលាការនឹងកំណត់អំឡុងពេលមួយសមរម្យសម្រាប់ភាគីធ្វើការកែតម្រូវនូវចំណុចដែលមិនបានបំពេញនូវលក្ខខណ្ឌដូចមានចែងនៅក្នុងមាត្រា៧៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី តែករណីដែលភាគីមិនបានកែតម្រូវនូវចំណុចខ្វះខាតនោះទេ នោះតុលាការនឹងធ្វើការលើកពាក្យបណ្ដឹងចោលដោយដីកាសម្រេច[33]។ ចំពោះកាលបរិច្ឆេទនៃការត្រៀមសម្រាប់ការទាញហេតុផល ចៅក្រមដែលទទួលបញ្ជា ឬចៅក្រមដែលទទួលការប្រគល់សិទ្ធិត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីតាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធិ[34]។ ប៉ុន្តែក្នុងករណីដែលភាគីមានមូលហេតុច្បាស់លាស់ ឬការព្រមព្រៀងគ្នាពីសំណាក់គូភាគី។ ភាគីអាចដាក់ពាក្យសុំឱ្យប្ដូរកាលបរិច្ឆេទ ដោយត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីមូលហេតុដែលនាំឱ្យត្រូវប្ដូរកាលបរិច្ឆេទ[35]។ តុលាការអាចសាកសួរភាគី ឬឱ្យភាគីអះអាង ឬបញ្ជាក់ភស្ដុតាង ចំពោះចំណុចនៃអង្គហេតុ និងអង្គច្បាប់ដែលទាក់ទងនឹងបណ្ដឹងដើម្បីឱ្យមានភាពច្បាស់លាស់។ នៅពេលដែលតុលាការយល់ឃើញថានៅមានចំណុចដែលត្រូវបំភ្លឺជាចាំបាច់ តុលាការអាចបង្គាប់ឱ្យភាគីត្រៀមខ្លួននឹងរៀបចំការឆ្លើយបំភ្លឺនៅកាលបរិច្ឆេទបន្ទាប់[36]។

---

[31]មាត្រា ៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[32]មាត្រា ៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[33]មាត្រា ៧៨ នៃក្រមនីតិវិធិរដ្ឋប្បវេណី

[34]មាត្រា ២៤០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[35]មាត្រា ២៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[36]មាត្រា ៩០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ម្យ៉ាងវិញទៀត តុលាការអាចបង្គាប់ឱ្យភាគីដាក់ឯកសារត្រៀម ដោយនៅក្នុងឯកសារត្រៀមត្រូវសរសេរអំពីមធ្យោបាយតទល់ ឬមធ្យោបាយការពារខ្លួន និងសេចក្ដីថ្លែងការណ៍ ចំពោះមធ្យោបាយតទល់ ឬការពារខ្លួនរបស់ភាគីម្ខាង[37]។ តែតុលាការក៏អាចចេញដីកាសម្រេចលើកចោលមធ្យោបាយតទល់ ឬការពារខ្លួនតាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធិរបស់ខ្លួន នៅពេលដែលភាគីដាក់មធ្យោបាយតទល់ ឬការពារខ្លួនយឺតយ៉ាវមិនត្រូវពេលសមរម្យដោយចេតនា ឬដោយកំហុសដ៏ធ្ងន់ធ្ងររបស់ភាគី ដែលនាំឱ្យមានការយឺតយ៉ាវក្នុងការបញ្ចប់នីតិវិធីនៃបណ្ដឹង[38]។ លើសពីនេះ តុលាការក៏អាចបញ្ចូលរឿងក្ដីច្រើនដែលកំពុងចាត់ការ មកជារឿងក្ដីតែមួយក៏បាន ប្រសិនបើរឿងក្ដីនោះមានភាគីខុសគ្នាក៏ដោយ[39]។ ក្នុងករណីដែលជនដែលទាក់ទងនឹងនីតិវិធីរដ្ឋប្បវេណី មិនអាចយល់ភាសាខ្មែរ ថ្លង់ ឬគ តុលាការត្រូវឱ្យមានអ្នកបកប្រែដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការចូលរួមជាមួយនឹងជននោះ។ ប៉ុន្តែតុលាការអាចសួរជនដែលថ្លង់ ជាអក្សរ ឬឱ្យជនដែលគ ធ្វើសេចក្ដីថ្លែងការណ៍ជាអក្សរបាន[40]។ នៅពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយបានបញ្ចប់ការរៀបចំចំណុចវិវាទនៃរឿងក្ដី និងភស្តុតាងហើយ នោះតុលាការត្រូវធ្វើការបញ្ជាក់ជាមួយភាគីនូវអង្គហេតុដែលនឹងត្រូវបំភ្លឺនៅពេលពិនិត្យភស្តុតាងនៅពេលក្រោយ[41]។

### កថាភាគទី៣. សិទ្ធិរបស់ភាគី

កម្មវត្ថុនៃការជំនុំជម្រះ និងការចេញសាលក្រមនៅក្នុងបណ្ដឹង គឺជាការទាមទារតាមផ្លូវបណ្ដឹង ដែលបានធ្វើឡើងដោយដើមចោទ តាមរយៈការដាក់ពាក្យបណ្ដឹង។ តុលាការអាចចាប់ផ្ដើមធ្វើការជំនុំជម្រះលើបណ្ដឹងបាន តែនៅពេលណាដែលបានទទួលពាក្យបណ្ដឹងរបស់ដើមចោទប៉ុណ្ណោះ។ តុលាការ មិនអាចចាប់ផ្ដើមនីតិវិធីនៃបណ្ដឹងបានឡើយ ប្រសិនបើពុំមានពាក្យបណ្ដឹងពីភាគីទេនោះ។ ជាគោលការណ៍ នៅពេលដែលមានការដាក់ពាក្យបណ្ដឹង ហើយការជំនុំជម្រះត្រូវបានចាប់ផ្ដើម ចំណុចដែលមានសរសេរនៅក្នុងពាក្យបណ្ដឹង ឬការទាមទារនៅក្នុងបណ្ដឹងអាចត្រូវបានជំនុំជម្រះ និងចេញសាលក្រម តែត្រឹមទំហំដែលបានសុំប៉ុណ្ណោះដែលតុលាការមិនអាចធ្វើការសម្រេចសេចក្ដីនៅចំណុចដែលភាគីមិនបានសុំនោះទេ[42]។ ឧទាហរណ៍៖ ក្នុងករណីដែលដើមចោទគ្រាន់តែប្ដឹងទាមទារសំណងប្រាក់ចំនួន ៨ លានរៀលក្នុងចំណោម ប្រាក់កម្ចីចំនួន ១០ លានរៀល តុលាការមិន

[37]មាត្រា ១០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[38]មាត្រា ៩៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[39]មាត្រា ៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[40]មាត្រា ១០០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[41]មាត្រា ១០៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[42]មាត្រា ១៨២ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

អាចចេញសាលក្រមបង្គាប់ឱ្យមានការសងប្រាក់លើសពី ៨ លានរៀលឡើយ បើទោះបីជាតុលាការយល់ឃើញថា ដើមចោទមានសិទ្ធិទាមទារសំណងប្រាក់រហូតដល់ចំនួន ១០ លានរៀលក៏ដោយ។ នេះមានន័យថា ភាគីមានសិទ្ធិសម្រេចអំពីកម្មវត្ថុ និងទំហំនៃការជំនុំជម្រះ និងការចេញសាលក្រមនៅក្នុងបណ្តឹង។ ម្យ៉ាងវិញទៀត ទោះបីជានីតិវិធីបណ្តឹងត្រូវបានចាប់ផ្តើម។ លើសពីនេះទៅទៀត ភាគីអាចបញ្ចប់បណ្តឹង ដោយមិនចាំបាច់រង់ចាំសាលក្រមចុងក្រោយបាន តាមរយៈការលះបង់ ឬការទទួលស្គាល់នូវការទាមទារ ឬតាមរយៈការផ្សះផ្សាលើបណ្តឹង[43]។ ភាគីអាចធ្វើការសម្រេច (ការចាត់ចែង) ដោយផ្អែកលើឆន្ទៈរបស់ខ្លួន អំពីការចាប់ផ្តើមបណ្តឹងអំពីកម្មវត្ថុ និងទំហំនៃការជំនុំជម្រះ និងចេញសាលក្រម និងអំពីការបញ្ចប់បណ្តឹង គេហៅថា គោលការណ៍នៃសិទ្ធិចាត់ចែងរបស់ភាគី គឺជា សិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលជាកម្មវត្ថុនៃបណ្តឹងរដ្ឋប្បវេណី អាចត្រូវបានចាត់ចែងដោយសេរី ដោយផ្អែកតាមឆន្ទៈរបស់ភាគី។ ហេតុដូច្នេះ តុលាការអាចធ្វើការវិនិច្ឆ័យទៅតាមទំហំ និងពេលវេលាដែលភាគីបានទាមទារ។ ប្រសិនបើតុលាការ ដែលជាស្ថាប័នរបស់រដ្ឋចាប់ផ្តើមបណ្តឹង ហើយចេញសាលក្រមលើសពីទំហំដែលភាគីទាមទារ ត្រូវចាត់ទុកថាជាការរំលោភបំពានទៅលើគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន។

## ផ្នែកទី២. សកម្មភាពក្នុងការត្រៀមសម្រាប់ការទាញហេតុផល

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលភាគីសងខាងអាចចូលរួមបាន។ នីតិវិធីនេះមិនចាំបាច់បើកជាសាធារណៈទេ[44]។ នៅពេលចាប់ផ្តើមធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលតុលាការអាចពិនិត្យឃើញថា អង្គហេតុដែលបានសរសេរក្នុងពាក្យបណ្តឹង ក៏ដូចជានៅក្នុងឯកសារត្រៀមមានភាពមិនច្បាស់លាស់ តុលាការអាចសាកសួរភាគីឱ្យភាគីអះអាង ឬបញ្ជាក់នូវភស្តុតាងចំពោះចំណុចនោះនៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន។ ភាពច្បាស់លាស់នៃអង្គហេតុ និងអង្គច្បាប់ដែលទាក់ទងនឹងបណ្តឹងគឺជាចំណុចសំខាន់ណាស់ ពីព្រោះថាការអះអាងអំពីអង្គហេតុនោះនឹងក្លាយជាមូលដ្ឋានសម្រាប់តុលាការចេញសាលក្រម ម៉្យាងទៀតវាជាកាតព្វកិច្ចរបស់គូភាគីដែលត្រូវធ្វើការអះអាង។ ដើម្បីឱ្យភាគីអាចបំពេញនូវកាតព្វកិច្ចរបស់ខ្លួនបាននោះ តុលាការអាចសួរអំពីចំណុចមិនច្បាស់លាស់នៃអង្គហេតុដែលភាគីបានអះអាង នេះជាសិទ្ធិរបស់តុលាការ។

---

[43]មាត្រា ២២០ និងមាត្រា ២២១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[44]មាត្រា ១០៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

នៅពេលបានទទួលពាក្យបណ្ដឹង និងក្រោយពីមានការពិនិត្យលើទម្រង់នៃពាក្យបណ្ដឹង ឬចំណុចផ្សេងៗទៀតឃើញថាមានលក្ខណៈពេញលេញរួចហើយ និងតុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងធ្វើការកោះហៅគូភាគីដែលអំឡុងពេលនោះត្រូវកំណត់៣០ថ្ងៃ[45] បន្ទាប់ពីថ្ងៃដាក់ពាក្យបណ្ដឹងលើកលែងតែមានករណីពិសេស ដូចជាចៅក្រមទទួលបន្ទុកមានធុរៈ ហើយមិនអាចរកចៅក្រមមកជំនួសបានសម្រាប់អំឡុងពេលនោះ ឬក៏មានហេតុការណ៍ដូចជាគ្រោះធម្មជាតិដែលតុលាការមិនអាចបំពេញភារកិច្ចបានជាដើម។ ការប្ដូរកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក៏ដូចជាការប្ដូរកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ មិនត្រូវបានអនុញ្ញាតទេ លើកលែងតែមានមូលហេតុពិសេសមិនអាចជៀសវាងបានដូចជា ភាគីមានជម្ងឺមិនអាចចូលរួមបានជាដើម។ ប៉ុន្តែប្រសិនបើមានការព្រមព្រៀងពីសំណាក់គូភាគី ការប្ដូរកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូងអាចអនុញ្ញាតប្ដូរបាន។ នៅពេលផ្លាស់ប្ដូរកាលបរិច្ឆេទតុលាការត្រូវបញ្ជាក់ប្រាប់ទៅគូភាគី ហើយត្រូវកំណត់នូវកាលបរិច្ឆេទថ្មីមួយទៀតដែលគូភាគីអាចចូលរួមបាន។ នីតិវីធីត្រៀមសម្រាប់ការទាញហេតុផលនេះ មិនសំដៅទៅលើន័យថា តុលាការត្រូវធ្វើការស៊ើបសួរដោយសកម្មទៅលើបណ្ដឹងនោះទេ គឺមានន័យថាត្រឹមតែឱ្យគូភាគីបំភ្លឺចំណុចវិវាទរបស់ខ្លួនដែលបានលើកឡើងមិនស្របគ្នាប៉ុណ្ណោះ និងធ្វើកិច្ចការត្រៀមមួយចំនួនដូចជា ការដាក់មធ្យោបាយតទល់ ឬការពារខ្លួន។

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ពុំអនុញ្ញាតឱ្យមានការសាកសួរទៅលើសាក្សី និងទៅលើភាគីទេ ប៉ុន្តែតុលាការអាចចេញដីកាសម្រេចដែលទាក់ទងនឹងការស្នើសុំឱ្យពិនិត្យភស្តុតាង និងអាចពិនិត្យភស្តុតាងជាឯកសារបាន ចំណុចនេះមិនមែនមានន័យថា តុលាការអាចធ្វើការសាកសួរទៅលើភស្តុតាងជាបុគ្គលផ្ទាល់ខ្លួននោះបានទេ តែមានន័យដូចជា ការអានឯកសារភស្តុតាងនោះដោយចៅក្រមជាដើម ព្រោះថាដើម្បីរៀបចំចំណុចវិវាទនៃរឿងក្ដីបានត្រឹមត្រូវ ភាគច្រើនតុលាការត្រូវរកភស្តុតាងជាឯកសារ ដូចនេះហើយបានជាច្បាប់អនុញ្ញាតឱ្យតុលាការពិនិត្យភស្តុតាងជាឯកសារនៅក្នុងកម្រិតចាំបាច់ដើម្បីរៀបចំនៅចំណុចវិវាទនៃរឿងក្ដីប៉ុណ្ណោះ។

[45]មាត្រា ៨០ កថាខណ្ឌ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

### កថាភាគទី១. ការសាកល្បងផ្សះផ្សា

ការផ្សះផ្សា គឺជាកិច្ចមួយដែលត្រូវលើកទឹកចិត្តជានិច្ច នៅក្នុងប្រព័ន្ធដោះស្រាយបណ្ដឹងរដ្ឋប្បវេណី ពីព្រោះវាអាចជួយឲ្យភាគីចំណេញបានយ៉ាងច្រើនទាំងពេលវេលា ហិរញ្ញវត្ថុ និងទំនាក់ទំនងនៅថ្ងៃក្រោយ។

នាកាលបរិច្ឆេទដំបូងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការគប្បីសាកល្បងធ្វើការផ្សះផ្សាជាមុនសិននៅពេលដែលភាគីទាំងពីរមានវត្តមាននៅកាលបរិច្ឆេទនោះ[46]។ ការផ្សះផ្សានេះ មិនត្រូវតែធ្វើនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលប៉ុណ្ណោះទេ ប៉ុន្តែតុលាការ អាចធ្វើនៅគ្រប់ដំណាក់កាលទាំងអស់នៃនីតិវិធី។ តុលាការត្រូវតែធ្វើការសាកល្បងផ្សះផ្សាគូភាគីក៏ពិតមែន ប៉ុន្តែតុលាការអាចសម្រេចចិត្តថា ត្រូវផ្សះផ្សា ឬមិនធ្វើការផ្សះផ្សា អាស្រ័យទៅលើស្ថានភាព និងគោលបំណងរបស់គូភាគីនៃរឿងក្ដីនីមួយៗ។ បើតុលាការបានដឹងច្បាស់លាស់តាមរយៈអាកប្បកិរិយារបស់ភាគីថាពុំមានឆន្ទៈសះជាទេ ឬឃើញថាការផ្សះផ្សាមិនមានភាពសមរម្យទេនោះ មិនចាំបាច់ធ្វើការផ្សះផ្សា នាពេលដំបូងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះទេ។ ហេតុដែលអនុញ្ញាតឱ្យធ្វើបែបនេះពីព្រោះថា បើតុលាការសម្រេចធ្វើការសាកល្បងផ្សះផ្សា ហើយមិនបានសម្រេចនៅខណៈនោះក៏ដោយ ក៏តុលាការអាចធ្វើការសាកល្បងផ្សះផ្សាពេលក្រោយទៀតបានដែរ ពីព្រោះមាត្រា ៩៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានចែងថា តុលាការអាចសាកល្បងធ្វើការផ្សះផ្សាបាន ទោះបីបណ្ដឹងស្ថិតក្នុងដំណាក់កាលណាក៏ដោយ។ ដើម្បីឱ្យការផ្សះផ្សាទទួលបានលទ្ធផលល្អ តុលាការអាចប្រើប្រាស់នូវវិធីសាស្ត្រសមរម្យតាមឆន្ទានុសិទ្ធិមានដូចជា តុលាការអាចស្នើសុំឱ្យភាគីម្ខាងចេញក្រៅបន្ទប់តុលាការដោយមាន ការព្រមព្រៀងពីភាគីម្ខាងទៀតជាមុនសិនដើម្បីជៀសវាងនូវភាពមន្ទិលសង្ស័យថាតុលាការ មានការលម្អៀង ហើយព្យាយាមធ្វើការបញ្ចុះបញ្ចូលភាគីម្ខាងទៀតដើម្បីឱ្យមានការព្រមព្រៀងគ្នា ឬតុលាការប្រើវិធីសាស្ត្រផ្សេងៗទៀតដែលតុលាការយល់ឃើញថាអាចមានប្រសិទ្ធិភាពសម្រាប់ធ្វើការផ្សះផ្សា។ បើការផ្សះផ្សាពុំបានសម្រេចនៅក្នុងនីតិវិធីនេះទេ នោះតុលាការត្រូវបន្តនីតិវិធីតទៅទៀត។

បើប្រៀបធៀបនឹងដំណោះស្រាយជម្លោះតាមសាលក្រម ការផ្សះផ្សា គឺជាដំណោះស្រាយនៃជម្លោះដែលមានគុណសម្បត្តិដូចតទៅ៖

(ក) អាចទទួលនូវខ្លឹមសារនៃការសះជាសមរម្យដែលស្របទៅនឹងលក្ខណៈ និងស្ថានភាពនៃរឿងក្ដី។

(ខ) ភាគីនឹងអនុវត្តដោយស្ម័គ្រចិត្តនូវកាតព្វកិច្ចដែលបានសន្យាក្នុងការសះជា។

(គ) អាចរក្សានូវភាពប្រក្រតីនូវទំនាក់ទំនងរវាងភាគីនាពេលអនាគតបាន។

[46]មាត្រា ១០៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ការសះជាគ្នា នាំមកនូវផ្សះផ្សា ការឯកភាព មិត្តភាព និងសុខដុមរមនាក្នុងសហគមន៍ និងសង្គមជាតិទាំងមូល។ លើសពីនេះ បើភាគីសះជាគ្នា នោះតុលាការក៏ចាំបាច់ត្រូវជំនុំជម្រះចេញសាលក្រមទៀតដែរ ហើយនីតិវិធីបណ្ដឹងត្រូវបញ្ចប់ដោយសកម្មភាពភាគី ក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុស្ដីពីការសះជាដែលកំណត់ហេតុនេះមានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរដែរ[47]។

**កថាភាគទី២. ករណីការផ្សះផ្សាមិនបានសម្រេច**

ក្នុងករណីការផ្សះផ្សាមិនបានសម្រេច ឬមិនអាចធ្វើបានដោយសារលក្ខណៈសារធាតុនៃសិទ្ធិជាអាទិ៍ តុលាការត្រូវចាប់ផ្ដើមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នៅពេលធ្វើនីតិវិធីត្រៀម តុលាការអាចបង្គាប់ឱ្យភាគីដាក់ឯកសារត្រៀម[48]។ នៅក្នុងឯកសារត្រៀម ត្រូវមានសរសេរអំពីមធ្យោបាយតទល់ ឬការពារខ្លួន និងសេចក្ដីថ្លែងការណ៍ចំពោះមធ្យោបាយតទល់ ឬការពារខ្លួនរបស់ភាគីម្ខាងទៀត[49]។ ចំពោះពាក្យបណ្ដឹងដែលមានសរសេរអំពីមធ្យោបាយតទល់ ឬការពារខ្លួនត្រូវចាត់ទុកថាជាឯកសារត្រៀម [50]។

**កថាភាគទី៣. ការថ្លែងពាក្យបណ្ដឹង**

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការសម្រាប់ការទាញហេតុផល តុលាការនឹងឱ្យគូភាគីធ្វើសេចក្ដីថ្លែងការណ៍ដែលជាមធ្យោបាយតទល់ (ដើមចោទ) ឬការពារខ្លួន ដូចជាការដាក់ពាក្យសុំ ឬសកម្មភាពផ្សេងៗទៀតរបស់គូភាគី។ ការដាក់ពាក្យសុំ ជាសកម្មភាពដែលភាគីស្នើសុំឱ្យតុលាការធ្វើសកម្មភាពជាកំណត់មួយ តាមនីតិវិធីច្បាប់ដូចជាចេញសាលក្រម ឬចេញដីកាសម្រេច ឬពិនិត្យភស្ដុតាង ឬពាក្យសុំផ្ទេរសមត្ថកិច្ច ជាអាទិ៍[51]។

**ក. ការដាក់មធ្យោបាយតទល់ ឬការពារខ្លួន**

មធ្យោបាយតទល់ គឺជាមធ្យោបាយដែលដាក់ដោយដើមចោទ (សេចក្ដីថ្លែងការណ៍ សកម្មភាព ឬនិងពាក្យសុំរបស់ដើមចោទ) ចំណែកឯមធ្យោបាយការពារខ្លួន គឺជាមធ្យោបាយដែលដាក់ដោយចុងចម្លើយ (សេចក្ដីថ្លែងការណ៍សកម្មភាព ឬនិងពាក្យសុំរបស់ចុងចម្លើយ) មធ្យោបាយតទល់ ឬការពារខ្លួនត្រូវដាក់ឱ្យតុលាការនៅពេលណាមួយដែលសមរម្យទៅតាមដំណើរការនៃបណ្ដឹង[52] ប៉ុន្តែក្នុងករណីមានមូលហេតុពិសេសភាគីអាចដាក់

[47]មាត្រា ២២២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[48]មាត្រា ១០១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[49] មាត្រា ១០១ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[50]មាត្រា ៧៥ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[51] សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណីភាគ១ និងភាគ២ ទំព័រទី៧៨

[52]មាត្រា ៩៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

មធ្យោបាយតទល់ ឬការពារខ្លួននៅពេលណាក៏បាន មុនពេលបញ្ចប់ការវិនិច្ឆ័យលើបណ្តឹង (មុនបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់)។

ចំពោះមធ្យោបាយតទល់ ឬការពារខ្លួនដែលត្រូវបានដាក់ទៅតុលាការយឺតយ៉ាវ មិនត្រូវនឹងពេលសមរម្យដោយចេតនា ឬកំហុសធ្ងន់ធ្ងររបស់ភាគី តុលាការអាចលើកចោលមធ្យោបាយតទល់ ឬការពារខ្លួននោះដោយដីកាសម្រេចតាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធិ[53]។ ម្យ៉ាងវិញទៀត ចំពោះមធ្យោបាយតទល់ ឬការពារខ្លួនដែលមានអត្ថន័យមិនច្បាស់លាស់ ហើយតុលាការបានទាមទារឱ្យបំភ្លឺ តែភាគីមិនផ្តល់ការបំភ្លឺចាំបាច់ ឬមិនបង្ហាញខ្លួនតាមកាលបរិច្ឆេទដែលបានកំណត់ឱ្យបំភ្លឺតុលាការក៏អាចលើកចោលនូវមធ្យោបាយតទល់ ឬការពារខ្លួនដែរ [54]។

**ខ. សកម្មភាពផ្សេងៗ**

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល សកម្មភាពមួយចំនួនត្រូវបានកម្រិត ដូចជា ការពិនិត្យភស្តុតាង ជាអាទិ៍ ប៉ុន្តែដើម្បីរៀបចំការអះអាងរបស់ភាគី កំណត់ចំណុចវិវាទ និងរៀបចំភស្តុតាងដែលត្រូវពិនិត្យនៅពេលទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាចធ្វើសកម្មភាពចាំបាច់មួយចំនួនបាន ដូចខាងក្រោម៖

(ក) ចេញដីកាសម្រេចទាក់ទងនឹងការស្នើសុំឱ្យពិនិត្យភស្តុតាង ដូចជាដីកាសម្រេចទទួលយកភស្តុតាងដែលបានស្នើសុំឱ្យពិនិត្យ (យោងតាមមាត្រា ១២៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដីកាសម្រេចបង្គាប់ឱ្យធ្វើកោសលវិច័យ (យោងតាមមាត្រា ១៤៣ កថាខណ្ឌទី ១នៃក្រមនីតិវិធីរដ្ឋប្បវេណី) និងដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ ជាអាទិ៍ (យោងតាមមាត្រា ១៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

(ខ) ចេញដីកាសម្រេចផ្សេងទៀត ដែលក្រមនីតិវិធីរដ្ឋប្បវេណីអនុញ្ញាតឱ្យធ្វើក្រៅពីកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ដូចជាដីកាសម្រេចអនុញ្ញាត ឬមិនអនុញ្ញាតឱ្យបន្ថែម ឬផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង (យោងតាមមាត្រា ៨៤ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី) និងដីកាសម្រេចអនុញ្ញាត ឬមិនអនុញ្ញាតឱ្យចូលអន្តរាគមន៍ក្នុងបណ្តឹង ជាអាទិ៍(យោងតាមមាត្រា៨៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

(គ) ពិនិត្យភស្តុតាងជាឯកសារ ត្រឹមកម្រិតដែលចាំបាច់ដើម្បីរៀបចំចំណុចវិវាទ[55]។ ឧទាហរណ៍៖ ចុងចម្លើយតវ៉ាចំពោះអង្គហេតុនៃការបង្កើតកិច្ចសន្យា ហើយអះអាងថា ទោះបីជាការបង្កើតកិច្ចសន្យាលក់ទិញត្រូវ

[53]មាត្រា ៩៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[54]មាត្រា ៩៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[55]មាត្រា ១០៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

បានទទួលស្គាល់ក៏ដោយ ខ្លួនលុបចោលកិច្ចសន្យានោះ ដោយសារការបង្ហាញឆន្ទៈបង្កើតកិច្ចសន្យាធ្វើឡើងដោយការឆបោក។

(ឃ) ការបញ្ជាក់អង្គហេតុ៖ នៅពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយបានបញ្ចប់ការរៀបចំចំណុចវិវាទ ការរៀបចំការអះអាង និងការរៀបចំភស្តុតាងរួចហើយ តុលាការត្រូវបញ្ជាក់ជាមួយភាគីទាំងសងខាងអំពីអង្គហេតុដែលត្រូវធ្វើការបញ្ជាក់តាមរយៈការពិនិត្យភស្តុតាង នៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ដែលនឹងធ្វើបន្ទាប់ពីនោះ[56]។ តុលាការ និងភាគីទាំងសងខាង ត្រូវធ្វើការបញ្ជាក់គ្នាទៅវិញទៅមក និងត្រូវមានការទទួលស្គាល់រួមគ្នា អំពីអង្គហេតុដែលជាចំណុចវិវាទដែលត្រូវក្លាយជាកម្មវត្ថុនៃការពិនិត្យភស្តុតាង ដើម្បីអាចធ្វើការពិនិត្យភស្តុតាងដោយសមូហវិធីនៅកាលបរិច្ឆេទនៃការទាញហេតុផលផ្ទាល់មាត់[57]។

(ង) ការកំណត់កាលបរិច្ឆេទលើកទី១ នៃការទាញហេតុផលដោយផ្ទាល់មាត់។

នៅពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយត្រូវការកោះហៅភាគីទាំងសងខាងឱ្យចូលរួមនៅកាលបរិច្ឆេទដែលកំណត់នោះ[58]។

សកម្មភាពដែលភាគីធ្វើការរៀបរាប់ ឬបញ្ចេញមតិយោបល់ ឬការយល់ឃើញរបស់ខ្លួនទៅកាន់តុលាការនៅក្នុងកាលបរិច្ឆេទនៃកិច្ចនីតិវិធី ហៅថា "សេចក្តីថ្លែងការណ៍"។ ប្រសិនបើសកម្មភាពដែលភាគីធ្វើការរៀបរាប់ បញ្ចេញមតិយោបល់ ឬការយល់ឃើញរបស់ខ្លួនពាក់ព័ន្ធនឹងអង្គហេតុទៅកាន់តុលាការ ហៅថា«សេចក្តីថ្លែងការណ៍អំពីអង្គហេតុ»។ ប្រសិនបើសកម្មភាពដែលភាគីធ្វើការរៀបរាប់ បញ្ចេញមតិយោបល់ ឬការយល់ឃើញរបស់ខ្លួនពាក់ព័ន្ធនឹងផ្លូវច្បាប់ទៅកាន់តុលាការ ហៅថា "សេចក្តីថ្លែងការណ៍អំពីអង្គច្បាប់»។

នៅក្នុងចំណោមសេចក្តីថ្លែងការណ៍ទាំងនេះ សេចក្តីថ្លែងការណ៍ទាំងឡាយណាដែលមិនឆ្លើយតបនឹងសេចក្តីថ្លែងការណ៍របស់ភាគីម្ខាងទៀត ហើយបានរៀបរាប់អំពីអង្គហេតុឯករាជ្យ ឬមតិយោបល់តាមផ្លូវច្បាប់ ហៅថា «ការអះអាង»។

ជាគោលការណ៍ នីតិវិធីបណ្តឹងត្រូវឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីវិនិច្ឆ័យអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិសារធាតុរបស់គូភាគីដែលបានទាមទារតាមរយៈការអះអាងអង្គហេតុ ហេតុនេះអង្គ

[56]មាត្រា ១០៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[57]មាត្រា ១២៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[58]មាត្រា ១១៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ហេតុដែលមិនបានអះអាងដោយភាគី តុលាការមិនអាចយកមកធ្វើជាមូលដ្ឋាននៃសាលក្រមបាននោះទេ[59] ហៅថា «គោលការណ៍នៃការទាញហេតុផល»។

នៅក្នុងការអះអាងរបស់ភាគី ភាគីនឹងធ្វើការអះអាងនូវអង្គហេតុទាំងអស់ ដោយពុំគិតអំពីអង្គហេតុមាន ឬគ្មានប្រយោជន៍តាមផ្លូវច្បាប់ដែលពាក់ព័ន្ធនឹងការទាមទារឡើយ ដូចនេះ តុលាការត្រូវរៀបចំការអះអាងរបស់ភាគី ដោយរៀបចំនូវចំណុចដែលភាគីមានទំនាស់ ឬវិវាទនឹងគ្នា និងឱ្យភាគីធ្វើការបំភ្លឺនូវចំណុចវិវាទនោះ ដោយដកការអះអាងអំពីអង្គហេតុដែលមិនមានប្រយោជន៍ចំពោះការសម្រេចអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិដែលជាកម្មវត្ថុនៃបណ្តឹង និងប្រមូលយកនូវអង្គហេតុទាំងឡាយណាដែលភាគីធ្វើការអះអាងដូចគ្នា ដោយចាត់ទុកថាជា «អង្គហេតុដែលគ្មានវិវាទ» ដាក់ដោយឡែកដើម្បីផ្ទៀងផ្ទាត់ និងរៀបចំការអះអាងរបស់គូភាគី ដោយកំណត់អង្គហេតុណាខ្លះជាអង្គហេតុមានវិវាទ (កំណត់ចំណុចវិវាទ) និងអង្គហេតុណាខ្លះជាអង្គហេតុគ្មានវិវាទ។ នៅពេលកំណត់បែបនេះបាន តុលាការនឹងមានភាពច្បាស់លាស់អំពីបញ្ហារបស់គូភាគី ឬបង្រួមបញ្ហាពិតប្រាកដរបស់គូភាគី ហើយអាចធ្វើការវិនិច្ឆ័យឱ្យចំបញ្ហានោះទើបស្របនឹងទ្រឹស្តី «តុលាការត្រូវរ៉ាប់រងបណ្តឹងឱ្យបានឆាប់រហ័ស និងត្រូវចេញសាលក្រមដែលអាចបញ្ចប់វិវាទជាក់ស្តែង»។

អង្គហេតុដែលគ្មានវិវាទ គឺជាអង្គហេតុដែលភាគីបានសារភាពនៅចំពោះមុខតុលាការ និងអង្គហេតុដែលតុលាការយល់ឃើញថាមានភាពជាក់ស្តែង ដោយមិនចាំបាច់ទទួលស្គាល់ដោយផ្អែកលើភស្តុតាងទេ[60]។

## កថាភាគទី៤. ការកំណត់ចំណុចវិវាទ

ចំណុចវិវាទ ជាចំណុចដែលភាគី «មិនស្របគ្នា» ចំពោះ អង្គហេតុចម្បងណាមួយ ដែលត្រូវបានអះអាងដោយភាគី។ តុលាការមិនអាចសម្រេចសេចក្តីអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលភាគីបានអះអាងនោះទេ ប្រសិនបើគ្មានការបំភ្លឺអំពីទំនាក់ទំនងអង្គហេតុនៃរឿងក្តី ទោះបីជាដើមចោទបានដាក់ពាក្យបណ្តឹងចំពោះចុងចម្លើយ ដោយអះអាងអំពីសិទ្ធិ ឬកាតព្វកិច្ចដែលចុងចម្លើយត្រូវបំពេញក៏ដោយ ក៏មិនអាចសម្រេចបានថាសិទ្ធិទាមទារនោះ មានអត្ថិភាព ឬគ្មាននោះដែរ ពីព្រោះការទាមទារជាសិទ្ធិអរូបី ហើយសិទ្ធិនេះអាចត្រូវបានទទួលស្គាល់តាមរយៈការអះអាងអង្គហេតុចម្បង ហើយភាពខ្វែងគ្នានៃអង្គហេតុចម្បងរបស់គូភាគី គឺជា «ចំណុចវិវាទ»។

[59]មាត្រា ៩៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[60]មាត្រា ១២៣ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

អង្គហេតុចម្បង ជាអង្គហេតុលម្អិតដែលត្រូវនឹងលក្ខខណ្ឌច្បាប់ ហើយនាំឱ្យកកើតអានុភាពគតិយុត្ត (អង្គហេតុកកើតសិទ្ធិ អង្គហេតុរារាំងសិទ្ធិ អង្គហេតុរលត់សិទ្ធិ និងអង្គហេតុទប់ស្កាត់សិទ្ធិ)។ តួនាទីអង្គហេតុចម្បងនៅក្នុងនីតិវិធីបណ្តឹងអាចជា៖

- អង្គហេតុកកើតសិទ្ធិ (អង្គហេតុដែលជាមូលហេតុនៃការទាមទារ) ជាទូទៅអះអាងដោយដើមចោទ
- អង្គហេតុតវ៉ា (ជាទូទៅអះអាងដោយចុងចម្លើយ)
- អង្គហេតុតវ៉ាតប (ជាទូទៅអះអាងដោយដើមចោទ)
- អង្គហេតុតវ៉ាតប (ជាទូទៅអះអាងដោយចុងចម្លើយ) ជាអាទិ៍។

នៅក្នុងនីតិវិធីបណ្តឹងសកម្មភាពរបស់ចុងចម្លើយឆ្លើយតបនឹងដើមចោទ អាចត្រូវបានកំណត់តាមសកម្មភាពដូចខាងក្រោម[61]៖

ក. ការបដិសេធអង្គហេតុ ៖ នៅពេលដើមចោទអះអាងអង្គហេតុគាំទ្រពាក្យបណ្តឹង ជាអាទិ៍ នៅក្នុងកិច្ចនៃនីតិវិធីណាមួយ ប្រសិនបើចុងចម្លើយធ្វើសេចក្តីថ្លែងការណ៍ផ្ទុយពីអង្គហេតុរបស់ដើមចោទ គេហៅសកម្មភាពនេះថា «ការបដិសេធអង្គហេតុ»។

ខ. ការទទួលស្គាល់អង្គហេតុ ៖ នៅពេលដើមចោទអះអាងអង្គហេតុគាំទ្រពាក្យបណ្តឹង ជាអាទិ៍ នៅក្នុងកិច្ចនៃនីតិវិធីណាមួយ ប្រសិនបើចុងចម្លើយធ្វើសេចក្តីថ្លែងការណ៍ស្របនឹងអង្គហេតុរបស់ដើមចោទ គេហៅសកម្មភាពនេះថា «ការទទួលស្គាល់អង្គហេតុ»។

គ. ការឆ្លើយថាមិនដឹង ៖ នៅពេលដើមចោទអះអាងអង្គហេតុគាំទ្រពាក្យបណ្តឹង ជាអាទិ៍ នៅក្នុងកិច្ចនៃនីតិវិធីណាមួយ ប្រសិនបើចុងចម្លើយធ្វើសេចក្តីថ្លែងការណ៍ថាមិនដឹងអំពីអង្គហេតុរបស់ដើមចោទ ឬស្របនឹងអង្គហេតុរបស់ដើមចោទ ប៉ុន្តែមានអានុភាពរំលត់គេហៅសកម្មភាពនេះថា «ការតវ៉ាអំពីអង្គហេតុ»។

ឃ. ការនៅស្ងៀម ៖ នៅពេលដើមចោទអះអាងអង្គហេតុគាំទ្រពាក្យបណ្តឹង ជាអាទិ៍ នៅក្នុងកិច្ចនៃនីតិវិធីណាមួយ ប្រសិនបើចុងចម្លើយនៅស្ងៀមគេហៅសកម្មភាពនេះថា «ការសារភាពអំពីអង្គហេតុ» លើកលែងតែតុលាការពិចារណាអំពីដំណើរការក្តី និងខ្លឹមសារនៃរឿងក្តីទាំងមូល ហើយយល់ឃើញថា ភាគីនោះបានតវ៉ាអំពីអង្គហេតុ។

នៅក្នុងនីតិវិធីបណ្តឹង (ទ្រឹស្តីអង្គហេតុចម្បង) ការបដិសេធ និងការតវ៉ា មានខ្លឹមសារខុសគ្នា៖

[61] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណីភាគ១ និងភាគ២ ទំព័រទី៨២

ក. ការតវ៉ា សំដៅលើអង្គហេតុតវ៉ា គឺជាអង្គហេតុដែលកើតឡើងស្របគ្នានឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ (អង្គហេតុកកើតសិទ្ធិ) ហើយអានុភាពគតិយុត្តនៃអង្គហេតុតវ៉ាអាចជាការរារាំង ឬការរំលត់ ឬឧបសគ្គនៃសិទ្ធិនូវការកើតឡើងអានុភាពគតិយុត្តនៃអង្គហេតុដែលជាមូលហេតុនៃការទាមទារ។

ខ. អង្គហេតុដែលមិនស្របគ្នានឹងមូលហេតុនៃការទាមទារ គឺជាការបដិសេធមិនមែនជាអង្គហេតុតវ៉ានោះទេ ដូចជាដើមចោទទាមទារឱ្យបង់ប្រាក់ថ្លៃលក់ ផ្អែកលើកិច្ចសន្យាលក់ទិញរថយន្ត ប៉ុន្តែចុងចម្លើយឆ្លើយតបវិញថា មិនមែនជាកិច្ចសន្យាលក់ទិញនោះទេ គឺជាអំណោយ។ ការអះអាងរបស់ចុងចម្លើយបែបនេះ ហៅថា «ការបដិសេធអង្គហេតុ» ដែលជាមូលហេតុនៃការទាមទារមិនមែនជា «អង្គហេតុតវ៉ា» នោះទេ។

នៅក្នុងនីតិវិធីបណ្ដឹង ការទទួលខុសត្រូវក្នុងការបញ្ជាក់ភស្តុតាង គឺជាបន្ទុករបស់ភាគីដែលបានអះអាងអង្គហេតុចម្បង ដែលនាំឱ្យខ្លួនកកើតសិទ្ធិ ហើយភាគីម្ខាងទៀតបដិសេធ លើកលែងតែអង្គហេតុនោះមានលក្ខណៈជាក់ស្ដែង[62] ដូចជាដើមចោទទាមទារឱ្យបង់ប្រាក់ថ្លៃលក់ ផ្អែកលើកិច្ចសន្យាលក់ទិញរថយន្ត ប៉ុន្តែចុងចម្លើយឆ្លើយតបវិញថា មិនមែនជាកិច្ចសន្យាលក់ទិញនោះទេ គឺជាអំណោយ។ ក្នុងករណីនេះ អ្នកទទួលខុសត្រូវក្នុងការបញ្ជាក់ភស្តុតាង គឺដើមចោទ។

សរុបជារួម ការកំណត់អំពីចំណុចវិវាទ ត្រូវធ្វើឡើងចំពោះ «អង្គហេតុមិនមែនកំណត់ចំណុចវិវាទ ទៅលើ «សិទ្ធិទាមទារ» នោះទេ ដូចជាកំណត់ចំណុចវិវាទថា «តើដើមចោទមានសិទ្ធិទាមទារប្រាក់ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិកដែរឬទេ? គឺជាកំណត់ចំណុចវិវាទដែលមិនត្រឹមត្រូវ ហើយអង្គហេតុដែលមានវិវាទជា «អង្គហេតុដែលតុលាការអាចទទួលស្គាល់បានផ្អែកលើភស្តុតាង» ពីព្រោះចំណុចវិវាទ ត្រូវបានកំណត់នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មានន័យថា តុលាការមិនទាន់វិនិច្ឆ័យអំពីសិទ្ធិ (ការទាញហេតុផលដោយផ្ទាល់មាត់) គឺគ្រាន់តែរៀបចំចំណុចវិវាទ ដើម្បីងាយស្រួលក្នុងការរៀបចំភស្តុតាងពាក់ព័ន្ធនឹងចំណុចវិវាទតែប៉ុណ្ណោះ និងពិនិត្យភស្តុតាងទាំងនោះ នៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយសិទ្ធិរបស់គូភាគីមាន ឬមិនមាន តុលាការនឹងវិនិច្ឆ័យនៅពេលចេញសាលក្រម។ ឧទាហរណ៍ថា **ក** បានឱ្យ **ខ** ខ្ចីប្រាក់ចំនួន ១០ លានរៀល នៅថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០០០ ហើយ **ក** មិនទាន់បានទទួលប្រាក់សំណងវិញនៅឡើយ បើទោះបីជាកាលកំណត់ត្រូវសងបានមកដល់តាំងពីថ្ងៃទី ១ ខែ មិថុនាម្ល៉េះក្តី។ ក្នុងករណីនេះ ប្រសិនបើ **ក** បានដាក់ពាក្យបណ្ដឹងទាមទារឱ្យសងប្រាក់ ១០ លានរៀលនោះ ហើយ **ខ** បានថ្លែងថា គាត់មិនបានខ្ចីប្រាក់ពី **ក** ចំនួន ១០ លានរៀលនោះទេ នៅថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០០០ ពេលនោះបញ្ហាដែលថាតើកិច្ចសន្យាខ្ចីប្រាក់ចំនួន ១០ លានរៀល ត្រូវបានធ្វើឡើងរវាង **ក** និង**ខ** កាលពីថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០០០ មែន ឬ

[62] មាត្រា ១២៣ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

មិនមែននោះ នឹងក្លាយទៅជាចំណុចវិវាទនៃរឿងក្តី។ ក៏ប៉ុន្តែ នៅក្នុងករណីជាក់ស្តែង ចំណុចវិវាទពិតប្រាកដ (ចំណុចវិវាទស្នូល) មិនចាត់ទុកថាបានបញ្ជាក់តែដោយចំណុចនេះឡើយ។ ប្រសិនបើ **ក** អះអាងថា ខ្លួនបានឱ្យ **ខ** ខ្ចីប្រាក់ចំនួន ១០ លានរៀល តុលាការយ៉ាងហោចណាស់ត្រូវបង្គាប់ឱ្យ **ក** បំភ្លឺអំពីកាលៈទេសៈដែលនាំទៅដល់ការខ្ចីប្រាក់ ព្រមទាំងរឿងរ៉ាវលំអិតអំពីពេលវេលាដែល **ក** បានឱ្យ ប្រាក់ទៅ **ខ** ខ្ចី ជាអាទិ៍ផងដែរ។ ជាលទ្ធផល ឧទាហរណ៍ថា ក្នុងការឆ្លើយតបទៅនឹងការបង្គាប់ឱ្យបំភ្លឺ **ក** បានថ្លែងថា តាមការពិត គឺ **ខ១** ដែលជាកូនប្រុសច្បងរបស់ **ខ** ទេ ដែលបានមកកាន់ការិយាល័យរបស់ខ្លួន ហើយសុំខ្ចីប្រាក់ក្នុងនាមរបស់ **ខ** ពោលគឺមិនមែន **ខ** ជាអ្នកមកខ្ចីដោយផ្ទាល់ឡើយ។ **ក** បានប្រគល់ មូលប្បទានប័ត្រលើទឹកប្រាក់ចំនួន ១០ លានរៀល ទៅឱ្យ **ខ១** ដោយសារថា **ខ១** មានលិខិតប្រគល់សិទ្ធិតំណាង ក្នុងនាមរបស់ **ខ** ហើយ **ក** ជឿទុកចិត្តលើលិខិតនោះ។ តុលាការត្រូវបង្គាប់ឱ្យ **ខ** ធ្វើការឆ្លើយតបចំពោះការអះអាងលើអង្គហេតុបែបនេះរបស់ **ក**។ ហេតុដូច្នេះ នៅក្នុងករណីនេះ ចំណុចវិវាទពិតប្រាកដនៃរឿងក្តី គឺនៅត្រង់ថាតើមានអង្គហេតុដែល **ខ** បានប្រគល់សិទ្ធិអំណាចឱ្យ **ខ១** ធ្វើជាអ្នកតំណាងរបស់ខ្លួនដែរឬទេ។ ជាងនេះទៅទៀត ក្នុងករណីដែលតុលាការបានបង្គាប់ឱ្យ **ក** ដាក់លិខិតប្រគល់សិទ្ធិតំណាងក្នុងនាមរបស់ **ខ** ដែលខ្លួនបានទទួលពី **ខ១** នោះ និងបានបង្គាប់ឱ្យ **ខ** ធ្វើការបញ្ជាក់អំពីបញ្ហានេះ ប្រសិនបើ **ខ** បានបដិសេធអំពីភាពត្រឹមត្រូវនៃហត្ថលេខា នោះចំណុចវិវាទពិតប្រាកដ កាន់តែត្រូវបានបង្រួមតូចរហូតដល់ភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃហត្ថលេខានៅលើលិខិតប្រគល់សិទ្ធិនោះហើយ។

### កថាភាគទី៥. ការស្នើសុំពិនិត្យភស្តុតាង

តុលាការអាចស្តាប់ពាក្យសុំ និងការអះអាងរបស់ភាគីទាំងសងខាង ហើយអាចចេញដីកាសម្រេចទៅលើការស្នើសុំឱ្យពិនិត្យភស្តុតាង (ឧទាហរណ៍ៈ ដីកាសម្រេចទទួលយក ឬមិនទទួលយកនូវភស្តុតាងដែលត្រូវបានស្នើសុំឱ្យពិនិត្យ ដីកាសម្រេចបង្គាប់ឱ្យធ្វើកោសលវិច័យ ដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ) ជាអាទិ៍[63]។ ម្យ៉ាងទៀត តុលាការក៏អាចធ្វើការពិនិត្យទៅលើភស្តុតាងជាឯកសារ ត្រឹមកម្រិតដែលចាំបាច់ដើម្បីរៀបចំចំណុចវិវាទ និងភស្តុតាងបានដែរ[64]។ ជាមូលដ្ឋាន ការពិនិត្យភស្តុតាងត្រូវធ្វើឡើងនៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ដែលត្រូវបើកជាសាធារណៈទេ ក៏ប៉ុន្តែដើម្បីកំណត់នូវចំណុចវិវាទពិតប្រាកដ តាមរយៈការរៀបចំការអះអាងរបស់ភាគី តុលាការចាំបាច់ត្រូវធ្វើការពិនិត្យលើឯកសារដែលភាគីបានដាក់ ហើយការពិនិត្យភស្តុតាងជាឯកសារនេះ ត្រូវធ្វើឡើងដោយចៅក្រមអានឯកសារនោះ ហេតុដូច្នេះហើយ អត្ថន័យនៃការពិនិត្យភស្តុតាងជាឯកសារនេះ នៅក្នុងសាលសវនាការជាសាធារណៈមិនសំខាន់ដូចការសាកសួរសាក្សីនោះទេ។ ហេតុនេះហើយ បានជាក្រមនីតិវិធីរដ្ឋប្បវេណី អនុញ្ញាតឱ្យតុលាការអាចពិនិត្យភស្តុតាងជាឯកសារ នៅក្នុងនីតិវិធីត្រៀមសម្រាប់

[63] មាត្រា ១២៦ មាត្រា១៤៣ កថាខណ្ឌទី១ និងមាត្រា ១៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[64] មាត្រា ១០៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ការទាញហេតុផលបានត្រឹមកម្រិតដែលចាំបាច់សម្រាប់រៀបចំចំណុចវិវាទ។ ឧទាហរណ៍ ក្នុងករណីដែលចុងចម្លើយតវ៉ា ចំពោះអង្គហេតុនៃការបង្កើតកិច្ចសន្យាលក់ទិញ ហើយព្រមជាមួយគ្នានោះ ចុងចម្លើយអះអាងថា ទោះបីជាការបង្កើតកិច្ចសន្យាលក់ទិញនោះ ត្រូវបានទទួលស្គាល់ក៏ដោយ ក៏ខ្លួនលុបចោលកិច្ចសន្យានោះ ដោយហេតុថា ការបង្ហាញឆន្ទៈបង្កើតកិច្ចសន្យានោះ ត្រូវបានធ្វើឡើងដោយការឆបោក ប្រសិនបើការបង្កើតកិច្ចសន្យាលក់ទិញនោះ ត្រូវបានទទួលស្គាល់ ដោយពិនិត្យលិខិតកិច្ចសន្យានោះដែលដើមចោទដាក់ទៅតុលាការ នោះតុលាការអាចប្រើវិធីនេះដើម្បីរៀបចំចំណុចវិវាទបាន។ ក៏ប៉ុន្តែចំពោះការពិនិត្យភស្តុតាង ដូចជាការសាកសួរសាក្សី និងកោសលវិច័យជាអាទិ៍ មិនអាចធ្វើឡើងបាននៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ។

## ផ្នែកទី៣. ការបញ្ចប់នៃការត្រៀមសម្រាប់ការទាញហេតុផល

ក្នុងករណីដែលនៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទីមួយ មិនអាចបញ្ចប់បានទេ នោះតុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមលើកទីពីរទៀត តែពេលបញ្ចប់នីតិវិធីត្រៀមនីមួយៗ តុលាការត្រូវធ្វើការបញ្ជាក់ជាមួយភាគីនូវអង្គហេតុដែលនឹងត្រូវបំភ្លឺនៅពេលក្រោយ។ ផ្ទុយទៅវិញនៅពេលដែលភាគី និងតុលាការមានការបញ្ជាក់ថា តើអ្វីទៅដែលជាចំណុចវិវាទ ហើយតើចាំបាច់ដើម្បីធ្វើការបញ្ជាក់ភស្តុតាងយ៉ាងណាដែលពាក់ព័ន្ធនឹងចំណុចវិវាទនោះ[65] មានន័យថា ចំណុចវិវាទនៃរឿងក្តី និងភស្តុតាងត្រូវបានរៀបចំរួចហើយ ចំណុចវិវាទបានរកឃើញ នោះនីតិវិធីត្រៀមត្រូវបញ្ចប់។ តុលាការត្រូវធ្វើការបញ្ជាក់ជាមួយភាគីទាំងសងខាងអំពីលទ្ធផលនៃការរៀបចំនេះ ដើម្បីឲ្យមានការឯកភាពគ្នា ព្រមទាំងបញ្ជាក់អំពីអង្គហេតុដែលត្រូវបំភ្លឺដើម្បីត្រៀមធ្វើការពិនិត្យលើភស្តុតាងឲ្យបានល្អិតល្អន់ នៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់នាពេលខាងមុខ។ នៅពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ទាញហេតុផល តុលាការអាចសម្រេចកំណត់ឲ្យភាគីដាក់ភស្តុតាងដោយកំណត់រយៈពេលសមរម្យ អាស្រ័យទៅតាមស្ថានភាពជាក់ស្តែងរបស់ភាគីនៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។

### កថាភាគទី១. កំណត់ហេតុស្តីពីការត្រៀមសម្រាប់ការទាញហេតុផល

សកម្មភាពសំខាន់មួយទៀត ដែលចៅក្រមទទួលបន្ទុកដឹកនាំនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវតែធ្វើនោះ គឺការធ្វើកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។ តុលាការត្រូវឱ្យក្រឡាបញ្ជីធ្វើកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនៅកាលបរិច្ឆេទនីមួយៗ[66]។ គ្រប់កាលបរិច្ឆេទទាំងអស់នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចាំបាច់ត្រូវតែមានកំណត់ហេតុដោយតុលាការត្រូវបង្គាប់ឲ្យ

[65] មាត្រា ១០៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[66] មាត្រា ១០៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ក្រឡាបញ្ជីធ្វើកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។ ហេតុផលសំខាន់ដែលច្បាប់តម្រូវឲ្យតុលាការត្រូវតែធ្វើកំណត់ហេតុនេះ ដោយសារតែកំណត់ហេតុនេះជាភស្តុតាងសំខាន់សម្រាប់បញ្ជាក់ថា តើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ពិតជាត្រូវបានធ្វើឡើងនៅកាលបរិច្ឆេទនោះពិតប្រាកដមែនឬទេ ហើយត្រូវបានធ្វើឡើងត្រឹមត្រូវតាមរបៀបដែលច្បាប់កំណត់ដែរឬទេ ដូចជាការពិនិត្យអំពីវត្តមានរបស់ភាគី កាលបរិច្ឆេទនៃការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ហើយមានការសម្រេចអ្វីខ្លះក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ជារួមគឺដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលអាចកំណត់បានតាមរយៈកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលប៉ុណ្ណោះ។ ចំណុចជារូបមន្ត និងចំណុចសារធាតុនៃកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវកត់ត្រាទៅតាមមាត្រា ១១០ និង១១១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**កថាភាគទី២. អានុភាពនៃការបញ្ចប់ការត្រៀមសម្រាប់ការទាញហេតុផល**

ក្រោយពីនីតិវិធីត្រៀមបានបញ្ចប់ ភាគីមិនអាចដាក់មធ្យោបាយតទល់ ឬការពារខ្លួនជាថ្មីទៀតបានទេនៅដំណាក់កាលនៃការទាញហេតុផលដោយផ្ទាល់មាត់។ ប៉ុន្តែការដាក់មធ្យោបាយតទល់ ឬការពារខ្លួនថ្មីត្រូវបានអនុញ្ញាតក្នុងករណីខាងក្រោម[67]៖

(១) មធ្យោបាយនោះ ទាក់ទងនឹងចំណុចដែលតុលាការត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិ ដូចជាអត្ថិភាព ឬនត្ថិភាពនៃសមត្ថកិច្ចជម្រះក្តី (យោងមាត្រា ១៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

(២) អត្ថិភាព ឬនត្ថិភាពនៃមូលហេតុនៃការដកហូតសមត្ថកិច្ចជម្រះក្តី ជាអាទិ៍ (យោងតាមមាត្រា ២៧ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

(៣) ការដាក់មធ្យោបាយថ្មី មិននាំឱ្យយឺតយ៉ាវដល់នីតិវិធីនៃបណ្តឹង ដូចជាការស្នើសុំឱ្យពិនិត្យភស្តុតាងដែលអាចពិនិត្យបានភ្លាមៗ (ឯកសារដែលភាគីដាក់តាមខ្លួនមកតុលាការជាអាទិ៍)។

(៤) ភាគីបានធ្វើសេចក្តីបញ្ជាក់ដំបូងថា មិនអាចដាក់ភស្តុតាងនៅមុនបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយគ្មានកំហុសធ្ងន់ធ្ងរ (ឧទាហរណ៍ អង្គហេតុដែលកើតឡើងក្រោយនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ការស្នើសុំឱ្យពិនិត្យភស្តុតាងដែលទើបនឹងរកឃើញ ជាអាទ៍)។

[67] មាត្រា ១០៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

# ជំពូកទី៣
# ការទាញហេតុផលដោយផ្ទាល់មាត់

# ជំពូកទី៣

# ការទាញហេតុផលដោយផ្ទាល់មាត់

## ផ្នែកទី១. គោលបំណងនៃការទាញហេតុផលដោយផ្ទាល់មាត់

### កថាភាគទី១. អត្ថន័យ និងភាពចាំបាច់

ការទាញហេតុផលដោយផ្ទាល់មាត់ គឺជាទម្រង់មួយនៃការជម្រះក្តីដែលក្នុងនោះសកម្មភាពរបស់តុលាការ និងសកម្មភាពរបស់ភាគី ចំពោះការជម្រះក្តីនោះត្រូវធ្វើឡើងតាមរយៈការធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ ការស្តាប់សេចក្តីថ្លែងការណ៍នោះនៅសាលសវនាការដែលបើកចំហជាសាធារណៈនៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចមានវត្តមានបាន។

ជាគោលការណ៍ ការសម្រេចសេចក្តីទៅលើបណ្តឹងរដ្ឋប្បវេណីចាំបាច់ត្រូវតែធ្វើតាមរយៈនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់។ ប៉ុន្តែក៏មានបណ្តឹងមួយចំនួនសម្រេចសេចក្តីដោយមិនចាំបាច់ធ្វើតាមរយៈនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នោះទេ។ ដូចជាក្នុងករណីដែលបណ្តឹងមានលក្ខណៈផ្ទុយនឹងច្បាប់ ហើយចំណុចខ្វះនោះមិនអាចកែតម្រូវបាន តុលាការអាចលើកបណ្តឹងនោះចោលដោយសាលក្រម ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់[68]។ ក្នុងករណីដែលបានរៀបរាប់ខាងលើនេះ គឺជាការចេញសាលក្រមដោយមិនចាំបាច់ឆ្លងកាត់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ប៉ុន្តែក្នុងករណីដែលចាំបាច់ត្រូវធ្វើការជម្រះក្តីដោយឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ មានតែអ្វីៗដែលត្រូវបានបង្ហាញក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ឬលទ្ធផលនៃការពិនិត្យភស្តុតាងដែលបានធ្វើឡើងនៅពេលទាញហេតុផលដោយផ្ទាល់មាត់ប៉ុណ្ណោះដែលតុលាការអាចយកមកធ្វើជាមូលដ្ឋាននៃការចេញសាលក្រមបាន[69]។ ប៉ុន្តែចំពោះសេចក្តីសម្រេចដែលតុលាការចេញក្រោមទម្រង់ជាដីកាសម្រេចមានដូចជា ការបញ្ជូនរឿងក្តី និងការដកហូតសមត្ថកិច្ចជំនុំជម្រះ ឬបណ្តឹងជំទាស់ចិត្តចៅក្រម ឬក៏រឿងក្តីដែលត្រូវសម្រេចដោយដីកាសម្រេច មានដូចជា នីតិវិធីដាស់តឿន និងនីតិវិធីរក្សាការពារជាអាទិ៍ ទុកឱ្យតុលាការជាអ្នកសម្រេចដោយឆន្ទានុសិទ្ធិថា ធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬមិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់ទេ[70]។ ហេតុដែលដីកាសម្រេចអាចធ្វើការឆ្លងការទាញហេតុផលដោយផ្ទាល់មាត់ក៏បាន ឬអត់ក៏បាន ដោយសារការសម្រេចដោយដីកាសម្រេច គឺជាបញ្ហាបន្ទាប់បន្សំដែលមិនប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគី ឬជាបញ្ហាដើម្បីជំនុំជម្រះឱ្យបានឆាប់រហ័ស។ នៅក្នុងករណីនេះ ទោះបី

[68]មាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[69]មាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[70]មាត្រា ១១៧ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

តុលាការបើកការទាញហេតុផលដោយផ្ទាល់មាត់ក៏ដោយ ត្រូវចាត់ទុកថានោះ គឺជាការទាញហេតុផលដោយផ្ទាល់មាត់តាមការស្ម័គ្រចិត្ត ហើយចំពោះឯកសារផ្សេង ដែលត្រូវបានដាក់ជាលាយល័ក្ខណ៍អក្សរ ក្រៅពីអ្វីដែលត្រូវបានបង្ហាញនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាចយកមកធ្វើជាមូលដ្ឋានក្នុងការសម្រេចសេចក្តីបាន។ ប្រសិនបើមិនបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ទេ តុលាការនឹងធ្វើការជម្រះសេចក្តីដោយឯកសារ។ នៅក្នុងករណីនេះ ប្រសិនបើចាំបាច់តុលាការអាចកោះហៅភាគីមកសួរដោយផ្ទាល់បាន។ នីតិវិធីនេះ គេហៅថា "ការសួរ"។

**កថាភាគទី២. សិទ្ធិរបស់ចៅក្រម**

ក្នុងការដឹកនាំនីតិវិធីជំនុំជម្រះលើបណ្តឹងឲ្យដើរទៅមុខ ប្រព្រឹត្តទៅដោយពេញលេញ ប្រកបដោយប្រសិទ្ធិភាព ព្រមទាំងការចាត់ចែង និងរៀបចំការជំនុំជម្រះឲ្យបានឆាប់រហ័ស សមរម្យទៅតាមស្ថានភាពនៃការជំនុំជម្រះ ហេតុដូចនេះ សិទ្ធិអំណាចនៃការគ្រប់គ្រងលើនីតិវិធី ដែលបានផ្តល់ឲ្យទៅតុលាការ គេហៅថា សិទ្ធិអំណាចក្នុងការដឹកនាំនីតិវិធីនៃបណ្តឹង។ ជាគោលការណ៍ សិទ្ធិអំណាចក្នុងការដឹកនាំនីតិវិធីបណ្តឹង គឺជាសិទ្ធិអំណាចរបស់តុលាការ ហើយត្រូវអនុវត្តដោយតុលាការដែលខ្លឹមសារនៃសិទ្ធិអំណាចក្នុងការដឹកនាំនីតិវិធីនៃបណ្តឹង មានវិសាលភាពគ្របដណ្តប់ទៅលើដំណើរការទាំងមូលនៃការជំនុំជម្រះដូចជាៈ តុលាការអាចសាកសួរភាគី ឬឲ្យភាគីអះអាង ឬបញ្ជាក់ភស្តុតាងចំពោះចំណុចដែលតុលាការយល់ថាឲ្យភាគីធ្វើការបំភ្លឺ[71]។ ក្នុងករណីដែលតុលាការយល់ឃើញថាចាំបាច់ តុលាការអាចបង្គាប់ឲ្យធ្វើការសាកសួរទៅលើសាក្សី និងសាក្សីផ្សេងទៀតនៅពេលក្នុងពេលជាមួយគ្នាបាន[72]។ ម្យ៉ាងទៀត តុលាការអាចធ្វើការសាកសួរសាមីភាគីបាន ហើយតុលាការក៏អាចឲ្យភាគីស្បថបានដែរ។ ក្នុងករណីដែលភាគីនោះពុំចូលខ្លួន ឬបដិសេធនូវការធ្វើសម្បថ ឬផ្តល់ចម្លើយដោយគ្មានមូលហេតុត្រឹមត្រូវ នោះតុលាការអាចទទួលស្គាល់នូវសេចក្តីអះអាងអំពីចំណុចសាកសួររបស់ភាគីម្ខាងទៀត ថាជាការពិតបាន[73]។ បន្ទាប់ពីបានបញ្ចប់ការរៀបចំចំណុចវិវាទ និងភស្តុតាងរួចមក នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវធ្វើឲ្យការពិនិត្យភស្តុតាងប្រព្រឹត្តទៅជាបន្ទាន់[74]។ នៅពេលដែលនីតិវិធីទាញហេតុផលផ្ទាល់មាត់បានបញ្ចប់ តុលាការត្រូវកំណត់កាលបរិច្ឆេទប្រកាសសាលក្រម ក្នុងអំឡុងពេល១ (មួយ)ខែ[75] ។

---

[71]មាត្រា ៩០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[72] មាត្រា ១៣៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[73] មាត្រា ១៣៨ កថាខណ្ឌទី១០ និងមាត្រា ១៤០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[74] មាត្រា ១២៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[75] មាត្រា ១៨៧នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

### កថាភាគទី៣. សិទ្ធិរបស់ភាគី

ជាគោលការណ៍នៃសិទ្ធិចាត់ចែងរបស់ភាគី នៅពេលចាប់ផ្តើមបណ្តឹង ភាគីជាអ្នកកំណត់នូវកម្មវត្ថុ និងទំហំនៃការទាមទារ ដែលជាទូទៅតុលាការមិនអាចធ្វើការវិនិច្ឆ័យទៅលើចំណុចណាដែលភាគីមិនសរសេរក្នុងពាក្យបណ្តឹងនោះទេ ទោះបីជាតុលាការធ្វើការស្រាវជ្រាវរកឃើញអង្គហេតុ ឬចំណុចដទៃទៀតក៏ដោយក៏តុលាការមិនអាចចេញសាលក្រមនូវចំណុចដែលរកឃើញនោះដែរ។ ក្នុងករណីដែលដើមចោទមានបំណងបញ្ចប់បណ្តឹង ដោយដកពាក្យបណ្តឹងមួយផ្នែក ឬទាំងអស់បានរហូតដល់ពេលដែលសាលក្រមចូលជាស្ថាពរ។ តែប្រសិនបើចុងចម្លើយបានដាក់ឯកសារត្រៀមអំពីអង្គសេចក្តី ឬបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់អំពីអង្គសេចក្តីហើយ ការដកពាក្យបណ្តឹងនេះ ត្រូវមានការយល់ព្រមពីភាគីចុងចម្លើយ[76]។ នៅពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយបានបញ្ចប់ការរៀបចំណុចវិវាទនៃរឿងក្តី និងភស្តុតាងហើយ តុលាការត្រូវបញ្ជាក់ជាមួយភាគីនូវអង្គហេតុដែលត្រូវបំភ្លឺនៅពេលពិនិត្យភស្តុតាង។ ភាគីមានសិទ្ធិក្នុងការធ្វើសេចក្តីថ្លែងការណ៍នៅក្នុងដំណើរការទាញហេតុផលផ្ទាល់មាត់ ដែលធ្វើការអះអាងពីចំណុចវិវាទ[77]។ ភាគីមានសិទ្ធិក្នុងការស្នើសុំដាក់ឯកសារជាភស្តុតាង ក្នុងនោះដែរភាគីត្រូវធ្វើការស្រាវជ្រាវឲ្យបានលម្អិតនូវទំនាក់ទំនងនៃអង្គហេតុចំពោះសាក្សី និងភស្តុតាងផ្សេងៗ ដើម្បីធ្វើការអះអាង និងបញ្ជាក់ឲ្យបានគ្រប់គ្រាន់និងច្បាស់លាស់ក្នុងបណ្តឹង[78]។ បន្ទាប់ពីបានដាក់ភស្តុតាងរួចមក ភាគីត្រូវធ្វើការស្នើសុំទៅកាន់តុលាការឲ្យធ្វើការពិនិត្យនូវភស្តុតាងដែលការពិនិត្យភស្តុតាងនេះ ត្រូវធ្វើឡើងតាមរយៈការស្នើសុំរបស់ភាគីទើបតុលាការ អាចធ្វើការចាប់ផ្តើមបាន[79] ដែលនៅក្នុងការស្នើសុំពិនិត្យភស្តុតាងនេះ ភាគីដែលបានដាក់ពាក្យស្នើសុំត្រូវតែកំណត់ឲ្យបានដាក់លាក់អំពីអង្គហេតុដែលត្រូវបញ្ជាក់ និងទំនាក់ទំនងរវាងអង្គហេតុនោះនិងភស្តុតាងទៅកាន់តុលាការ[80]។

## ផ្នែកទី២. សកម្មភាពក្នុងការទាញហេតុផលដោយផ្ទាល់មាត់

ការទាញហេតុផលដោយផ្ទាល់មាត់ គឺជាទម្រង់មួយនៃការជម្រះក្តី ដែលក្នុងនោះសកម្មភាពរបស់តុលាការ និងភាគីចំពោះការជម្រះក្តីនោះត្រូវធ្វើឡើងតាមរយៈការធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ និងការ

[76]មាត្រា ២១៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[77]មាត្រា ១០៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[78]មាត្រា ៩២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[79]មាត្រា ១២៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[80]មាត្រា ១២៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ស្តាប់សេចក្តីថ្លែងការណ៍នោះនៅសាលសវនាការបើកចំហរជាសាធារណៈនៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចមានវត្តមាន[81]។

នៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវបង្គាប់ឱ្យក្រឡាបញ្ជីធ្វើកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ នៅគ្រប់កាលបរិច្ឆេទនីមួយៗ[82]។ នៅក្នុងកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវកត់ត្រានូវចំណុចដូចមានចែងនៅក្នុងមាត្រា ១១៨ និងមាត្រា ១១៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ជាគោលការណ៍ ការជម្រះក្តីលើបណ្តឹង ត្រូវធ្វើឡើងដោយការទាញហេតុផលដោយផ្ទាល់មាត់[83] ហៅថា នីតិវិធីចេញសាលក្រម។ ហេតុនេះ នៅពេលដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលចប់សព្វគ្រប់ហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទ ដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ហើយត្រូវកោះហៅភាគីមកចូលរួម[84]។ កាលបរិច្ឆេទនេះ ច្បាប់មិនបានកំណត់អំឡុងពេលប៉ុន្មាននោះទេ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ តុលាការត្រូវកំណត់កាលបរិច្ឆេទនៃការទាញហេតុផលឱ្យបានឆាប់រហ័ស ពីព្រោះការទទួលខុសត្រូវរបស់តុលាការ គឺប្រឹងប្រែងដើម្បីរ៉ាប់រងបណ្តឹងរដ្ឋប្បវេណីឱ្យប្រព្រឹត្តទៅដោយមានភាពយុត្តិធម៌ និងឆាប់រហ័ស[85]។

ប៉ុន្តែចំពោះបណ្តឹងដែលមិនបានបំពេញលក្ខខណ្ឌ ដោយមានភាពផ្ទុយច្បាប់ តុលាការអាចចេញសាលក្រមលើកបណ្តឹងនោះចោល ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់[86]។ ម្យ៉ាងវិញទៀត ចំពោះចំណុចណាដែលត្រូវសម្រេចដោយដីកាសម្រេច តុលាការអាចសម្រេចធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬមិនធ្វើបាន[87]។ ទាក់ទងនឹងចំណុចដែលត្រូវសម្រេចដោយដីកាសម្រេច ក្នុងករណីតុលាការមិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាចសួរភាគីបានដែលការសួរភាគី គឺជាការឱ្យភាគីមានឱកាសធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ ឬជាលាយល័ក្ខណ៍អក្សរ[88]។

[81]មាត្រា ១១៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[82]មាត្រា ១១៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[83]មាត្រា ១១៤ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[84]មាត្រា ១១៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[85]មាត្រា ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[86]មាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[87]មាត្រា ១១៤ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[88]មាត្រា ១១៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

## កថាភាគទី១. ការថ្លែងអំពីលទ្ធផលនៃការត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់

នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ជាបឋមភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ទាញហេតុផល (សេចក្តីថ្លែងការណ៍ដោយសង្ខេប)[89]។ សេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ទាញហេតុផល គឺជាសេចក្តីថ្លែងការណ៍សរុបអំពីសកម្មភាពទាំងឡាយដែលបានធ្វើនៅក្នុងនីតិវិធីត្រៀម ដូចនេះតាមរយៈសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ទាញហេតុផល ការអះអាងអង្គហេតុ ការដាក់ភស្តុតាង លទ្ធផលនៃការពិនិត្យភស្តុតាងជាឯកសារ លទ្ធផលនៃការរៀបចំចំណុចវិវាទចាត់ទុកថាបានធ្វើនៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយពុំចាំបាច់ធ្វើសកម្មភាពទាំងនោះឡើងវិញទេ។

នៅពេលធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវបញ្ជាក់ឱ្យច្បាស់លាស់អំពីអង្គហេតុដែលត្រូវបញ្ជាក់ តាមរយៈការពិនិត្យភស្តុតាងដែលនឹងត្រូវធ្វើនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ពោលគឺត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីអង្គហេតុដែលជាចំណុចវិវាទ[90]។

សេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការនឹងឱ្យដើមចោទធ្វើសេចក្តីថ្លែងការណ៍មុននូវចំណុចមួយចំនួនដូចជា ទី១ គោលគំនិតនៃការទាមទារ (បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ចំនួន ២០០០០ ដុល្លារអាមេរិកមកឱ្យដើមចោទ) ទី២ កម្មវត្ថុនៃបណ្តឹង (សិទ្ធិទាមទារឱ្យបង់ប្រាក់ផ្អែកលើកិច្ចសន្យាលក់ទិញ ជាអាទិ៍) ទី៣ មូលហេតុនៃការទាមទារ (អង្គហេតុកកើតសិទ្ធិ) ទី៤ ចំណុចវិវាទ (តើមានកិច្ចសន្យាលក់ទិញនៃរឿងក្តីនេះឬទេ?) ទី៥ ភស្តុតាងពាក់ព័ន្ធនឹងចំណុចវិវាទ (លិខិតកិច្ចសន្យាលក់ទិញ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ២០១៩) ជាអាទិ៍។

បន្ទាប់មក តុលាការនឹងឱ្យចុងចម្លើយធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលជាការឆ្លើយតបរបស់ចុងចម្លើយចំពោះដើមចោទ ដោយចុងចម្លើយអាចបញ្ជាក់ដោយសង្ខេបនូវចំណុចមួយចំនួន ដូចជា ទី១ ច្រានចោលការទាមទាររបស់ដើមចោទ ទី២ បដិសេធមូលហេតុនៃការទាមទាររបស់ដើមចោទ ទី៣ ចំណុចវិវាទដែលលើកឡើងដោយដើមចោទ គឺត្រឹមត្រូវ ទី៤ ស្នើសុំតុលាការពិនិត្យភស្តុតាង ជាអាទិ៍។

[89]មាត្រា ១១៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[90]មាត្រា ១១៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

## ការដាក់មធ្យោបាយតទល់ ឬការពារខ្លួនថ្មី

ការអះអាងបន្ថែមអំពីអង្គហេតុ និងដាក់ភស្តុតាងថ្មី ភាគីអាចធ្វើទៅបានបន្ទាប់ពីបានធ្វើសេចក្តីថ្លែងការណ៍ អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ពោលគឺនៅក្នុងដំណាក់កាលនៃការទាញហេតុផលដោយផ្ទាល់មាត់ ប៉ុន្តែមិនត្រូវឱ្យផ្ទុយនឹងបទបញ្ញត្តិនៃមាត្រា ១០៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីឡើយ។ ចំពោះមធ្យោបាយការអះអាង និងដាក់ភស្តុតាងថ្មី ដែលអាចដាក់បាន គឺមានតែមធ្យោបាយមួយចំនួនប៉ុណ្ណោះ ដែលក្នុងនោះមានដូចជា ការអះអាង និងដាក់ភស្តុតាងថ្មី ដែលពាក់ព័ន្ធទៅនឹងបញ្ហាដែលតុលាការត្រូវធ្វើការស្រាវជ្រាវដោយឆន្ទានុសិទ្ធិរបស់ខ្លួន ការអះអាង និងដាក់ភស្តុតាងថ្មី ដែលមិនបង្កឱ្យមានការយឺតយ៉ាវខ្លាំងទៅដល់នីតិវិធីការអះអាង និងដាក់ភស្តុតាងថ្មីដែលភាគីបានធ្វើសេចក្តីបញ្ជាក់ពីដំបូងថា ការមិនអាចដាក់មធ្យោបាយនោះនៅមុនការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានមិនបណ្តាលមកពីកំហុសធ្ងន់ធ្ងរឡើយ។ នៅក្នុងករណីដែលភាគីធ្វើការអះអាង និងដាក់ភស្តុតាងថ្មី ភាគីត្រូវដាក់មធ្យោបាយទាំងនោះ នៅក្នុងរយៈពេលមួយដែលសមរម្យ នៅក្នុងពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់។ ប៉ុន្តែប្រសិនបើ ភាគីធ្វើការអះអាង និងដាក់ភស្តុតាងថ្មី មិនបានដាក់នៅក្នុងរយៈពេលមួយសមរម្យទេនោះ ហើយធ្វើឲ្យមានការយឺតយ៉ាវដល់ការបញ្ចប់នីតិវិធីដោយកំហុសធ្ងន់ធ្ងរ និងជាចេតនារបស់ភាគី តុលាការអាចចេញដីកាសម្រេចលើកចោលមធ្យោបាយតទល់ ដែលជាការអះអាង និងដាក់ភស្តុតាងថ្មី តាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធិរបស់តុលាការ។

គួរកត់សម្គាល់ផងដែរថា មធ្យោបាយតទល់ស្តីពីការអះអាង និងដាក់ភស្តុតាងថ្មីមិនត្រូវបានកំណត់នៅក្នុងដំណាក់កាលណាមួយជាក់លាក់នោះទេ នៅក្នុងដំណាក់កាលនៃការទាញហេតុផលដោយផ្ទាល់មាត់ ពោលគឺមធ្យោបាយទាំងនោះអាចនឹងត្រូវមានការអូសបន្លាយពេលទៅកាលបរិច្ឆេទណាមួយផ្សេងទៀត។ ប៉ុន្តែគេមិនចាត់ទុក ការលើកមធ្យោបាយទាំងនោះជាដំណាក់កាលផ្សេងក្រៅអំពីនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់នោះទេ គឺត្រូវចាត់ទុកថា បានធ្វើនៅក្នុងដំណាក់កាលនៃការទាញហេតុផលដោយផ្ទាល់មាត់ទាំងមូលតែម្តង។ ក្នុងករណីដែលមានការដាក់មធ្យោបាយតទល់ ឬការពារខ្លួនថ្មី តុលាការត្រូវរៀបចំនូវចំណុចវិវាទ និងភស្តុតាងនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ តែត្រឹមទំហំនៃមធ្យោបាយនោះតែប៉ុណ្ណោះ។ ហេតុដូច្នេះហើយ នៅពេលចំណុចវិវាទ និងភស្តុតាងដែលត្រូវពិនិត្យត្រូវបានកំណត់នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់តែម្តង នោះតុលាការត្រូវកំណត់កាលបរិច្ឆេទសម្រាប់ការពិនិត្យភស្តុតាង កោះហៅគូភាគីឱ្យចូលរួមនៅក្នុងការពិនិត្យភស្តុតាង។

## កថាភាគទី២. ការពិនិត្យភស្តុតាង

ការពិនិត្យភស្តុតាង ត្រូវធ្វើឡើងនៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់[91]។ ប្រសិនបើភស្តុតាងដែលត្រូវពិនិត្យជាភស្តុតាងជាឯកសារ តុលាការអានឯកសារនោះនាសាលសវនាការជាសាធារណៈអំពីខ្លឹមសារនៃភស្តុតាងនោះ ហើយផ្តល់ឱកាសដល់គូភាគីធ្វើសេចក្តីថ្លែងការណ៍អំពីភស្តុតាងនោះ។ ម្យ៉ាងទៀត ភស្តុតាងដែលត្រូវពិនិត្យជាសាក្សី ជាធម្មតាសាក្សី គឺនៅក្រៅសាលសវនាការតុលាការនឹងបង្គាប់ឱ្យក្រឡាបញ្ជីនាំសាក្សីទៅធ្វើសម្បថដោយមានកំណត់ហេតុ។ កំណត់ហេតុសម្បថនោះ ត្រូវដាក់ចូលក្នុងសំណុំរឿងបន្ទាប់ពីសាក្សីបានធ្វើសម្បថ។ តុលាការនឹងប្រាប់សាក្សីអំពីទណ្ឌកម្មព្រហ្មទណ្ឌនានា ដែលអាចកើតមានឡើង ប្រសិនបើសាក្សីផ្តល់សក្ខីកម្មក្លែងដែលបានធ្វើឱ្យតុលាការជឿ ហើយផ្អែកលើជំនឿនោះតុលាការបានសម្រេចនូវសិទ្ធិជាក់លាក់ណាមួយឱ្យទៅភាគីណាមួយ។ តុលាការនឹងប្រាប់សាក្សី សូមនិយាយអ្វីដែលជាការពិតត្រឹមអ្វីដែលសាក្សីបានដឹងឮ ហើយតុលាការនឹងចាប់ផ្តើមសាកសួរសាក្សី ឬផ្តល់សិទ្ធិឱ្យអ្នកតំណាងដោយអាណត្តិរបស់គូភាគី ជាអាទិ៍ សាកសួរសាក្សីនោះទៅតាមខ្លឹមសារនៃពាក្យស្នើសុំឱ្យសាកសួរសាក្សី ដើម្បីទទួលបានចម្លើយដែលពាក់ព័ន្ធនឹងចំណុចវិវាទ។

ការពិនិត្យភស្តុតាង តុលាការអាចៈ

- បើការពិនិត្យភស្តុតាងជាការសាកសួរសាមីភាគី តុលាការនឹងធ្វើការសាកសួរសាមីភាគី ដោយ មុនពេលសាកសួរសាមីភាគីត្រូវធ្វើសម្បថ ហើយតុលាការនឹងចាប់ផ្តើមសាកសួរសាមីភាគី ឬផ្តល់សិទ្ធិឱ្យអ្នកតំណាងដោយអាណត្តិរបស់គូភាគី ជាអាទិ៍ សាកសួរសាមីភាគីទៅតាមខ្លឹមសារនៃពាក្យស្នើសុំឱ្យសាកសួរសាមីភាគី ដើម្បីទទួលបានចម្លើយដែលពាក់ព័ន្ធនឹងចំណុចវិវាទ។
- បើការពិនិត្យភស្តុតាងជាការធ្វើកោលសលវិច័យ តុលាការអានលទ្ធផលនៃកោសលវិច័យរបស់អ្នកជំនាញនាសាលសវនាការជាសាធារណៈអំពីខ្លឹមសារនៃលទ្ធផលកោសលវិច័យនោះ ហើយផ្តល់ឱកាសដល់គូភាគីធ្វើសេចក្តីថ្លែងការណ៍អំពីខ្លឹមសារនៃលទ្ធផលកោសលវិច័យនោះ។
- បើការពិនិត្យភស្តុតាងជាវត្ថុដែលត្រូវត្រួតពិនិត្យ តុលាការនឹងបង្ហាញវត្ថុនោះនាសាលសវនាការជាសាធារណៈ ហើយតុលាការនឹងត្រួតពិនិត្យវត្ថុនោះដោយសមូហវិធី ឬផ្តល់សិទ្ធិឱ្យអ្នកតំណាងដោយអាណត្តិរបស់គូភាគី ឬគូភាគី ជាអាទិ៍ ធ្វើសេចក្តីថ្លែងការណ៍អំពីវត្ថុដែលត្រូវត្រួតពិនិត្យ ដើម្បីទទួលបានចម្លើយដែលពាក់ព័ន្ធនឹងចំណុចវិវាទ។

---

[91]មាត្រា ១២៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ក្រោយពីបានពិនិត្យភស្តុតាងនៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ហើយ បើយល់ឃើញថា «ត្រូវការជាចាំបាច់ពិសេស» តុលាការអាចធ្វើនីតិវិធីត្រៀមសម្រាប់ទាញហេតុផលជាថ្មី ម្តងទៀតបានដោយដីកាសម្រេច[92]។

ពាក្យ «ត្រូវការជាចាំបាច់ពិសេស» ជាស្ថានភាព តាមលទ្ធផលនៅក្រោយពេលដែលបានធ្វើការពិនិត្យភស្តុតាងរួចហើយបានរកឃើញនូវចំណុចវិវាទថ្មី ឬផ្សេង ឬបន្ថែមពីចំណុចវិវាទដែលមានស្រាប់ ដែលមានភាពស្មុគស្មាញនៅក្នុងការដោះស្រាយនៅកាលបរិច្ឆេទទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាចបើកធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលម្តងទៀតបាន។ ដីកាសម្រេចនេះ មិនអាចប្តឹងជំទាស់បានឡើយ។

### ១. ប្រភេទនៃភស្តុតាង

### ក. ភស្តុតាងផ្ទាល់ និងភស្តុតាងប្រយោល

ភស្តុតាងផ្ទាល់ គឺជាភស្តុតាងដែលបញ្ជាក់ដោយផ្ទាល់ អំពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុផ្ទាល់ (អង្គហេតុចម្បង) ដែលឆ្លើយតបទៅនឹងល័ក្ខខ័ណ្ឌផ្ទាល់នៃអានុភាពគតិយុត្ត គឺការបង្កើត កែប្រែ ឬរំលត់ទំនាក់ទំនងគតិយុត្ត។

ភស្តុតាងប្រយោល គឺជាភស្តុតាងដែលបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាព នៃអង្គហេតុប្រយោល និងអង្គហេតុបន្ទាប់បន្សំ ដែលមានប្រយោជន៍ក្នុងការបញ្ជាក់អំពីអង្គហេតុផ្ទាល់។ ក្នុងករណីដែលពុំមានភស្តុតាងផ្ទាល់ទេ ចាំបាច់ត្រូវបញ្ជាក់អំពីអង្គហេតុប្រយោល ដោយផ្អែកលើភស្តុតាងប្រយោល ហើយត្រូវបញ្ជាក់អំពីអង្គហេតុផ្ទាល់ ដោយធ្វើការសន្និដ្ឋានអំពីអង្គហេតុផ្ទាល់ តាមរយៈការអនុវត្តរូបមន្តនៃបទពិសោធន៍ (វិធានតាមបទពិសោធន៍)។ អង្គហេតុបន្ទាប់បន្សំ គឺជាអង្គហេតុស្តីពីលក្ខណៈសម្បត្តិតាមផ្លូវច្បាប់ដែលអាចយកទៅប្រើជាភស្តុតាងបាន (អំណាច ឬសមត្ថភាពជាភស្តុតាង) ឬអង្គហេតុស្តីពីអានុភាពដែលជួយឱ្យចៅក្រម មានការជឿជាក់ទៅលើអ្វីមួយ (តម្លៃជាភស្តុតាង)។ ឧទាហរណ៍ អង្គហេតុបន្ទាប់បន្សំ មានដូចជាអង្គហេតុ ស្តីពីភាពគួរឱ្យជឿបាននៃសេចក្តីថ្លែងការណ៍របស់សាក្សី ឬអង្គហេតុស្តីពីបញ្ហាថាតើឯកសារណាមួយត្រូវបានបង្កើតឡើងដោយត្រឹមត្រូវដែរឬទេ[93]។

[92]មាត្រា ១១៦ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[93] មាត្រា ១៥៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

## ខ. ភស្តុតាងជាមនុស្ស និងភស្តុតាងជាវត្ថុ

ភស្តុតាងជាមនុស្ស សំដៅទៅលើមនុស្ស ក្នុងករណីដែលសាកសួរមនុស្សនោះ ដើម្បីយកសេចក្តីថ្លែងការណ៍របស់មនុស្សនោះមកធ្វើជាភស្តុតាង។ ភស្តុតាងជាមនុស្ស មានដូចជាសាក្សី អ្នកជំនាញខាងកោសលវិច័យ ឬសាមីភាគី រួមទាំងអ្នកតំណាងដែលច្បាប់បានកំណត់ផងដែរ[94]។

ឧបករណ៍ភស្តុតាង ដែលមានកម្មវត្ថុក្រៅពីមនុស្ស គេហៅថា ភស្តុតាងជាវត្ថុដែលមានដូចជាឯកសារ និងវត្ថុដែលត្រូវធ្វើការត្រួតពិនិត្យ។ ទោះបីជាក្នុងករណីដែលកម្មវត្ថុនៃភស្តុតាង គឺជាមនុស្សក៏ដោយ ក្នុងករណីដែលសង្កេតពីអត្តចរិតតាមរយៈទឹកមុខរបស់បុគ្គលនោះ និងការពិនិត្យស្នាមម្រាមដៃរបស់បុគ្គលនោះ ភស្តុតាងនោះ គឺជាភស្តុតាងជាវត្ថុដែរ។

## គ. ភស្តុតាងស្រប និងភស្តុតាងផ្ទុយ

ភស្តុតាងស្រប គឺជាឧបករណ៍ភស្តុតាង ដែលត្រូវដាក់ដោយភាគី (ឧទាហរណ៍ ក) ដើម្បីបញ្ជាក់អំពីអង្គហេតុផ្ទាល់ដែលខ្លួនមានបន្ទុកទទួលខុសត្រូវក្នុងការបញ្ជាក់ផ្ទាល់ខ្លួន។ គោលបំណងនៃភស្តុតាងស្រប គឺធ្វើឱ្យចៅក្រមមានការជឿជាក់ទៅលើអត្ថិភាពនៃអង្គហេតុផ្ទាល់។

ភស្តុតាងផ្ទុយ គឺជាឧបករណ៍ភស្តុតាង (វិធីភស្តុតាង) ដែលត្រូវដាក់ដោយភាគីម្ខាងទៀត (ឧទាហរណ៍ ខ) ដែលធ្វើការតវ៉ាចំពោះអង្គហេតុដែលត្រូវបានអះអាងនោះ (មានន័យថា ធ្វើសេចក្តីថ្លែងការណ៍ថា បដិសេធនូវអង្គហេតុ ឬមិនបានដឹងអំពីអង្គហេតុនោះ[95]។ ភស្តុតាងផ្ទុយមានគោលបំណងរារាំងចៅក្រមមិនឱ្យមានការជឿជាក់ ដោយផ្អែកលើភស្តុតាងស្រប ឬផ្លាស់ប្តូរការជឿជាក់ដែលចៅក្រមមានរួចហើយ។

នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី បានកំណត់ថា មធ្យោបាយផ្តុកភស្តុតាងមាន ០៥ ប្រភេទ ៖

(១) ការសាកសួរសាក្សី៖ ប្រសិនបើចំណុចវិវាទត្រូវបញ្ជាក់ដោយភស្តុតាងជាសាក្សី ភាគីដែលទទួលខុសត្រូវក្នុងការបញ្ជាក់ ត្រូវដាក់ពាក្យស្នើសុំសាកសួរសាក្សី ដូចមានកំណត់នៅក្នុងមាត្រា ១៣៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលមានចំណុចសារធាតុមួយចំនួន ដូចជា ទី១ បញ្ជាក់ឱ្យបានច្បាស់លាស់ទៅលើ អត្តសញ្ញាណសាក្សី និងទី២ បញ្ជាក់អំពីចំណុចដែលត្រូវសាកសួរសាក្សី។

[94] មាត្រា ១៤២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[95] មាត្រា ៩៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

(២) ការសាកសួរភាគី៖ ប្រសិនបើចំណុចវិវាទត្រូវបញ្ជាក់ដោយភស្តុតាង ប៉ុន្តែភាគីយល់ថាភាគីម្ខាងទៀតគប្បីផ្តល់ចម្លើយ ភាគីដែលទទួលខុសត្រូវក្នុងការបញ្ជាក់ ត្រូវដាក់ពាក្យស្នើសុំសាកសួរសាមីភាគី ដូចមានកំណត់នៅក្នុងមាត្រា ១៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

(៣) កោសលវិច័យ៖ ប្រសិនបើចំណុចវិវាទត្រូវបញ្ជាក់ដោយភស្តុតាង ចំពោះភាពមិនប្រក្រតីទៅលើឯកសារជាក់លាក់ណាមួយ ដែលខ្លួនយល់ថាមានប្រយោជន៍ស្របច្បាប់ក្នុងការបំភ្លឺចំណុចវិវាទ ភាគីដែលទទួលខុសត្រូវក្នុងការបញ្ជាក់ ត្រូវដាក់ពាក្យស្នើសុំធ្វើកោសលវិច័យ ដូចមានកំណត់នៅក្នុងមាត្រា ១៤៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលមានចំណុចសារធាតុមួយចំនួន ដូចជា ទី១ ភ្ជាប់ឯកសារដោយកំណត់អំពីចំណុចដែលស្នើសុំធ្វើកោសលវិច័យ ទី២ ផ្ញើឯកសារអំពីចំណុចដែលត្រូវធ្វើកោសលវិច័យទៅអ្នកជំនាញ។ ជាទូទៅដើម្បីអាចធ្វើកោសលវិច័យបាន លុះត្រាតែមានឯកសារច្បាប់ដើម។

(៤) ភស្តុតាងជាឯកសារ៖ ប្រសិនបើចំណុចវិវាទត្រូវបញ្ជាក់ដោយភស្តុតាងជាឯកសារភាគីដែលទទួលខុសត្រូវក្នុងការបញ្ជាក់ ត្រូវដាក់ពាក្យស្នើសុំពិនិត្យភស្តុតាងជាឯកសារ ដូចមានកំណត់នៅក្នុងមាត្រា ១៤៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលមានចំណុចសារធាតុមួយចំនួន ដូចជា ទី១ ផ្តល់ឯកសារដែលសាមីភាគីមាន ឬទី២ ដាក់ពាក្យសុំទៅតុលាការបង្គាប់ឱ្យម្ចាស់ឯកសារផ្តល់ឯកសារមកតុលាការ។ ជាទូទៅ ឯកសារដែលត្រូវបានធ្វើឡើងដោយមន្ត្រីរាជការនៅក្នុងមុខនាទី ដោយផ្អែកទៅលើទម្រង់ និងខ្លឹមសារនៃឯកសារនោះ ត្រូវបានសន្មតថាជាឯកសារសាធារណៈ ដែលបានធ្វើឡើងដោយត្រឹមត្រូវ ដូចជាវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដែលបានធ្វើ និងចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាអាទិ៍ ត្រូវបានចាត់ទុកថាជាឯកសារសាធារណៈដែលបានធ្វើឡើងដោយត្រឹមត្រូវ[96](តុលាការមានទំនុកចិត្ត)។

(៥) ការត្រួតពិនិត្យវត្ថុដែលជាកម្មវត្ថុ៖ ប្រសិនបើចំណុចវិវាទត្រូវបញ្ជាក់ដោយភស្តុតាងជាវត្ថុ ភាគីដែលទទួលខុសត្រូវក្នុងការបញ្ជាក់ ត្រូវដាក់ពាក្យស្នើសុំឱ្យត្រួតពិនិត្យវត្ថុ ដូចមានកំណត់នៅក្នុងមាត្រា ១៦២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលមានចំណុចសារធាតុមួយចំនួន ដូចជា ទី១ ផ្ញើមកនូវវត្ថុដែលត្រូវត្រួតពិនិត្យ ឬទី២ ដាក់ពាក្យសុំទៅតុលាការបង្គាប់ឱ្យម្ចាស់វត្ថុផ្តល់វត្ថុមកតុលាការ។ ជាទូទៅ វត្ថុដែលត្រូវត្រួតពិនិត្យសម្រាប់ជាមធ្យោបាយផ្ទុកភស្តុតាង អាចជាកាំបិត ឬឧបករណ៍ប្រព្រឹត្តបទល្មើសផ្សេងៗជាអាទិ៍ (ករណីទាមទារប្រាក់ ផ្អែកលើអំពើអនីត្យានុកូល)។

[96]មាត្រា ១៥៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

## ២. ការថែរក្សាការពារភស្តុតាង

### ២.១. ភាពចាំបាច់នៃការថែរក្សាការពារភស្តុតាង

ការពិនិត្យភស្តុតាង ជាគោលការណ៍ គឺត្រូវធ្វើឡើងនៅក្នុងដំណាក់កាលនៃការទាញហេតុផលដោយផ្ទាល់មាត់ បន្ទាប់ពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។ ក៏ប៉ុន្តែ ក្នុងករណីពិសេសដែលប្រសិនបើចាំឱ្យដល់ដំណាក់កាលនោះទៅ នឹងអាចមានការមិនអាច ឬមានការពិបាកនឹងពិនិត្យភស្តុតាងបាន។ ឧទាហរណ៍ អាចមានករណីដែលជនដែលនឹងក្លាយជាសាក្សី អាចទទួលមរណភាព ដោយសារមានជម្ងឺធ្ងន់ ឬគ្រោះថ្នាក់ ឬអាចមានករណីដែលជននោះនឹងចេញទៅបរទេស ឬករណីដែលអាចមានការលួចកែឯកសារ ឬអាចមានការផ្លាស់ប្តូរស្ថានភាពនៃកន្លែងដែលត្រូវធ្វើការត្រួតពិនិត្យជាដើម។ ក្នុងករណីដូចនេះ ចាំបាច់ត្រូវធ្វើការពិនិត្យភស្តុតាងជាមុន ដើម្បីរក្សាលទ្ធផលនោះ ហើយនេះគឺជានីតិវិធីថែរក្សាការពារភស្តុតាង[97]។

នីតិវិធីថែរក្សាការពារភស្តុតាង គឺជានីតិវិធីឯករាជ្យពីបណ្តឹងដែលមាននោះ ទោះជាបានធ្វើក្រោយពីការដាក់ពាក្យបណ្តឹងក៏ដោយ។ បណ្តឹងដើមដែលត្រូវការប្រើភស្តុតាងដែលបានរក្សាការពារនេះ ក្នុងនីតិវិធីនេះគេហៅថា បណ្តឹងអង្គសេចក្តី[98]។

### ២.២. ការចាប់ផ្តើមនីតិវិធី

នីតិវិធីថែរក្សាការពារភស្តុតាងអាចចាប់ផ្តើមមុនពេលដាក់ពាក្យបណ្តឹងក៏បាន ក្រោយពេលដាក់ពាក្យបណ្តឹង តែមុនពេលដល់ដំណាក់កាលនៃការពិនិត្យភស្តុតាងក៏បាន។ ជាគោលការណ៍ នីតិវិធីនេះត្រូវចាប់ផ្តើមតាមពាក្យសុំរបស់ភាគី ប៉ុន្តែក្រោយពេលមានពាក្យបណ្តឹង ប្រសិនបើយល់ឃើញថាមានការចាំបាច់ តុលាការអាចចាប់ផ្តើមដោយឆន្ទានុសិទ្ធិបាន[99]។

ពាក្យសុំស្តីពីនីតិវិធីថែរក្សាការពារភស្តុតាង ដែលបានដាក់មុនពេលដាក់ពាក្យបណ្តឹង ត្រូវធ្វើទៅសាលាដំបូងដែលមានសមត្ថកិច្ចនៅទីសំណាក់របស់បុគ្គលដែលត្រូវទទួលនូវការសាកសួរ ឬរបស់បុគ្គលដែលជាម្ចាស់ឯកសារ ឬនៅទីកន្លែងដែលមានវត្ថុដែលជាកម្មវត្ថុនៃការត្រួតពិនិត្យ[100]។ ពាក្យសុំស្តីពីនីតិវិធីថែរក្សាការពារភស្តុតាង ដែលបានដាក់ក្រោយពេលដាក់ពាក្យបណ្តឹង ជាគោលការណ៍ត្រូវធ្វើទៅតុលាការនៃលំដាប់ថ្នាក់ដែលភស្តុតាងនោះនឹងត្រូវបានប្រើប្រាស់[101]។ តុលាការដែលភស្តុតាងនោះនឹងត្រូវបានប្រើប្រាស់ គឺជា

[97]មាត្រា ១៦៣ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[98]មាត្រា ១៦៣ កថាខណ្ឌទី ២ និង ទី ៣ និងមាត្រា ១៧២នៃក្រមនីតិវិធិរដ្ឋប្បវេណី
[99]មាត្រា ១៦៧ នៃក្រមនីតិវិធិរដ្ឋប្បវេណី
[100]មាត្រា ១៦៤ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[101]មាត្រា ១៦៤ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

សាលាដំបូង ក្នុងករណីមុនពេលចេញសាលក្រម ទោះជាបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ក្នុងការជំនុំជម្រះលើកទីមួយហើយក៏ដោយ ពីព្រោះអាចមានការទាញហេតុផលសាជាថ្មីឡើងវិញ ហើយប្រើភស្តុតាងនោះ[102]។ ក៏ប៉ុន្តែ ក្នុងករណីដែលមានការចាំបាច់ធ្វើការពិនិត្យភស្តុតាងជាបន្ទាន់ ទោះជានៅក្រោយពេលបានដាក់ពាក្យបណ្តឹងក៏ដោយ ក៏អាចដាក់ពាក្យសុំឱ្យថែរក្សាការពារភស្តុតាងទៅសាលាដំបូងដែលបានកំណត់ក្នុងមាត្រា ១៦៤ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានដែរ[103]។

ពាក្យសុំឱ្យថែរក្សាការពារភស្តុតាង ត្រូវធ្វើជាលាយលក្ខណ៍អក្សរ[104]។ ក្នុងពាក្យសុំនោះ ត្រូវសរសេរអំពីចំណុចដែលមានចែងក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី២ មាត្រា១៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ចំពោះមូលហេតុនៃការថែរក្សាការពារភស្តុតាង មានន័យថា ភាពចាំបាច់នៃការថែរក្សាការពារភស្តុតាងត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង[105]។ ចំពោះដីកាសម្រេចលើកចោលនូវពាក្យសុំនោះ អ្នកដាក់ពាក្យសុំអាចប្តឹងជំទាស់បាន[106]។

ពេលដាក់ពាក្យសុំថែរក្សាការពារភស្តុតាង មុនការដាក់ពាក្យបណ្តឹង អាចមានករណីដែលមិនដឹងថាអ្នកណាត្រូវជាភាគីម្ខាងទៀត។ ឧទាហរណ៍ ពេលដែលជនរងគ្រោះដោយគ្រោះថ្នាក់ចរាចរណ៍បានដាក់ពាក្យសុំឱ្យត្រួតពិនិត្យកន្លែងកើតគ្រោះថ្នាក់ចរាចរណ៍ក្នុងនាមជាការថែរក្សាការពារភស្តុតាង អាចមានករណីដែលមិនទាន់ដឹងច្បាស់ថាអ្នកណាជាចារី។ ក្នុងករណីនេះ អាចដាក់ពាក្យបណ្តឹងដោយមិនចាំបាច់កំណត់ថា អ្នកណាជាភាគីម្ខាងទៀតបាន ហើយតុលាការអាចជ្រើសតាំងអ្នកតំណាងពិសេសសម្រាប់ជនដែលនឹងក្លាយជាភាគីម្ខាងទៀតបាន[107]។ ក្នុងករណីនេះ តុលាការត្រូវឱ្យអ្នកដាក់ពាក្យសុំធ្វើការបញ្ជាក់ដំបូងអំពីការដែលមិនអាចកំណត់ថា អ្នកណាជាភាគីម្ខាងទៀត ហើយត្រូវឱ្យអ្នកដាក់ពាក្យសុំនោះបង់ប្រាក់កម្រៃសម្រាប់អ្នកតំណាងពិសេសនោះជាមុន។

### ២.៣. ការធ្វើការពិនិត្យភស្តុតាង

ជាគោលការណ៍ ការធ្វើការពិនិត្យភស្តុតាងនេះ ត្រូវធ្វើដូចនីតិវិធីពិនិត្យភស្តុតាងធម្មតាដែរ[108]។ នៅកាលបរិច្ឆេទនៃការពិនិត្យភស្តុតាង ត្រូវកោះហៅអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត។ ក្នុងករណីដែលមានការ

[102]មាត្រា ១៨០ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[103]មាត្រា ១៦៤ កថាខណ្ឌទី៣នៃក្រមរដ្ឋប្បវេណី

[104]មាត្រា ១៦៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[105]មាត្រា ១៦៥ កថាខណ្ឌទី៣នៃក្រមនីតិវិធីរដ្ឋប្បវេណី

[106]មាត្រា ១៦៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[107] មាត្រា ១៦៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[108]មាត្រា ១៦៣ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ជ្រើសតាំងអ្នកតំណាងពិសេសសម្រាប់ជនដែលនឹងក្លាយជាភាគីម្ខាងទៀត ត្រូវកោះហៅអ្នកតំណាងពិសេសនោះ។ ក៏ប៉ុន្តែ ក្នុងករណីដែលមានភាពបន្ទាន់ តុលាការអាចធ្វើការពិនិត្យភស្តុតាង ដោយមិនចាំបាច់កោះហៅជនទាំងនោះក៏បានដែរ[109]។ ទោះជាយ៉ាងណាពេលធ្វើការពិនិត្យភស្តុតាងត្រូវធ្វើកំណត់ហេតុស្តីពីការពិនិត្យភស្តុតាងនោះ[110]។

### ២.៤. ការប្រើលទ្ធផលនៃការពិនិត្យភស្តុតាង

លទ្ធផលនៃការពិនិត្យភស្តុតាងដែលត្រូវបានថែរក្សាការពារនេះ មានអានុភាពជាភស្តុតាងនៅក្នុងបណ្តឹងអង្គសេចក្តី[111]។ ក៏ប៉ុន្តែ ភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃការពិនិត្យភស្តុតាងនោះ នៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្តឹងអង្គសេចក្តី[112]។ នេះគឺដើម្បីបង្ហាញលទ្ធផលនៃការពិនិត្យភស្តុតាងដែលបានធ្វើក្នុងនីតិវិធីថែរក្សាការពារភស្តុតាងនៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ហើយយកលទ្ធផលនោះមកធ្វើជាមូលដ្ឋាននៃសាលក្រម ដោយចាត់ទុកថាមានអានុភាពដូចគ្នានឹងសកម្មភាពដែលបានធ្វើឡើងនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ដែរ (មានគោលបំណងដូចគ្នានឹងសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃការវិធីត្រៀមសម្រាប់ការទាញហេតុផលដែលបានកំណត់នៅក្នុងមាត្រា ១១៦ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ពេលចាប់ផ្តើមចាត់ការបណ្តឹងអង្គសេចក្តីតុលាការដែលបានធ្វើការពិនិត្យភស្តុតាង ត្រូវផ្ញើកំណត់ហេតុស្តីពីការពិនិត្យភស្តុតាងទៅតុលាការនៃបណ្តឹងអង្គសេចក្តី[113]។

លទ្ធផលនៃការពិនិត្យភស្តុតាងដែលត្រូវបានថែរក្សាការពារ នៅតែមានអានុភាពទោះជាក្រោយពេលនោះ អាចធ្វើការពិនិត្យភស្តុតាងនោះនៅក្នុងបណ្តឹងអង្គសេចក្តីក៏ដោយ ក៏ប៉ុន្តែក្នុងករណីដែលបានធ្វើការសាកសួរសាក្សីនៅក្នុងនីតិវិធីនៃការថែរក្សាការពារភស្តុតាង ប្រសិនបើមានការស្នើសុំពីភាគី តុលាការត្រូវធ្វើការសាកសួរសាក្សីនោះម្តងទៀត នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់[114]។ ចំពោះសោហ៊ុយនៃការថែរក្សាការពារភស្តុតាង គឺជាមួយភាគនៃប្រាក់ប្រដាប់ក្តីនៃបណ្តឹងអង្គសេចក្តី[115]។

---

[109]មាត្រា ១៦៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[110]សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ និងភាគ២ ទំព័រ១១៤

[111]មាត្រា ១៦៣ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[112]មាត្រា ១៦៣ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[113] មាត្រា ១៧២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[114]មាត្រា ១៧១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[115] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ និងភាគ២ ទំព័រ១១៤

## ផ្នែកទី៣. ការបញ្ចប់នៃការទាញហេតុផលដោយផ្ទាល់មាត់

បន្ទាប់ពីបានបញ្ជាក់ការពិនិត្យភស្តុតាងហើយ តុលាការដែលអាចនឹងមានជំនឿទុកចិត្តទៅលើទំនាក់ទំនងអង្គហេតុនៃរឿងក្តីតាមរយៈការពិនិត្យភស្តុតាងនេះ ឬដោយផ្អែកតាមគោលការណ៍ទទួលខុសត្រូវក្នុងការបញ្ជាក់ ដែលនឹងមានពន្យល់នៅពេលក្រោយ ត្រូវមានតួនាទីចេញសាលក្រមទៅលើភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវចំពោះការទាមទាររបស់ដើមចោទ។ ប៉ុន្តែ តុលាការអាចអនុញ្ញាតឲ្យភាគីនីមួយៗ ធ្វើការទាញហេតុផលលើកចុងក្រោយបាន នៅមុនពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់[116]។

### កថាភាគទី១. ការទាញហេតុផលចុងក្រោយ

ក្រោយពិនិត្យភស្តុតាង តុលាការនឹងអនុញ្ញាតឱ្យគូភាគីធ្វើការទាញហេតុផលចុងក្រោយ មុនពេលបញ្ឈប់ការទាញហេតុផលដោយផ្ទាល់មាត់[117]។ ការទាញហេតុផលចុងក្រោយជាឱកាសដែលភាគីនីមួយៗអាចលើកឡើងនូវមតិចុងក្រោយរបស់ខ្លួនពាក់ព័ន្ធនឹងភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវ នៃការទាមទាររបស់ដើមចោទដោយផ្អែកលើលទ្ធផលនៃការពិនិត្យភស្តុតាង។

ខ្លឹមសារនៃការទាញហេតុផលចុងក្រោយ គឺតុលាការនឹងឱ្យដើមចោទធ្វើសេចក្តីថ្លែងការណ៍ ជាទូទៅតុលាការនឹងសួរបញ្ជាក់ទៅដើមចោទនូវសំណួរមួយចំនួនដូចជា តើដើមចោទមានអ្វីជាសំដីចុងក្រោយមកតុលាការ? ដើមចោទនឹងឆ្លើយតបវិញថា សំណូមពរតុលាការចេញសាលក្រមតាមខ្លឹមសារនៃការទាមទារ ជាអាទិ៍ ឬបើយល់ថាត្រូវធ្វើនីតិវិធីត្រៀមសាជាថ្មី ក៏អាចធ្វើសេចក្តីថ្លែងការណ៍បែបនេះបានផងដែរ។ បន្ទាប់មកតុលាការនឹងសួរបញ្ជាក់ទៅចុងចម្លើយ នូវសំណួរមួយចំនួនដូចជា តើចុងចម្លើយមានអ្វីជា សំដីចុងក្រោយមកតុលាការ? ចុងចម្លើយនឹងឆ្លើយតបវិញថា សំណូមពរតុលាការចេញសាលក្រមប្រានចោលការទាមទាររបស់ដើមចោទ ជាអាទិ៍ ឬបើយល់ថាត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់បន្ថែមទៀត ក៏អាចធ្វើសេចក្តីថ្លែងការណ៍បែបនេះបានផងដែរ។

[116]មាត្រា ១១៦ កថាខណ្ឌទី៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[117]មាត្រា ១១៦ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

**កថាភាគទី២. អានុភាពនៃការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់**

បន្ទាប់ពីពិនិត្យភស្តុតាងរួចហើយ តុលាការត្រូវមានតួនាទីចេញសាលក្រមទៅលើភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវចំពោះការទាមទាររបស់ដើមចោទ នៅពេលនោះតុលាការត្រូវបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ និងចេញសាលក្រមចុងក្រោយ[118]។

នៅពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវប្រកាសអំពីកាលបរិច្ឆេទនៃការបញ្ចប់នីតិវិធីនោះ ដើម្បីបញ្ជាក់អំពីអានុភាពនៃអាជ្ញាអស់ជំនុំនៃសាលក្រម (សិទ្ធិ ឬទំនាក់ទំនងគតិយុត្តក្នុងចន្លោះពេលពីពេលដាក់ពាក្យបណ្ដឹងដល់កាលបរិច្ឆេទនៃការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់)។

ទោះបីជាការទាញហេតុផលដោយផ្ទាល់មាត់បានបញ្ចប់ក៏ដោយ បើយល់ឃើញថាចាំបាច់តុលាការអាចបើកឱ្យមានការទាញហេតុផលជាថ្មី នៅមុនពេលចេញសាលក្រមចុងក្រោយបាន[119]។

ក្រោយកាលបរិច្ឆេទបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ទោះបីជាគូភាគីបានធ្វើសកម្មភាពបែបណាក៏ដោយ ក៏មិនអាចកែប្រែមូលដ្ឋាននៃការសម្រេចរបស់តុលាការបានឡើយ ដូចជា ក្រោយបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ប៉ុន្តែមុនប្រកាសសាលក្រមចុងក្រោយ ចុងចម្លើយយល់ថាខ្លួននឹងចាញ់ក្ដីហេតុនេះមានបំណងបង់ប្រាក់ទៅដើមចោទ។ ការសងប្រាក់របស់ចុងចម្លើយនាពេលនេះ មិនអាចកែប្រែសេចក្ដីសម្រេចបញ្ចប់របស់តុលាការបានឡើយ។

សាលក្រម គឺជាសេចក្ដីសម្រេចដែលតុលាការធ្វើលិខិតសាលក្រមដែលមានលក្ខណៈគ្រប់គ្រាន់ទៅតាមទម្រង់ដែលច្បាប់បានកំណត់ ដោយផ្អែកលើការទាញហេតុដោយផ្ទាល់មាត់[120]។

សាលក្រមនឹងមានអានុភាពដោយការប្រកាស នៅក្នុងសាលសវនាការជាសាធារណៈ ដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះអានសេចក្ដីសម្រេចបញ្ចប់ ដោយផ្អែកលើច្បាប់ដើមនៃមូលសាលក្រម និងប្រសិនបើយល់ឃើញថាចាំបាច់ ប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចអានសំអាងហេតុនៃសាលក្រម ឬពន្យល់អំពីខ្លឹមសារនៃសំអាងហេតុដោយផ្ទាល់មាត់បាន[121]។

---

[118]មាត្រា ១៨០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[119]មាត្រា ១៨០ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[120] មាត្រា ១៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[121]មាត្រា ១៨៦មាត្រា ១៨៧ និងមាត្រា ១៨៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ការប្រកាសសាលក្រមអាចធ្វើឡើងភ្លាមៗ នៅកាលបរិច្ឆេទបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ឬលើកកាលបរិច្ឆេទទៅពេលក្រោយ។ ប្រសិនបើ តុលាការសម្រេចលើកពេលប្រកាសសាលក្រម ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវជូនដំណឹងអំពីកាលបរិច្ឆេទជាក់លាក់នៃការប្រកាសសាលក្រមទៅគូភាគី។ ប៉ុន្តែការប្រកាសសាលក្រម ត្រូវធ្វើឡើងក្នុងអំឡុងពេល ០១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានបញ្ចប់នូវការទាញហេតុផលដោយផ្ទាល់មាត់ លើកលែងតែរឿងក្តីនោះមានលក្ខណៈស្មុគស្មាញខ្លាំង ឬមានលក្ខណៈទេសៈផ្សេងទៀត (គោលការណ៍ស្តីពីតុលាការត្រូវរ៉ាប់រងបណ្តឹងរដ្ឋប្បវេណីឱ្យបានឆាប់រហ័ស និងយុត្តិធម៌)។ សេចក្តីប្រកាសសាលក្រម អាចធ្វើឡើងបាន ទោះបីជាគ្មានវត្តមានគូភាគីនៅក្នុងសាលសវនាការក៏ដោយ។ តុលាការត្រូវបញ្ជូនអនុសារសាលក្រមទៅឱ្យគូភាគី ក្នុងអំឡុងពេល ០២ (ពីរ) សប្តាហ៍ គិតចាប់ពីថ្ងៃប្រកាសសាលក្រម[122]។

[122]មាត្រា ១៩០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានបញ្ចប់ការសិក្សាស្រាវជ្រាវ អំពីនីតិវិធីការជម្រះក្តីលើកទី១មក ក្រុមយើងខ្ញុំសង្កេតឃើញថា នីតិវិធីការជម្រះក្តីលើកទី១ជានីតិវិធីដោះស្រាយរឿងក្តីរដ្ឋប្បវេណី ដោយសារតែរឿងក្តីរដ្ឋប្បវេណីត្រូវបានដោះស្រាយតាមរយៈនីតិវិធីជំនុំជម្រះក្តីលើកទី១ ក្នុងនោះផងដែរ នៅក្នុងនីតិវិធីជំនុំជម្រះក្តីលើកទី១ ក៏មានបែងចែកជាជំពូកចំនួន០៣ (បី) ។ដូចជា ទី០១ (មួយ) អំពីពាក្យបណ្តឹង បកស្រាយនៃការដាក់ពាក្យបណ្តឹង ការទទួលពាក្យបណ្តឹង ការពិនិត្យពាក្យបណ្តឹង និងការបែងចែករឿងក្តី ទី០២ (ពីរ) ការត្រៀមសម្រាប់ការទាញហេតុផល បកស្រាយអំពីសញ្ញាណនៃការត្រៀមសម្រាប់ការទាញហេតុផល និងការបញ្ចប់ការត្រៀមសម្រាប់ការទាញហេតុផល ទី០៣ (បី) ការទាញហេតុផលដោយផ្ទាល់មាត់ ដែលបានធ្វើការបកស្រាយអំពីសញ្ញាណទូទៅនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់។ ដោយនីតិវិធីនីមួយៗត្រូវបត់បែនទៅតាមស្ថានភាពនៃរឿងក្តី ហើយពេលខ្លះ កាលៈទេសៈនៃរឿងក្តីត្រូវបានផ្លាស់ប្តូរទៅតាមសមត្ថភាពរបស់ភាគីដូចជា កាលណាភាគីនៃវិវាទ មានចំណេះដឹងផ្នែកច្បាប់គ្រប់គ្រាន់ នោះតុលាការមិនសូវមានការលំបាកនៅក្នុងការដឹកនាំនីតិវិធីជម្រះក្តីនោះទេ ប៉ុន្តែប្រសិនបើសមត្ថភាពរបស់ភាគីក្នុងការយល់ដឹងផ្នែកច្បាប់នៅមានកម្រិត នោះតុលាការនឹងជួបប្រទះនូវបញ្ហាមួយចំនួននៅក្នុងការដឹកនាំនីតិវិធី ដោយត្រូវធ្វើការពន្យល់ដល់ភាគីនូវសិទ្ធិរបស់ភាគីនៅក្នុងដំណាក់កាលនីតិវិធីនីមួយៗ។

ហេតុនេះហើយ ទើបក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យមានអ្នកតំណាងដោយអាណត្តិ និងអ្នកជំនួយ ដើម្បីឱ្យភាគីអាចជ្រើសរើសដោយខ្លួនឯង ដើម្បីធ្វើជាអ្នកតំណាងដោយអាណត្តិ ឱ្យខ្លួននៅក្នុងដំណើរការនីតិវិធីរបស់តុលាការបាន ហើយអ្នកតំណាងដោយអាណត្តិ គឺសំដៅទៅលើមេធាវី ដែលជាអ្នកវិជ្ជាជីវៈផ្នែកច្បាប់។ ដើម្បីឱ្យបុគ្គលដែលបានទទួលរងនូវការរំលោភបំពានសិទ្ធិ និងខូចខាតទ្រព្យសម្បត្តិ ទទួលបានសំណងជម្ងឺចិត្ត និងសំណងការខូចខាតអំពីព្យសនកម្មនៃអំពើបំពាន ដែលខ្លួនបានទទួលរងនោះ។ ម៉្យាងទៀត ចំពោះដំណើរការនីតិវិធីជម្រះក្តី គឺមានលក្ខណៈស្មុគស្មាញ និង បត់បែនទៅតាមកាលៈទេសៈនៃរឿងក្តីនីមួយៗ ដូច្នេះហើយ ការកត់កំណត់ហេតុ គឺជាចំណុចដ៏សំខាន់មួយនៅក្នុងដំណើរការនីតិវិធីរបស់តុលាការ ដែលអាចបញ្ជាក់នូវរាល់សកម្មភាពទាំងឡាយដែលបានធ្វើឡើងនៅក្នុងកាលបរិច្ឆេទនៃនីតិវិធីនីមួយៗដូចជា ការកំណត់ចំណុចវិវាទ, ការអះអាងរបស់ភាគី, ការទទួលស្គាល់ ឬមិនទទួលស្គាល់ចំពោះការអះអាង, ការតវ៉ាចំពោះការអះអាង, ការធ្វើសេចក្តីថ្លែងការណ៍របស់ភាគី ឬការធ្វើសេចក្តីថ្លែងការណ៍របស់អ្នកតំណាងដោយអាណត្តិរបស់ភាគី និង ការសះជាគ្នាតាមផ្លូវបណ្តឹងជាដើម។ល។ ជាពិសេស គឺកំណត់ហេតុនៃការសះជា ពោលគឺ ការសះជាតាមផ្លូវបណ្តឹងដែលកំណត់ហេតុនៃការសះជានេះ មានសារៈសំខាន់ណាស់

ពីព្រោះថា កំណត់ហេតុនេះមានអានុភាពដូចគ្នាទៅនឹងសាលក្រមស្ថាពរដែរ ដោយភាគីនៅក្នុងរឿងក្តីអាចយកទៅធ្វើការអនុវត្តបាន ប្រសិនបើការសះជាគ្នានោះ ជាករណីដែលមានការផ្តល់នូវតាវកាលិកណាមួយដោយភាគីម្ខាងទៅឱ្យភាគីម្ខាងទៀត។

យ៉ាងណាមិញ ចំពោះការដោះស្រាយវិវាទតាមរយៈប្រព័ន្ធតុលាការ តុលាការគួរតែព្យាយាមនៅក្នុងការប្រើនីតិវិធីផ្សះផ្សា ដើម្បីរកនូវចំណុចត្រូវរ៉ូវគ្នា ដែលអាចឱ្យភាគីយល់ឃើញថាការផ្សះផ្សាបានផ្តល់អត្ថប្រយោជន៍ដល់ខ្លួនច្រើនជាងការដោះស្រាយវិវាទដោយការចេញសាលក្រម ហើយភាគីផ្ទាល់ផងដែរ គប្បីធ្វើការផ្សះផ្សាគ្នា ជាជាងជ្រើសរើសយកការដោះស្រាយវិវាទដោយការចេញសាលក្រមនោះ ពីព្រោះថា ការដោះស្រាយវិវាទដោយប្រើការសះជាគ្នាអាចបញ្ចប់វិវាទបានឆាប់រហ័សជាងការដោះស្រាយវិវាទដោយការចេញសាលក្រម ហើយម៉្យាងទៀត ការដោះស្រាយវិវាទតាមរយៈការសះជាគ្នា អាចរក្សាទំនាក់ទំនងល្អរវាងភាគីនាពេលអនាគតថែមទៀតផង ដោយភាគីនៅតែអាចធ្វើការទំនាក់ទំនងល្អជាមួយនឹងគ្នា ភាគីអាចធ្វើអាជីវកម្មជាមួយគ្នា និងភាគីអាចធ្វើសកម្មភាពគតិយុត្តជាមួយគ្នាដោយទំនុកចិត្តជាដើម។ល។

ដូច្នេះ គ្រប់ដំណាក់កាលនៃនីតិវិធី សុទ្ធតែមានសារៈសំខាន់ ដែលទាមទារឱ្យចៅក្រម ក៏ដូចជាភាគីយល់ឱ្យច្បាស់អំពីនីតិវិធីនីមួយៗចាប់តាំងពីការដាក់ពាក្យបណ្តឹង រហូតដល់ការចេញសាលក្រមចុងក្រោយទើបការដោះស្រាយរឿងក្តីរដ្ឋប្បវេណីតាមរយៈប្រព័ន្ធតុលាការប្រកបទៅដោយរលូន។

# អនុសាសន៍

# អនុសាសន៍

យើងបានសង្កេតឃើញថា នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ នៅក្នុងប្រទេសកម្ពុជាយើង នៅមិនទាន់បានយល់ដឹងផ្នែកច្បាប់ ក៏ដូចជានីតិវិធីច្បាប់ឱ្យបានទូលំទូលាយនៅឡើយទេ។ ថ្វីត្បិតតែច្បាប់បានបង្កើតឡើងក៏ពិតមែន តែបើប្រជាពលរដ្ឋនៅមិនទាន់បានជ្រួតជ្រាបអំពីច្បាប់ នោះច្បាប់ក៏នៅមិនទាន់អាចធានាបាននូវសន្តិសុខក្នុងសង្គម ដែលជាហេតុធ្វើឱ្យកើតមានជម្លោះនៅក្នុងរឿងក្តីរដ្ឋប្បវេណីកើតមានច្រើនជាបន្តបន្ទាប់ ទាំងរឿងបណ្តឹងអង្គសេចក្តី រឿងក្តីរក្សាការពារ ក៏ដូចជារឿងក្តីអនុវត្តដោយបង្ខំជាដើម។ ហេតុនេះហើយ ដើម្បីឱ្យប្រធានបទសារណាស្តីអំពីការជំនុំជំម្រះក្តីលើកទី១នេះ ប្រព្រឹត្តទៅត្រឹមត្រូវតាមបញ្ញត្តិច្បាប់ដាច់ខាត ត្រូវអនុវត្តតាមច្បាប់ត្រឹមត្រូវទាមទារឱ្យអ្នកមានសមត្ថកិច្ចអនុវត្តច្បាប់ប្រកបដោយស្មារតីយកចិត្តទុកដាក់ខ្ពស់ ក្នុងការបំពេញកិច្ចការងារដែលខ្លួនមានតួនាទីត្រូវបំពេញឱ្យបានល្អ ដើម្បីការពារសិទ្ធិរបស់បុគ្គលឯកជនដោយការទទួលខុសត្រូវតុលាការប្រឹងប្រែង ក្នុងការរ៉ាប់រងបណ្តឹងរដ្ឋប្បវេណីឱ្យប្រព្រឹត្តទៅដោយមានភាពយុត្តិធម៌ និងឆាប់រហ័សដោយមានការចូលរួមចំណែកទទួលខុសត្រូវពីភាគីក្នុងរឿងក្តី ត្រូវអនុវត្តបណ្តឹងរដ្ឋប្បវេណីដោយសុចរិត និងស្មោះត្រង់។ ពោលគឺ ដូចជាក្នុងដំណាក់កាលនៃ ការដាក់ពាក្យបណ្តឹង នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ការទាញហេតុផលដោយផ្ទាល់មាត់ ជាដើម។

ហេតុដូច្នេះហើយ តុលាការ ក៏ដូចជាភាគីមានកាតព្វកិច្ច និងការទទួលខុសត្រូវមួយចំនួនដូចជាៈ

- តុលាការ និងភាគីត្រូវគោរពតាមបទបញ្ញត្តិច្បាប់ដែលមានចែងជាធរមានឱ្យបានខ្ជាប់ខ្ជួនដើម្បីធានានូវការគោរពសិទ្ធិ និងផលប្រយោជន៍របស់ភាគី
- តុលាការត្រូវផ្តល់សិទ្ធិដល់ភាគីឱ្យបានសមរម្យ ចំពោះការស្នើសុំពន្យារពេលនីតិវិធី ដោយត្រូវបើកសិទ្ធិឱ្យភាគីអាចធ្វើការស្នើសុំពន្យារពេល ដើម្បីឱ្យភាគីអាចមានពេលវេលាគ្រប់គ្រាន់សម្រាប់រៀបចំខ្លួនជាមុន ស្វែងរកមេធាវីដើម្បីធ្វើជាអ្នកតំណាងដោយអាណត្តិឱ្យខ្លួន និងស្វែងរកឯកសារពាក់ព័ន្ធនឹងរឿងក្តីផ្សេងៗទៀត មុនពេលដែលភាគីត្រូវចូលរួមនីតិវិធីនីមួយៗរបស់តុលាការ។ ប៉ុន្តែការពន្យារពេលនេះតុលាការក៏មិនត្រូវបើកសិទ្ធិ ឱ្យភាគីជ្រុលហួសហេតុពេកដែរ ពោលគឺ កុំឱ្យភាគីស្នើសុំពន្យារពេលនីតិវិធីច្រើនដងពេក ដែលអាចធ្វើឱ្យមានការកកស្ទះសំណុំរឿងនៅតុលាការ និងភាគីអាចនឹងមានបំណងចង់គេចវេសមិនចូលរួមនីតិវិធីរបស់តុលាការ ដោយ ការស្នើសុំពន្យារពេលនីតិវិធីនេះ
- នៅក្នុងកិច្ចនីតិវិធីជំនុំជម្រះក្តីលើកទី១ នៅពេលដែលភាគីធ្វើសកម្មភាពនៅក្នុងកាលបរិច្ឆេទនៃនីតិវិធីនីមួយៗ តុលាការត្រូវផ្តល់នូវសិទ្ធិស្មើគ្នាចំពោះភាគី ដូចជាការផ្តល់សិទ្ធិឱ្យភាគីបានធ្វើការអះអាង តវ៉ាថ្លែងការណ៍, តទល់ និងការបង្ហាញភស្តុតាងឱ្យបានគ្រប់គ្រាន់ ដើម្បីឱ្យតុលាការទទួលបាននូវគោលគំនិតពីសកម្មភាពដែលបានធ្វើឡើងនោះ សម្រាប់យកមកធ្វើជាមូលដ្ឋានក្នុងការពិចារណា និងវិនិច្ឆ័យ

សម្រេចសេចក្ដីហើយនិងកុំឱ្យភាគីមានអារម្មណ៍ថា តុលាការបានរឹតត្បិតសិទ្ធិភាគីណាម្ខាងមិនឱ្យធ្វើសកម្មភាពនៅពេលដែលតុលាការធ្វើការសម្រេចសេចក្ដីចប់សព្វគ្រប់តាមនីតិវិធីរួចរាល់ហើយ តុលាការត្រូវតែធ្វើការជូនដំណឹង និងបញ្ជូនឯកសារពាក់ព័ន្ធទៅឱ្យភាគីភ្លាមៗ ដើម្បីឱ្យភាគីបានដឹងអំពីលទ្ធផលនៃការជំនុំជម្រះលើរឿងក្ដីរបស់ខ្លួន និងដើម្បីឱ្យភាគីអាធ្វើការប្ដឹងឧបាស្រ័យបានទាន់ពេលវេលា ប្រសិនបើភាគីណាមួយ មិនពេញចិត្តនឹងការសម្រេចសេចក្ដីរបស់តុលាការ។

- ការជម្រះក្ដីត្រូវធានាឱ្យបានថា ត្រូវធ្វើឡើងដោយគោរពតាមគោលការណ៍ចំពោះមុខ ដើម្បីធានាឱ្យបាននូវតម្លាភាព ក៏ដូចជាទំនុកចិត្តជាសាធារណៈ។

តុលាការ គួរតែធ្វើការបញ្ជាក់ឱ្យបានច្បាស់លាស់ ដើម្បីឱ្យភាគីបានយល់ដឹងអំពីសិទ្ធិរបស់ខ្លួនដែលអាចធ្វើការប្ដឹងលើដីកាសម្រេច ឬសាលក្រម ដែលតុលាការបានចេញនៅក្នុងអំឡុងពេលដែលច្បាប់បានកំណត់ ដើម្បីជៀសវាងនូវករណីដែលភាគីថ្លោះសិទ្ធិនៅក្នុងការប្ដឹងឧបាស្រ័យ ឬប្ដឹងទាស់ជាដើម។ ដោយសាលក្រមចុងក្រោយ បានធ្វើការសម្រេចសេចក្ដីអំពីវិវាទរបស់ភាគីនោះ ត្រូវធានាឱ្យថាបានធ្វើតាមដំណើរការនៃនីតិវិធីទៅតាមលំដាប់លំដោយតាមបទបញ្ញត្តិច្បាប់ដែលមានចែងជាធរមាន។

# ឯកសារយោង

## ឯកសារយោង

- ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
- ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
- សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ និងភាគ២
- សៀវភៅមេរៀនស្តីពីនីតិវិធីបណ្តឹងរបស់លោកមេធាវី អ៊ុំ ប៉ូលី

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

## តារាងឧបសម្ព័ន្ធ

១.បង្កាន់ដៃបង់ប្រាក់

២.ពាក្យបណ្ដឹង

៣.លិខិតតំណាងដោយអាណត្តិ

៤.ពាក្យសុំថតចម្លងសំណុំរឿង

៥.លិខិតប្រគល់សិទ្ធិដល់មេធាវីតំណាងដោយអាណត្តិ

៦.ពាក្យសុំជូនពិនិត្យភស្តុតាង

៧.កំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

៨.ភស្តុតាង

៩.សេចក្ដីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិ

១០.កំណត់ហេតុស្ដីពីនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

១១.សាលក្រមរដ្ឋប្បវេណី។

គំរូលេខ ០១ សហវ/ចមក

260-1- 00202258

MEF20882604121

ក្រសួងយុត្តិធម៌

# បង្កាន់ដៃបង់ប្រាក់

(ប្រគល់ជូនអ្នកបង់ប្រាក់)

អង្គភាព.......................................

ទទួលពី ........................................ អង្គភាព........................................

ចំនួនទឹកប្រាក់ជាលេខ ........................................................................

ជាអក្សរ ........................................................................

អត្ថន័យចំណូល........................................ មាតិកាថវិកា........................

............ ថ្ងៃទី..... ខែ..... ឆ្នាំ.....

អ្នកប្រមូលចំណូល

[redacted] 1720 /21.10.2022

ឈុន តារ ៥.4

អេង សុវណ្ណារ៉ា

បង្កាន់ដៃនេះត្រូវបានបោះពុម្ព និងគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្របតាមអនុក្រឹត្យលេខ ៨២អនក្រ. ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ
ចូល ថ្ងៃទី.21...ខែ.10...ឆ្នាំ2022

## ពាក្យបណ្តឹង

❖ **ដើមចោទ**

ឈ្មោះ ភេទប្រុស កើតថ្ងៃទី០២ ខែមីនា ឆ្នាំ១៩៨៧ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ០២០៩៩៨៥៨៩០ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៣ និងប្រពន្ធឈ្មោះ ភេទស្រី កើតថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨៨ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ០១១៣៣៦៣២១ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩ មានអាសយដ្ឋានផ្លូវលំ ភូមិដីថ្មី សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

❖ **សហចុងចម្លើយ៖**

១. ឈ្មោះ អាយុ៧០ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរមានអាសយដ្ឋានភូមិដីថ្មី សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

២. ឈ្មោះ អាយុ៦៩ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរមានអាសយដ្ឋានភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

៣. ឈ្មោះ អាយុ៦៥ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានអាសយដ្ឋានសង្កាត់ស្ទោះ ខណ្ឌកំបូល រាជធានីភ្នំពេញ ។

៤. ឈ្មោះ ភេទស្រី កើតថ្ងៃទី០៦ ខែកក្កដា ឆ្នាំ១៩៧១ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ០១១១២៣៨៣៩ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៦ មានអាសយដ្ឋានផ្ទះលេខ២១ ផ្លូវបេតុង ភូមិដីថ្មី សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

សាលាដំបូងរាជធានីភ្នំពេញ
បញ្ជាក់លេខ 00202258
ចុះថ្ងៃទី 21 ខែ 10 ឆ្នាំ 2022

**សូមគោរពជូនចំពោះ**

**ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ**

### ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ

១.បង្គាប់ឱ្យសហចុងចម្លើយទទួលស្គាល់ដើមចោទជាម្ចាស់កម្មសិទ្ធិដីមួយកន្លែង មានទំហំ ១១៣ម²(មួយរយដប់បីម៉ែត្រការ៉េ) មានក្បាលដីលេខ ១៥០ មានទីតាំងស្ថិតនៅភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ (បច្ចុប្បន្នស្ថិតនៅភូមិដីថ្មី សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ) មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ចេញដោយប្រធានមន្ទីរៀបចំដែនដី នគររូបនីយកម្មសំណង់ និងសុរិយោដីរាជធានីភ្នំពេញ ។

២.បង្គាប់ឱ្យចុងចម្លើយបំពេញបែបបទ នៅចំពោះមុខមន្ត្រីសុរិយោដី តាមនីតិវិធីច្បាប់ ដើម្បីផ្ទេរសិទ្ធិកម្មសិទ្ធិ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ មកឱ្យដើមចោទ ។

៣.បង្គាប់ឲ្យមន្ត្រីសុរិយោដី និងអាជ្ញាធរពាក់ព័ន្ធ បំពេញបែបបទតាមនីតិវិធីច្បាប់ ដើម្បីផ្ទេរសិទ្ធិកម្មសិទ្ធិ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ មកឲ្យដើមចោទជាម្ចាស់កម្មសិទ្ធិ ។

## ខ. អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារ

កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩ ឈ្មោះ និងប្រពន្ធឈ្មោះ បានលក់ដីមួយកន្លែង មានទំហំ ១១៣ម$^{២}$(មួយរយដប់បីម៉ែត្រការ៉េ) មានក្បាលដីលេខ ១៥០ មានទីតាំងស្ថិតនៅភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ (បច្ចុប្បន្នស្ថិតនៅភូមិដីថ្មី សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ) មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ចេញដោយប្រធានមន្ទីររៀបចំដែនដីនគររូបនីយកម្មសំណង់ និងសុរិយោដីរាជធានីភ្នំពេញ មកឲ្យឈ្មោះ និងប្រពន្ធឈ្មោះ ដោយបានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែង លេខ ០៣៤ លប ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩ ចេញដោយចៅសង្កាត់ភ្នំពេញថ្មី ។ ក្រោយមកនៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០ ឈ្មោះ និងឈ្មោះ បានព្រមព្រៀងលក់ដីខាងលើមកឲ្យឈ្មោះ ដោយបានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែង លេខ ១១៨ លប ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០ ចេញដោយចៅសង្កាត់ភ្នំពេញថ្មី ហើយបន្ទាប់មកទៀតទើបឈ្មោះ បានលក់ដីខាងលើមកឲ្យដើមចោទ នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែង លេខ ១៧៤៨ លប ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ចេញដោយចៅសង្កាត់ភ្នំពេញថ្មី ។

បន្ទាប់ពីបានទទួលកម្មសិទ្ធិលើដីខាងលើ ដើមចោទបានគ្រប់គ្រង ប្រើប្រាស់ និងអាស្រ័យផលជាលើដីនេះរហូតមកដល់សព្វថ្ងៃ ប៉ុន្តែនៅអំឡុងឆ្នាំ២០២២ នេះដើមចោទមានបំណងផ្ទេរសិទ្ធិកម្មសិទ្ធិក្នុងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ចេញដោយប្រធានមន្ទីររៀបចំដែនដីនគររូបនីយកម្មសំណង់ និងសុរិយោដី រាជធានីភ្នំពេញ មានឈ្មោះខ្លួនជាម្ចាស់កម្មសិទ្ធិនោះ មិនទាន់អាចធ្វើបាននៅឡើយដោយហេតុថា ឈ្មោះ និងប្រពន្ធឈ្មោះ ដែលមានឈ្មោះ ជាម្ចាស់កម្មសិទ្ធិក្នុងវិញ្ញាបនបត្រខាងលើ បានទទួលមរណភាព មិនទាន់បានចូលខ្លួនមកបំពេញបែបបទ នៅចំពោះមុខមន្ត្រីសុរិយោដី ដើម្បីផ្ទេរសិទ្ធិកម្មសិទ្ធិមកឲ្យដើមចោទជាម្ចាស់កម្មសិទ្ធិនៅឡើយ ។ ឈ្មោះ និងប្រពន្ធឈ្មោះ មានកូនទាំងអស់ចំនួន ០៤នាក់(បួន) ដែលជាសហចុងចម្លើយទាំងអស់ ។

ដើម្បីអាចឲ្យដើមចោទ ទទួលបានសិទ្ធិ ជាម្ចាស់កម្មសិទ្ធិលើដីទំហំ ១១៣ម$^{២}$(មួយរយដប់បីម៉ែត្រការ៉េ) មានក្បាលដីលេខ ១៥០ មានទីតាំងស្ថិតនៅភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ (បច្ចុប្បន្នស្ថិតនៅភូមិដីថ្មី សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ) មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ចេញដោយប្រធានមន្ទីររៀបចំដែនដីនគររូបនីយកម្មសំណង់ និងសុរិយោដីរាជធានីភ្នំពេញ សូម **ឯកឧត្តមប្រធាន** មេត្តាសម្រេចតាមពាក្យបណ្តឹងខាងលើដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** ទទួលការគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំ ។

**គ. សេចក្តីបញ្ជាក់ដំបូង (ជាឯកសារថតចម្លង)**

១,. ឯកសារផ្ទេរសិទ្ធិកម្មសិទ្ធិពីឈ្មោះ និងប្រពន្ធឈ្មោះ មកឱ្យឈ្មោះ និងប្រពន្ធឈ្មោះ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩ ។

២,. ឯកសារផ្ទេរសិទ្ធិកម្មសិទ្ធិពីឈ្មោះ និងប្រពន្ធឈ្មោះ មកឱ្យឈ្មោះ ចុះថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០១០ ។

៣,. ឯកសារផ្ទេរសិទ្ធិកម្មសិទ្ធិពីឈ្មោះ មកឱ្យឈ្មោះ និងប្រពន្ធឈ្មោះ ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០១៦ ។

៤,. ឯកសារបញ្ជាក់ពីអត្តសញ្ញាណដើមបណ្តឹង ។

៥,. ឯកសារបញ្ជាក់ពីអត្តសញ្ញាណសហចុងចម្លើយ និងទំនាក់ទំនងញាតិរវាង ឈ្មោះ និងប្រពន្ធឈ្មោះ ត្រូវជាម្តាយ និងឪពុករបស់សងចុងចម្លើយ ។

រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២

**ស្នាមម្រាមដៃស្តាំ**



ក្រុមមេធាវី ស៊ីនហាន
SHINHAN LAW GROUP

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ
ចូល លេខ ១០០៨ ថ្ងៃទី ២៦.០១.២០២៣ ម៉ោង ១០ និង ៤០ នាទី

## លិខិតតំណាងដោយអាណត្តិ

ខ្ញុំមេធាវី **សូ សុវណ្ណារិទ្ធ** អត្តលេខ ២០៧៦ ជាសមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា មានការិយាល័យ **ក្រុមមេធាវី ស៊ីនហាន** (SHINHAN LAW GROUP) ស្ថិតនៅផ្សារទំនើបស៊ីធីម៉ល ជាន់ទី៣ ផ្លូវ២១៧(មហាវិថីមុនីវ៉េត) សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ។

**សូមគោរពចូលមក**
**ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ** : សុំធ្វើជាមេធាវីតំណាងដោយអាណត្តិក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ១៧២០ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ ។

**យោង** : -ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។
-ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ។
-លិខិតប្រគល់សិទ្ធិជូនមេធាវីតំណាងដោយអាណត្តិ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣ របស់ឈ្មោះ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា: អាណត្តិទាយក ឈ្មោះ បានប្រគល់សិទ្ធិដល់ខ្ញុំធ្វើជាមេធាវីតំណាងដោយអាណត្តិក្នុងសំណុំរឿងដូចមានចែងក្នុងកម្មវត្ថុខាងលើ ។

អាស្រ័យដូចបានជំរាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាជ្រាប និងអនុញ្ញាតឱ្យខ្ញុំធ្វើជាមេធាវីតំណាងតាមនីតិវិធីច្បាប់ចាប់ពីពេលនេះតទៅ ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពរាប់អានអំពីខ្ញុំ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៣

**ហត្ថលេខា**

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

មេធាវី សូ_សុវណ្ណារិទ្ធ

3Floor, CityMall Shopping Center St. 217 Monireth Blvd, Sangkat Veal Vong, Khan 7 Makara, Phnom Penh, Cambodia.
Tel: 070 667 667 / 067 355 168 / 078 355 168 E-mail: so.sovannarith9999@gmail.com

ក្រុមមេធាវី ស៊ីនហាន
SHINHAN LAW GROUP

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## <u>ពាក្យសុំថតចម្លងសំណុំរឿង</u>

ខ្ញុំមេធាវី **សូ សុវណ្ណារិទ្ធ** អត្តលេខ **២០៧៦** ជាសមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា មានការិយាល័យ **ក្រុមមេធាវីស៊ីនហាន** (SHINHAN LAW GROUP) ស្ថិតនៅផ្សារទំនើបស៊ីធីម៉ល ជាន់ទី៣ ផ្លូវ ២១៧(មហាវិថីមុនីរ៉េត) សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ។

**<u>សូមគោរពចូលមក</u>**

**ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ**

**<u>កម្មវត្ថុ</u>** ៖សំណើសុំថតចម្លងសំណុំរឿងលេខ១៧២០ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ ។

**<u>យោង</u>**៖ -ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ។

-ច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ។

-លិខិតប្រគល់សិទ្ធិដល់មេធាវីតំណាងដោយអាណត្តិ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣ របស់ឈ្មោះ [redacted] ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា ៖ ដោយខ្ញុំបាទជាមេធាវីការពារនៅក្នុងរឿងក្តីនេះ ហើយត្រូវពិនិត្យនិងសិក្សាសំណុំរឿងទាំងមូល ដើម្បីត្រៀមលក្ខណៈការពារកូនក្តីក្នុងនីតិវិធីរបស់តុលាការ ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមប្រធាន** មេត្តាអនុញ្ញាតតាមពាក្យសុំក្នុងកម្មវត្ថុខាងលើរបស់ខ្ញុំបាទ ដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពរាប់អានពីខ្ញុំ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៣

**ហត្ថលេខា និង ត្រា**

រាជាណាចក្រកម្ពុជា
មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

មេធាវី សូ_សុវណ្ណារិទ្ធ

3Floor, CityMall Shopping Center St. 217 Monireth Blvd, Sangkat Veal Vong, Khan 7 Makara, Phnom Penh, Cambodia.
Tel: 070 667 667 / 067 355 168 / 078 355 168 E-mail: so.sovannarith9999@gmail.com

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ
ចូល លេខ ១៣៧០ក៥
ថ្ងៃទី ២៣ ខែ ១២ ឆ្នាំ ២០២២
ម៉ោង ៤ នាទី ២០

## ពាក្យសុំជូនពិនិត្យភស្តុតាង

ខ្ញុំបាទឈ្មោះ [illegible] ភេទប្រុស កើតថ្ងៃទី០២ ខែមីនា ឆ្នាំ១៩៨៧ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ០២០៩៩៨៥៨៩០ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៣ មានអាសយដ្ឋានផ្ទះលំ ភូមិដីថ្មី សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

**សូមគោរពចូលមក**
**ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ**: សុំជូនពិនិត្យភស្តុតាងជាឯកសារថតចំលង ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ១៧២០ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ ។

**យោង**:-សំណុំរឿងរដ្ឋប្បវេណីលេខ ១៧២០ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ ។

សេចក្តីដូចបានជម្រាបជូនខាងលើ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា: ខ្ញុំបាទសុំជូនពិនិត្យភស្តុតាង ជាឯកសារថតចម្លង៖

**១, ឯកសារបញ្ជាក់ថាចុងចម្លើយជា សន្តតិជនរបស់ឈ្មោះ [illegible] និងឈ្មោះ [illegible]:**

ក/. ឯកសារបញ្ជាក់ពីអត្តសញ្ញាណរបស់ឈ្មោះ ឯក លុន:

- សំបុត្របញ្ជាក់កំណើតឈ្មោះ [illegible] មានលេខ ៤៧៤៩ ក្នុងសៀវភៅបញ្ជាក់កំណើតលេខ ៥១/២០០៥ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៥ ។
- អត្តសញ្ញាណប័ណ្ណឈ្មោះ [illegible] មានលេខ ០១០២០៩៥៦២(០១) ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៤ ។

ខ/. ឯកសារបញ្ជាក់ពីអត្តសញ្ញាណរបស់ឈ្មោះ ឯក ផាន់ណា:

- សំបុត្របញ្ជាក់កំណើតឈ្មោះ [illegible] មានលេខ ៧៤៥៩ ក្នុងសៀវភៅបញ្ជាក់កំណើតលេខ ៨០/២០០៥ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៥ ។
- អត្តសញ្ញាណប័ណ្ណឈ្មោះ [illegible] មានលេខ ០១០២០៩៧០៥(០១) ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤ ។
- សៀវភៅស្នាក់នៅ របស់ឈ្មោះ [illegible] ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ ។

គ/. ឯកសារបញ្ជាក់ពីអត្តសញ្ញាណរបស់ឈ្មោះ [illegible]:

- សំបុត្របញ្ជាក់កំណើតឈ្មោះ [illegible] មានលេខ ៤៧០០ ក្នុងសៀវភៅបញ្ជាក់កំណើតលេខ ៥០/២០០៥ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៥ ។

ក

- អត្តសញ្ញាណប័ណ្ណឈ្មោះ មានលេខ ០១០៤៣០៧២៣(០១) ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៥ ។

**ឃ**/. ឯកសារបញ្ជាក់ពីអត្តសញ្ញាណរបស់ឈ្មោះ :

- អត្តសញ្ញាណប័ណ្ណឈ្មោះ មានលេខ ០១១១២៣៨៣៩(០១) ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៦ ។
- សៀវភៅស្នាក់នៅលេខ ២៦៨៨ របស់ឈ្មោះ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៩ ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យភស្តុតាងជាឯកសារថតចំលងខាងលើ ដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ ។

រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២

**ស្នាមម្រាមដៃស្តាំ**



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងរាជធានីភ្នំពេញ**
សំណុំរឿងរដ្ឋប្បវេណីលេខ: ១៧២០
ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២

## កំណត់ហេតុស្ដីពី
## នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

សញ្ញាណនៃរឿងក្ដី: ប្ដឹងសុំសាលក្រមទទួលស្គាល់ជាម្ចាស់កម្មសិទ្ធិដី

កាលបរិច្ឆេទ: ពីរពាន់ម្ភៃពីរ ខែធ្នូ ថ្ងៃទីដប់បួន វេលាម៉ោង ២ និង ៣០ នាទី រសៀល

ទីកន្លែង: បន្ទប់ "ថ" ជាន់ទី៤ នៃសាលាដំបូងរាជធានីភ្នំពេញ

**ដោយមានសមាសភាព**

លោកស្រី **ឈុន ដាទី** ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោកស្រី **ម៉ុខ សៀកលីខ** ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**ភាគីមាន**

**ដើមចោទ** ឈ្មោះ ភេទប្រុស កើតឆ្នាំ១៩៨៧ ជនជាតិ ខ្មែរ ទីលំនៅបច្ចុប្បន្នផ្លូវលំ ភូមិថ្មី សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

សហចុងចម្លើយ៖

១-ឈ្មោះ អាយុ ៧០ឆ្នាំ ជនជាតិខ្មែរ មានអាសយដ្ឋាននៅភូមិដីថ្មី សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

២-ឈ្មោះ អាយុ ៦៩ឆ្នាំ ជនជាតិខ្មែរ អាសយដ្ឋាននៅភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

៣-ឈ្មោះ អាយុ ៦៥ឆ្នាំ ជនជាតិខ្មែរ មានអាសយដ្ឋាននៅសង្កាត់ស្ពាន ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

៤-ឈ្មោះ កើតឆ្នាំ១៩៧១ ជនជាតិខ្មែរ អាសយដ្ឋាននៅផ្ទះលេខ២១ ផ្លូវបេតុង ភូមិដីថ្មី សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

១. ខ្លឹមសារនៃសាលក្រមដែលដើមចោទបានទាមទារ

ក-បង្គាប់ឱ្យសហចុងចម្លើយទទួលស្គាល់ដើមចោទជាម្ចាស់កម្មសិទ្ធិដីមួយកន្លែងមានទំហំ ១១៣ ម៉ែត្រការេ មានក្បាលដីលេខ ១៥០ មានទីតាំងស្ថិតនៅភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ (បច្ចុប្បន្នស្ថិតនៅភូមិដីថ្មី សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ) មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ចេញដោយប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដីរាជធានីភ្នំពេញ។

ឮថា ពួកគាត់ពិតជាបានលក់ដីមួយកន្លែងដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលវត្ថុលេខ ១២០៧០៥០៦-០១៥០ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ទៅឱ្យឈ្មោះ ______ និងឈ្មោះ ______ ហើយឈ្មោះ ______ បានលក់បន្តឱ្យទៅឈ្មោះ ______ ហើយឈ្មោះ ______ បានលក់ឱ្យឈ្មោះ ______ បន្តទៀត ប៉ុន្តែខ្ញុំមិនបានដឹងច្បាស់ថាតម្លៃប៉ុន្មានទេ ហើយដីនោះក៏មិនទាន់បានកាត់ឈ្មោះផ្ទេរកម្មសិទ្ធិនៅឡើយទេ ដោយសារថាមិនសូវបានខ្វល់អំពីការផ្ទេរឈ្មោះនេះឡើយ ទើបទុករហូតមកដល់បច្ចុប្បន្ននេះ។ ដូច្នេះនៅក្នុងរឿងក្តីនេះ ខ្ញុំជាកូនរបស់អ្នកស្លាប់ដែលជាកម្មសិទ្ធិករនៃដីខាងលើ គឺយល់ព្រមផ្តិតម្រាមដៃ និងចូលរួមគ្រប់ដំណើរការនីតិវិធីផ្ទេរកម្មសិទ្ធិនៃដីខាងលើ ឱ្យទៅដើមចោទ ដោយគ្មានការជំទាស់អ្វីឡើយ និងពុំមានការបង្ខិតបង្ខំពីអ្នកណានោះឡើយ។

ចុងចម្លើយឈ្មោះ ______៖ ខ្ញុំជាកូនរបស់ឪពុកឈ្មោះ ______ និងម្តាយឈ្មោះ ______។ ម្តាយឪពុករបស់ខ្ញុំបានស្លាប់អស់ហើយកាលពីអំឡុងឆ្នាំ២០១៧ ដោយសាររោគាពាធ។ កាលគាត់នៅមានជីវិត ខ្ញុំបានដឹងឮថា ពួកគាត់ពិតជាបានលក់ដីមួយកន្លែងដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលវត្ថុលេខ ១២០៧០៥០៦-០១៥០ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ទៅឱ្យឈ្មោះ ______ និងឈ្មោះ ______ ហើយឈ្មោះ ______ បានលក់បន្តឱ្យទៅឈ្មោះ ______ ហើយឈ្មោះ ______ បានលក់ឱ្យឈ្មោះ ______ បន្តទៀត ប៉ុន្តែខ្ញុំមិនបានដឹងច្បាស់ថាតម្លៃប៉ុន្មានទេ ហើយដីនោះក៏មិនទាន់បានកាត់ឈ្មោះផ្ទេរកម្មសិទ្ធិនៅឡើយទេ ដោយសារថាមិនសូវបានខ្វល់អំពីការផ្ទេរឈ្មោះនេះឡើយ ទើបទុករហូតមកដល់បច្ចុប្បន្ននេះ។ ដូច្នេះនៅក្នុងរឿងក្តីនេះ ខ្ញុំជាកូនរបស់អ្នកស្លាប់ដែលជាកម្មសិទ្ធិករនៃដីខាងលើ គឺយល់ព្រមផ្តិតម្រាមដៃ និងចូលរួមគ្រប់ដំណើរការនីតិវិធីផ្ទេរកម្មសិទ្ធិនៃដីខាងលើ ឱ្យទៅដើមចោទ ដោយគ្មានការជំទាស់អ្វីឡើយ និងពុំមានការបង្ខិតបង្ខំពីអ្នកណានោះឡើយ។

ចុងចម្លើយឈ្មោះ ______៖ ខ្ញុំជាកូនរបស់ឪពុកឈ្មោះ ______ និងម្តាយឈ្មោះ ______។ ម្តាយឪពុករបស់ខ្ញុំបានស្លាប់អស់ហើយកាលពីអំឡុងឆ្នាំ២០១៧ ដោយសាររោគាពាធ។ កាលគាត់នៅមានជីវិត ខ្ញុំបានដឹងឮថា ពួកគាត់ពិតជាបានលក់ដីមួយកន្លែងដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលវត្ថុលេខ ១២០៧០៥០៦-០១៥០ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ទៅឱ្យឈ្មោះ ______ និងឈ្មោះ ______ ហើយឈ្មោះ ______ បានលក់បន្តឱ្យទៅឈ្មោះ ______ ហើយឈ្មោះ ______ បានលក់ឱ្យឈ្មោះ ______ បន្តទៀត ប៉ុន្តែខ្ញុំមិនបានដឹងច្បាស់ថាតម្លៃប៉ុន្មានទេ ហើយដីនោះក៏មិនទាន់បានកាត់ឈ្មោះផ្ទេរកម្មសិទ្ធិនៅឡើយទេ ដោយសារថា មិនសូវបានខ្វល់អំពីការផ្ទេរឈ្មោះនេះឡើយ ទើបទុករហូតមកដល់បច្ចុប្បន្ននេះ។ ដូច្នេះក្នុងរឿងក្តីនេះ ខ្ញុំជាកូនរបស់អ្នកស្លាប់ដែលជាកម្មសិទ្ធិករនៃដីខាងលើ គឺយល់ព្រមផ្តិតម្រាមដៃ និងចូលរួមគ្រប់ដំណើរការនីតិវិធីផ្ទេរកម្មសិទ្ធិនៃដីខាងលើ ឱ្យទៅដើមចោទ ដោយគ្មានការជំទាស់អ្វីឡើយ និងពុំមានការបង្ខិតបង្ខំពីអ្នកណានោះឡើយ។

ចំណុចវិវាទ៖ គ្មាន។

តុលាការបានបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនៅវេលាម៉ោង ៣ និង ៤០ នាទី រសៀល នាថ្ងៃខែឆ្នាំដដែល ហើយតុលាការបានកំណត់កាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៅពេលក្រោយ ហើយធ្វើការកោះហៅភាគីនៅពេលក្រោយ។

**ដើមចោទ** **សហចុងចម្លើយ** **ក្រឡាបញ្ជី** **ចៅក្រម**



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាខណ្ឌឫស្សីកែវ**
សាលាសង្កាត់...ភ្នំពេញថ្មី

## លិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និង ផ្ទះសម្បែង

លេខៈ ០១ ខ្ញុំបាទ -នាងខ្ញុំឈ្មោះ.....[redacted]......................ភេទ...........អាយុ...........ឆ្នាំ សញ្ជាតិខ្មែរ
មុខរបរ...........................ប្ដី-ប្រពន្ធឈ្មោះ...........................អាយុ...........ឆ្នាំ សញ្ជាតិខ្មែរ
មុខរបរ...........................មានទីលំនៅផ្ទះលេខ...........................ផ្លូវលេខ...........ភូមិ...........
ឃុំ-សង្កាត់...ភ្នំពេញថ្មី...........ស្រុក-ខណ្ឌ...ឫស្សីកែវ...........ខេត្ត-ក្រុង ....ភ្នំពេញ........ ។

**ផ្ទេរសិទ្ធិកាន់កាប់**

ប្រភេទដី...........ឡូត៍លេខ...........................មួយកន្លែងស្ថិតក្នុងភូមិ...........................
ឃុំ-សង្កាត់...ភ្នំពេញថ្មី.......ស្រុក-ខណ្ឌ.....ឫស្សីកែវ.....ខេត្ត-ក្រុង...ភ្នំពេញ......... ។ ដីមានទំហំ
...........................និងព្រំប្រទល់...........................................................
...........................................................................................
ដែលធ្លាប់កាន់កាប់ និង ប្រើប្រាស់តាំងពីឆ្នាំ.......................មកដល់សព្វថ្ងៃនេះមានបង្កាន់ដៃលេខ.................
ចុះថ្ងៃទី.......................អោយទៅឈ្មោះ...[redacted]...ភេទ...........អាយុ...........ឆ្នាំ សញ្ជាតិខ្មែរ
មុខរបរ...........................ប្ដី-ប្រពន្ធឈ្មោះ...[redacted]...អាយុ...........ឆ្នាំ សញ្ជាតិខ្មែរ
មុខរបរ...........................មានទីលំនៅផ្ទះលេខ...........................ផ្លូវលេខ...........ភូមិ...........
ឃុំ-សង្កាត់...........................ស្រុក-ខណ្ឌ....ឫស្សីកែវ...........ខេត្ត-ក្រុង.........ភ្នំពេញ.........
ដើម្បីកាន់កាប់ និងប្រើប្រាស់តទៅ ។

ខ្ញុំបាទ-នាងខ្ញុំជាម្ចាស់ដីសូមសន្យា ទទួលខុសត្រូវចំពោះមុខច្បាប់ ។

**អ្នកផ្ទេរ** **អ្នកទទួល** **សាក្សី**

[redacted] [redacted] [redacted] [redacted] [redacted]

លេខ..................
បានឃើញ និង បញ្ជាក់ថា
ហត្ថលេខាខាងស្ដាំនេះពិតជាហត្ថលេខារបស់
លោក.........................................
ចៅសង្កាត់...............................ប្រាកដមែន ។
ឫស្សីកែវ. ថ្ងៃទី..........ខែ.............ឆ្នាំ២០០.....
**អភិបាលខណ្ឌឫស្សីកែវ**

លេខ.............
បានឃើញ និង បញ្ជាក់ថា
ស្នាមមេដៃខាងលើនេះពិតជាស្នាមមេដៃរបស់
ឈ្មោះ[redacted].........
[redacted]
បានផ្ដិតមេដៃចំពោះមុខយើង ។
ភ្នំពេញ.ថ្ងៃទី.........ខែ.........ឆ្នាំ២០០.៥.
ចៅសង្កាត់...ភ្នំពេញថ្មី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## លិខិតធានាអះអាង

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ.................................ភេទ ប្រុស អាយុ ៥២ ឆ្នាំ សញ្ជាតិ ខ្មែរ អត្តសញ្ញាណប័ណ្ណលេខ ១១៥៨៧៤ [illegible] និង ឈ្មោះ ហ៊ុល សាំ អាយុ ៥៥ ឆ្នាំ សញ្ជាតិ ខ្មែរ អត្តសញ្ញាណប័ណ្ណលេខ ១១៧៤៨១ [illegible] មានទីលំនៅផ្ទះលេខ.............. ក្រុម.............. ភូមិ [illegible] សង្កាត់ ភ្នំពេញថ្មី ខណ្ឌ ឫស្សីកែវ ក្រុង ភ្នំពេញ

## សូមធានាអះអាង

ចំពោះដី សំណង់ មួយកន្លែងដែលមានទំហំ...................................................... ស្ថិតនៅភូមិ [illegible] សង្កាត់ ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ ដែលបានផ្ទេរសិទ្ធកាន់កាប់ប្រើប្រាស់ដីធ្លីអោយទៅឈ្មោះ.............................. និង ឈ្មោះ..............................កាន់កាប់បន្តនោះពិតជាពុំអោនប័ណ្ណសំគាល់សិទ្ធ កាន់កាប់អចលនៈវត្ថុ . ពុំមានការដាក់ជូល-ដាក់បញ្ចាំ . ឬ ធ្វើអំណោយទានទៅជនណាមួយ ពុំពាក់ព័ន្ធទំនាស់ ឬ ដីការហាមឃាត់របស់តុលាការ និង ពុំពាក់ព័ន្ធដីសាធារណៈដែលរដ្ឋហាមឃាត់ឡើយ ។

ក្រែងពុំប្រាកដខ្ញុំបាទ-នាងខ្ញុំ សូមទទួលខុសត្រូវទាំងស្រុងសំពោះមុខច្បាប់ និង ផ្តិតមេដៃស្តាំទុកជាចំណាំ ។

ធ្វើនៅ ឫស្សីកែវ .ថ្ងៃទី ២០ ខែ ០១ ឆ្នាំ ២០០៩

ស្នាមមេដៃ

ប្តី ប្រពន្ធ

លេខ ០៣៣ លប

បានឃើញ និង បញ្ជាក់ថា

ឈ្មោះ.......................................

.......................................

ពិតជាបានផ្តិតមេដៃស្តាំចំពោះមុខយើងចៅសង្កាត់ព្រាកដមែន ។

ឫស្សីកែវ . ថ្ងៃទី ២៤ ខែ ០១ ឆ្នាំ ២០០៩

ចៅសង្កាត់

ម៉ុំ សាវឿន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**កិច្ចសន្យា**

ខ្ញុំបាទឈ្មោះ ............................ ភេទ ប្រុស អាយុ ...... ឆ្នាំ សញ្ជាតិ ខ្មែរ ......

មុខរបរ ......................................................................

ប្រពន្ធឈ្មោះ ...................... អាយុ ...... ឆ្នាំ សញ្ជាតិ ខ្មែរ ...... មុខរបរ ......

មានទីលំនៅផ្ទះលេខ ............ ផ្លូវលេខ ............ ក្រុមទី ............ ភូមិ ............ សង្កាត់ ............

ខណ្ឌ ...................... ក្រុង ...................... ។

**សូមចុះកិច្ចសន្យា**

ចំពោះដី ............................................ មួយកន្លែងទំហំ ............................................ ស្ថិតនៅ

ភូមិ ............................ សង្កាត់ ............................ ខណ្ឌឬស្សីកែវ ដែលបានកាន់កាប់ទទួលបន្តពី

ឈ្មោះ ............................ ប្រពន្ធឈ្មោះ ............................ នេះ ខ្ញុំបាទ / នាងខ្ញុំ និង បំពេញ

បែបបទ សុំធ្វើប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនៈវត្ថុ ដើម្បីបានកាន់កាប់ស្របច្បាប់ជាពរមាន ។

នៅថ្ងៃអនាគតពេលរាជរដ្ឋាភិបាលរៀបចំអភិវឌ្ឍន៍ហើយប៉ះពាល់ដល់ដីនោះ ខ្ញុំបាទ/នាងខ្ញុំគោរពតាមគោលការដោយឥតលក្ខណ្ឌនិង

ពុំទាមទារសំណងអ្វីពីរាជរដ្ឋាភិបាលឡើយ ។

ក្នុងករណីដែលពុំអនុវត្តន៍ តាមកិច្ចសន្យាខាងលើនោះ ខ្ញុំបាទ/នាងខ្ញុំ សូមទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ ។

ក្រៅពុំពិតប្រាកដខ្ញុំបាទនាងខ្ញុំសូមផ្តិតមេដៃស្តាំលើកិច្ចសន្យានោះ ។

................ ថ្ងៃទី ...... ខែ ...... ឆ្នាំ២០០...

**ស្នាមមេដៃ**

...............

លេខ ............

**បានឃើញ និង បញ្ជាក់ថា**

ឈ្មោះ ............................

............................

ពិតជាបានផ្តិតមេដៃស្តាំចំពោះមុខយើងចៅសង្កាត់

ប្រាកដមែន ។

.............. ថ្ងៃទី ...... ខែ ...... ឆ្នាំ ២០០...

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**កំណត់ហេតុ**

ស្តីពីការចុះពិនិត្យ ដី-ធ្លី របស់ឈ្មោះ [redacted]

ឆ្នាំ [illegible] ខែ មករា ...... ថ្ងៃទី [illegible] ...... វេលាម៉ោង [illegible] ......

យើង [illegible] ...... មេភូមិ [illegible] ...... សង្កាត់ ភ្នំពេញថ្មី ដោយមានការចូលរួម:

១/លោក: ...... មុខងារ......

២/លោក: ...... មុខងារ......

បានចុះពិនិត្យទីតាំងដី-ធ្លីរបស់ឈ្មោះ [illegible] ...... ភេទ [illegible] ...... អាយុ [illegible] ...... ឆ្នាំ សញ្ជាតិ ខ្មែរ

មានបង្កាន់ដៃដាក់ពាក្យសុំកាន់កាប់ប្រើប្រាស់ដី-ធ្លីលេខ...... ចុះថ្ងៃទី......

ដែលបានផ្ទេរអោយឈ្មោះ [redacted] ...... ភេទ [illegible] ...... អាយុ [illegible] ...... ឆ្នាំ សញ្ជាតិ ខ្មែរ

ប្តី/ប្រពន្ធឈ្មោះ [redacted] ភេទ...... អាយុ [illegible] ឆ្នាំ សញ្ជាតិ ខ្មែរ ឃើញថាជាប្រភេទដី [illegible] ......

មានទំហំ: ...... ជាអក្សរ: ...... ។

**ព្រំប្រទល់**

- ខាងជើងទល់នឹង [illegible] ......
- ខាងត្បូងទល់នឹង [illegible] ......
- ខាងកើតទល់នឹង [illegible] ......
- ខាងលិចទល់នឹង [illegible] ......

សូមបញ្ជាក់ថា : ដីនេះពុំមានពាក់ពន្ធ័ះលើការហាមឃាត់របស់រដ្ឋ ឬ មានជំលោះអ្វីឡើយ ( ជូនភ្ជាប់ជាមួយគំនូសប្លង់បង្ហាញទីតាំង)

កំណត់ហេតុនេះបានបញ្ចប់នៅវេលាម៉ោង [illegible] ...... នាថ្ងៃខែឆ្នាំដដែល ដោយមានការចូលរួប ទទួលស្គាល់ព្រំដីរបស់អ្នកជាប់ព្រំប្រទល់ និង បានផ្តិតមេដៃស្តាំ ឯកភាព ក្នុងកំណត់ហេតុនេះផងដែរ ។

**ស្នាមមេដៃអ្នកចូលរួម**

[redacted] [redacted] [redacted] [redacted]

**ស្នាមមេដៃអ្នកជាប់ព្រំ**

**ស្នាមមេដៃមេភូមិ**

[redacted]

**បានឃើញ និង ឯកភាព**

ភ្នំពេញថ្មី. ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

ចៅសង្កាត់ភ្នំពេញថ្មី

[illegible]

# គំណត់បង្ហាញពីភាគដីរបស់ឈ្មោះ

លោក...[redacted]..............ប្រពន្ធ......[redacted]..............

ផ្ទេរអោយទៅឈ្មោះ [redacted].....ឈ្មោះ...[redacted]ក......ម៉ប់...........................

មានបង្កាន់ដៃកាន់កាប់ដីធ្លីលេខ:.........................................ចុះថ្ងៃទី..............................

ស្ថិតនៅក្នុងផ្លូវទី ៣.ភូមិ..............សង្កាត់ ភ្នំពេញថ្មី ខណ្ឌ ឫស្សីកែវ រាជធានីភ្នំពេញ។







## ស្នាមមេដៃទទួលខុសត្រូវ

អ្នកលក់ អ្នកទិញ



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ការិយាល័យមេធាវី កច្ចាយនៈ**
**KACHAYANAK LAW OFFICE**
大诚国际合作律师事务所
លេខៈ 001/23 ស.ច.ក

សាលាដំបូងរាជធានីភ្នំពេញ
ចូល លេខ ៣៤០០
ថ្ងៃទី ២៣ ខែ ០៣ ឆ្នាំ ២០២៣
ម៉ោង ១០ និង ១០ នាទី

## សេចក្តីថ្លែងការណ៍

ខ្ញុំមេធាវី **សូ សុវណ្ណារិទ្ធ** អត្តលេខ **២០៧៦** ជាសមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា មានការិយាល័យ**មេធាវីកច្ចាយនៈ (KACHAYANAK LAW OFFICE)** មានទីតាំងស្ថិតនៅផ្ទះលេខ R4-3960 ផ្លូវរុងរឿង៤ (បុរីរុងរឿងក្នុងតំបន់អភិវឌ្ឍន៍ទីក្រុងជ្រោយចង្វារ) សង្កាត់ព្រែកលាប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ជាមេធាវីតំណាងដោយអាណត្តិឱ្យឈ្មោះ [redacted] និងឈ្មោះ [redacted] ។

**សូមគោរពចូលមក**
**ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ:** សំណើជូនសេចក្តីថ្លែងការណ៍ ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ១៧២០ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ

**យោង:** -ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ។
-សំណុំរឿងរដ្ឋប្បវេណីលេខ ១៧២០ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមធ្វើសេចក្តីថ្លែងការណ៍ជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបដូចតទៅ ៖

### I. អំពីអង្គហេតុ

កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩ ឈ្មោះ ឯក កុល និងប្រពន្ធឈ្មោះ ហ៊ុល ណាំ បានលក់ដីមួយកន្លែងមានទំហំ ១១៣ម²(មួយរយដប់បីម៉ែត្រការ៉េ) មានក្បាលដីលេខ ១៥០ មានទីតាំងស្ថិតនៅភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ (បច្ចុប្បន្នស្ថិតនៅភូមិដីថ្មី សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ) មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ចេញដោយប្រធានមន្ទីររៀបចំដែនដីនគររូបនីយកម្មសំណង់ និងសុរិយោដីរាជធានីភ្នំពេញ មកឱ្យឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted] ដោយបានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខ ០៣៤ លប ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩ ចេញដោយចៅសង្កាត់ភ្នំពេញថ្មី ។ ក្រោយមកនៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០ ឈ្មោះ [redacted] និងប្រពន្ធបានព្រមព្រៀងលក់ដីខាងលើមកឱ្យឈ្មោះ កៅ ពឿន ដោយបានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែង លេខ ១១៨ លប ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០ ចេញដោយចៅសង្កាត់ភ្នំពេញថ្មី ហើយបន្ទាប់មកទៀតទើបឈ្មោះ [redacted] បានលក់ដីខាងលើមកឱ្យកូនក្តីខ្ញុំនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ដែល

ផ្ទះលេខ R4-3960 ផ្លូវរុងរឿង៤ (បុរីរុងរឿងក្នុងតំបន់អភិវឌ្ឍន៍ទីក្រុងជ្រោយចង្វារ) សង្កាត់ព្រែកលាប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ kachayanak168@gmail.com
#R4-3960, St.4 (Rong Roeurng), Sangkat Prek Leab, Khan Chroy Changvar, Phnom Penh, Cambodia. 089 606 860 / 070 606 860 / 060 606 860

មានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែង លេខ ១៧៤៨ លប ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ចេញដោយចៅសង្កាត់ភ្នំពេញថ្មី ។

បន្ទាប់ពីបានទទួលកម្មសិទ្ធិលើដីខាងលើកូនក្តីខ្ញុំឈ្មោះ [redacted] និងប្រពន្ធ [redacted] បានគ្រប់គ្រង ប្រើប្រាស់ និងអាស្រ័យផលជាលើដីនេះរហូតមកដល់សព្វថ្ងៃ ប៉ុន្តែនៅអំឡុងឆ្នាំ២០២២ នេះកូនក្តីខ្ញុំមានបំណងផ្ទេរសិទ្ធិកម្មសិទ្ធិក្នុងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ចេញដោយប្រធានមន្ទីររៀបចំដែនដីនគររូបនីយកម្មសំណង់ និងសុរិយោដី រាជធានីភ្នំពេញ មានឈ្មោះខ្លួនជាម្ចាស់កម្មសិទ្ធិនោះ មិនទាន់អាចធ្វើបាននៅឡើយដោយហេតុថា ឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted] ដែលមានឈ្មោះ ជាម្ចាស់កម្មសិទ្ធិក្នុងវិញ្ញាបនបត្រខាងលើ បានទទួលមរណភាព មិនទាន់បានចូលខ្លួនមកបំពេញបែបបទ នៅចំពោះមុខមន្ត្រីសុរិយោដី ដើម្បីផ្ទេរសិទ្ធិកម្មសិទ្ធិមកឱ្យកូនក្តីខ្ញុំឈ្មោះ [redacted] និងឈ្មោះ [redacted] ជាម្ចាស់កម្មសិទ្ធិនៅឡើយ ។ ឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted] មានកូនទាំងអស់ចំនួន ០៤នាក់(បួន) ដែលជាសហចុងចម្លើយទាំងអស់ ។

ក្រោយពីកូនក្តីខ្ញុំបានដាក់ពាក្យបណ្តឹងទៅសាលាដំបូងរាជធានីភ្នំពេញរួចមក សហចុងចម្លើយទាំងអស់បានបញ្ជាក់ចំពោះឆន្ទះរបស់ខ្លួនថា "មិនមានការប្រកែកតវ៉ាចំពោះតុលាការដែលសម្រេចឱ្យកូនក្តីខ្ញុំជាម្ចាស់កម្មសិទ្ធិលើដីខាងលើឡើយ" ។ មិនតែប៉ុណ្ណោះក៏មានពាក្យសុំចូលជួយអន្តរាគមន៍របស់ឈ្មោះ [redacted] និងឈ្មោះ [redacted] ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៣ ដែលមានខ្លឹមសារ "សុំចូលរួមអន្តរាគមន៍ដល់ភាគីដើមចោទឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted] ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ១៧២០ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ ដោយសំណូមពរឱ្យតុលាការសម្រេច តាមខ្លឹមសារដែលទាមទារដោយដើមចោទឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted] ទាំងស្រុង" ។

## II <u>អង្គច្បាប់</u>

១,. មាត្រា ៤៣ នៃក្រមរដ្ឋប្បវេណី "ការចូលរួមជួយអន្តរាគមន៍" ។

២,. មាត្រា ៤៤ នៃក្រមរដ្ឋប្បវេណី "ពាក្យសុំចូលរួមជួយអន្តរាគមន៍" ។

## III <u>សំណូមពរ</u>

ក្នុងនាមខ្ញុំជាមេធាវីតំណាងដោយអាណត្តិដើមចោទឈ្មោះ ឈ្មោះ [redacted] និងឈ្មោះ [redacted] សូមសុំណូមពរដូចខាងក្រោម ៖

១.បង្គាប់ឱ្យសហចុងចម្លើយទទួលស្គាល់ដើមចោទជាម្ចាស់កម្មសិទ្ធិដីមួយកន្លែង មានទំហំ ១១៣ម²(មួយរយដប់បីម៉ែត្រការ៉េ) មានក្បាលដីលេខ ១៥០ មានទីតាំងស្ថិតនៅភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ (បច្ចុប្បន្នស្ថិតនៅភូមិដីថ្មី សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ) មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ចេញដោយប្រធានមន្ទីររៀបចំដែនដីនគររូបនីយកម្មសំណង់ និងសុរិយោដីរាជធានីភ្នំពេញ ។

២.បង្គាប់ឲ្យចុងចម្លើយបំពេញបែបបទ នៅចំពោះមុខមន្ត្រីសុរិយោដី តាមនីតិវិធីច្បាប់ ដើម្បីផ្ទេរសិទ្ធិកម្មសិទ្ធិវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ មកឲ្យដើមចោទ ។

៣.បង្គាប់ឲ្យមន្ត្រីសុរិយោដី និងអាជ្ញាធរពាក់ព័ន្ធ បំពេញបែបបទតាមនីតិវិធីច្បាប់ ដើម្បីផ្ទេរសិទ្ធិកម្មសិទ្ធិវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ មកឲ្យដើមចោទជាម្ចាស់កម្មសិទ្ធិ ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យ និងសម្រេចតាមច្បាប់ជូនកូនក្តីខ្ញុំ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពរាប់អានអំពីខ្ញុំ ។

រាជធានីភ្នំពេញ,ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣

**ហត្ថលេខា**

មេធាវី ស៊្វូ_សុវណ្ណារិទ្ធ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងរាជធានីភ្នំពេញ**

សំណុំរឿងរដ្ឋប្បវេណីលេខ ១៧២០

ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២

## កំណត់ហេតុស្ដីពី
## នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

សញ្ញាណនៃរឿងក្ដី៖ ប្ដឹងសុំសាលក្រមទទួលស្គាល់ជាម្ចាស់កម្មសិទ្ធិដី

កាលបរិច្ឆេទ៖ ពីរពាន់ម្ភៃបី ខែឧសភា ថ្ងៃទីបី វេលាម៉ោង ៩ និង ១០ នាទី ព្រឹក

ទីកន្លែង៖ បន្ទប់ "ថ" ជាន់ទី៤ នៃសាលាដំបូងរាជធានីភ្នំពេញ

**ដោយមានសមាសភាព**

លោកស្រី **ឈុន ដាទី** ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោកស្រី **ម៉ុម សៀកលីម** ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ភាគីមាន

**អ្នកតំណាងដោយអាណត្តិ** លោកមេធាវី **សូ សុវណ្ណរិទ្ធ** អត្តលេខ២០៧៦ **មានការិយាល័យមេធាវី កច្ចាយន:** (KACHAYANAK LAW OHHICE) មានអាសយដ្ឋានផ្ទះលេខ R4-3960 ផ្លូវរុងរឿង៤ (បុរីរុងរឿងក្នុងតំបន់អភិវឌ្ឍន៍ទីក្រុងជ្រោយចង្វារ) សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ជាអ្នកតំណាងដោយអាណត្តិឱ្យសហដើមចោទឈ្មោះ និងឈ្មោះ ។

**១. ខ្លឹមសារនៃសាលក្រមដែលដើមចោទបានទាមទារ**

ក-បង្គាប់ឱ្យសហចុងចម្លើយទទួលស្គាល់ដើមចោទជាម្ចាស់កម្មសិទ្ធិដីមួយកន្លែងមានទំហំ ១១៣ ម៉ែត្រការេ ដែលមានក្បាលដីលេខ ១៥០ មានទីតាំងស្ថិតនៅភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ (បច្ចុប្បន្នស្ថិតនៅភូមិដីថ្មី សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ) មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ចេញដោយប្រធានមន្ទីររៀបចំដែនដីនគររូបនីយកម្មសំណង់ និងសុរិយោដីរាជធានីភ្នំពេញ។

ខ-បង្គាប់ឱ្យសហចុងចម្លើយបំពេញបែបបទនៅចំពោះមុខមន្ត្រីសុរិយោដីតាមនីតិវិធីច្បាប់ ដើម្បីផ្ទេរកម្មសិទ្ធិវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ មកឱ្យ ដើមចោទ

គ-បង្គាប់ឱ្យមន្ត្រីសុរិយោដី និងអាជ្ញាធរពាក់ព័ន្ធបំពេញបែបបទតាមនីតិវិធីច្បាប់ ដើម្បីផ្ទេរសិទ្ធិកម្មសិទ្ធិវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ មកឱ្យដើមចោទជាកម្មសិទ្ធិករ។

**២-សេចក្ដីថ្លែងការណ៍របស់គូភាគី**

**អ្នកតំណាងដោយអាណត្តិឱ្យសហដើមចោទ** បានថ្លែងការណ៍ថា៖ ខ្ញុំបាទសូមរក្សាខ្លឹមសារនៃពាក្យបណ្ដឹងចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ និងសេចក្ដីថ្លែងការណ៍នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុកាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២ និងកាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ ទុកជាបានការដដែល។ ខ្ញុំបាទសូមបញ្ជាក់ថា កាលពីថ្ងៃទី២០

ខែមករា ឆ្នាំ២០០៩ ឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted] បានលក់ដី១កន្លែង មានទំហំ ១១៣ (មួយរយដប់បី) ម៉ែត្រការេ មានក្បាលដីលេខ ១៥០ មានទីតាំងស្ថិតនៅភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ (បច្ចុប្បន្នស្ថិតនៅភូមិដីថ្មី សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ) ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ចេញដោយប្រធានមន្ទីររៀបចំដែនដីនគររូបនីយកម្មសំណង់ និងសុរិយោដីរាជធានីភ្នំពេញ មកឱ្យឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted] ដោយបានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខ ០៣៤ លប ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩ ចេញដោយចៅសង្កាត់ភ្នំពេញថ្មី។ ក្រោយមកនៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០ ឈ្មោះ [redacted] និងប្រពន្ធបានព្រមព្រៀងលក់ដីខាងលើមកឱ្យឈ្មោះ [redacted] ដោយបានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខ ១១៨ លប ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០ ចេញដោយចៅសង្កាត់ភ្នំពេញថ្មី ហើយបន្ទាប់មកទៀតទើបឈ្មោះ [redacted] បានលក់ដីខាងលើមកឱ្យកូនក្ដីខ្ញុំនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខ ១៧៤៨ លប ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ចេញដោយចៅសង្កាត់ភ្នំពេញថ្មី ។

បន្ទាប់ពីបានទទួលកម្មសិទ្ធិលើដីខាងលើកូនក្ដីខ្ញុំឈ្មោះ [redacted] និងប្រពន្ធ [redacted] បានគ្រប់គ្រងប្រើប្រាស់ និងអាស្រ័យផលជាលើដីនេះរហូតមកដល់សព្វថ្ងៃ ប៉ុន្តែនៅអំឡុងឆ្នាំ២០២២ កូនក្ដីខ្ញុំមានបំណងផ្ទេរសិទ្ធិកម្មសិទ្ធិក្នុងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ចេញដោយប្រធានមន្ទីររៀបចំដែនដីនគររូបនីយកម្មសំណង់ និងសុរិយោដីរាជធានីភ្នំពេញ មានឈ្មោះខ្លួនជាម្ចាស់កម្មសិទ្ធិនោះ មិនទាន់អាចធ្វើបាននៅឡើយដោយហេតុថា ឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted] ដែលមានឈ្មោះជាម្ចាស់កម្មសិទ្ធិក្នុងវិញ្ញាបនបត្រខាងលើបានទទួលមរណភាព មិនទាន់បានចូលខ្លួនមកបំពេញបែបបទ នៅចំពោះមុខមន្ត្រីសុរិយោដីដើម្បីផ្ទេរសិទ្ធិកម្មសិទ្ធិមកឱ្យកូនក្ដីខ្ញុំឈ្មោះ [redacted] និង ឈ្មោះ [redacted] ជាម្ចាស់កម្មសិទ្ធិនៅឡើយ។ ឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted] មានកូនទាំងអស់ ចំនួន ០៤នាក់(បួន) ដែលជាសហចុងចម្លើយទាំងអស់។ ក្រោយពីកូនក្ដីខ្ញុំបានដាក់ពាក្យបណ្ដឹងទៅសាលាដំបូងរាជធានីភ្នំពេញរួចមក សហចុងចម្លើយទាំងអស់ បានបញ្ជាក់ចំពោះឆន្ទៈរបស់ខ្លួនថា "មិនមានការប្រកែកតវ៉ាចំពោះតុលាការដែលសម្រេចឱ្យកូនក្ដីខ្ញុំជាម្ចាស់កម្មសិទ្ធិលើដីខាងលើឡើយ"។ មិនតែប៉ុណ្ណោះក៏មានពាក្យសុំចូលជួយអន្តរាគមន៍របស់ឈ្មោះ [redacted] និងឈ្មោះ [redacted] ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៣ ដែលមានខ្លឹមសារ "សុំចូលរួមអន្តរាគមន៍ដល់ភាគីដើមចោទឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted] ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ១៧២០ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ ដោយសំណូមពរឱ្យតុលាការសម្រេច តាមខ្លឹមសារដែលទាមទារដោយ ដើមចោទឈ្មោះ [redacted] និងប្រពន្ធឈ្មោ [redacted] ទាំងស្រុង"។ ក្នុងនាមខ្ញុំបាទជាអ្នកតំណាងដោយអាណត្តិឱ្យសហដើមចោទ សូមសំណូមពរដូចខាងក្រោម៖

១.បង្គាប់ឱ្យសហចុងចម្លើយទទួលស្គាល់ដើមចោទជាម្ចាស់កម្មសិទ្ធិដីមួយកន្លែង មានទំហំ ១១៣ (មួយរយដប់បី) ម៉ែត្រការ៉េ មានក្បាលដីលេខ ១៥០ មានទីតាំងស្ថិតនៅភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ (បច្ចុប្បន្នស្ថិតនៅភូមិដីថ្មី សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ ) មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ចេញដោយប្រធានមន្ទីររៀបចំដែនដីនគររូបនីយកម្មសំណង់ និងសុរិយោដីរាជធានីភ្នំពេញ ។

២.បង្គាប់ឱ្យចុងចម្លើយបំពេញបែបបទនៅចំពោះមុខមន្ត្រីសុរិយោដី តាមនីតិវិធីច្បាប់ ដើម្បីផ្ទេរសិទ្ធិកម្មសិទ្ធិ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ មកឱ្យ ដើមចោទ ។

៣.បង្គាប់ឱ្យមន្ត្រីសុរិយោដី និងអាជ្ញាធរពាក់ព័ន្ធបំពេញបែបបទទៅតាមនីតិវិធីច្បាប់ ដើម្បីផ្ទេរសិទ្ធិកម្មសិទ្ធិ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ មកឱ្យដើមចោទជាម្ចាស់កម្មសិទ្ធិ។

**សហចុងចម្លើយ៖** អវត្តមាន ដោយតុលាការបានធ្វើការកោះហៅសហចុងចម្លើយឱ្យចូលរួមតាមកាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ តាមដីកាកោះត្រឹមត្រូវតាមនីតិវិធីបណ្តឹង តែសហចុងចម្លើយអវត្តមាន។

តុលាការបានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៅវេលាម៉ោង ៩ និង ៣០ នាទី ព្រឹក នាថ្ងៃខែឆ្នាំដដែល ហើយតុលាការបានកំណត់កាលបរិច្ឆេទនៃការប្រកាសសាលក្រមនៅពេលក្រោយ។

| អ្នកតំណាងដោយអាណត្តិឱ្យដើមចោទ | ក្រឡាបញ្ជី | ចៅក្រម |
|---|---|---|

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមរដ្ឋប្បវេណី**

លេខ ៥០៧ "ផ"

ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣

សំណុំរឿងរដ្ឋប្បវេណីលេខ ១៧២០

ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃពុធ ១៤កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៣ លើសំណុំរឿងរដ្ឋប្បវេណីលេខ ១៧២០ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ ដោយមានសមាសភាព៖

**ចៅក្រមជំនុំជម្រះ**

លោកស្រី **ឈុន ដាវី** ជាចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី**

លោកស្រី **ម៉ុង សៀកលីង** ជាក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**សមាដើមចោទ**

១-ឈ្មោះ ភេទប្រុស កើតថ្ងៃទី០២ ខែមីនា ឆ្នាំ១៩៨៧ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០២០៩៩៨៥៨៩០ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៣ មានទីលំនៅបច្ចុប្បន្ននៅផ្លូវលំ ភូមិដីថ្មី សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

២-ឈ្មោះ ភេទស្រី កើតថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨៨ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១១៣៣៦៣២១ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩ មានទីលំនៅបច្ចុប្បន្ននៅផ្លូវលំ ភូមិដីថ្មី សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

**អ្នកតំណាងដោយអាណត្តិ** លោកមេធាវី **ស្វ សុវណ្ណរិទ្ធ** អត្តលេខ ២០៧៦ មានការិយាល័យមេធាវី កច្ចាយនៈ (KACHAYANAK LAW OHHICE) មានអាសយដ្ឋានផ្ទះលេខ R4-3960 ផ្លូវរុងរឿង៤ (បុរីរុងរឿងក្នុងតំបន់អភិវឌ្ឍន៍ទីក្រុងជ្រោយចង្វារ) សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

**អ្នកចូលរួមជួយអន្តរាគមន៍ក្នុងបណ្តឹង**

១-ឈ្មោះ ភេទប្រុស អាយុ៤៧ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅផ្លូវលេខ១២៥ សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ ។

២-ឈ្មោះ ភេទប្រុស អាយុ៤៤ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១០៤៤២៨១ (០១) ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ ២៣០អ៊ី១ ផ្លូវលេខ៥៩៨ ភូមិសេរប៉េសេ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

**សមាចុងចម្លើយ**

១-ឈ្មោះ ភេទស្រី កើតឆ្នាំ១៩៨៤ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិដីថ្មី សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

២-ឈ្មោះ ភេទស្រី អាយុ៦៩ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

៣-ឈ្មោះ  ភេទស្រី អាយុ៦៥ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅសង្កាត់ស្ពានខណ្ឌដូនពេញ រាជធានីភ្នំពេញ។

៤-ឈ្មោះ  ភេទស្រី កើតឆ្នាំ១៩៧១ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ២១ ផ្លូវបេតុង ភូមិដីថ្មី សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

## I. **អង្គហេតុ និងចំណុចវិវាទ**

### **១-ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ**

ក-បង្គាប់ឱ្យសហចុងចម្លើយទទួលស្គាល់ដើមចោទជាម្ចាស់កម្មសិទ្ធិដីមួយកន្លែង ដែលមានទំហំ ១១៣ ម៉ែត្រការេ មានក្បាលដីលេខ ១៥០ មានទីតាំងស្ថិតនៅភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ (បច្ចុប្បន្នស្ថិតនៅភូមិដីថ្មី សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ) មានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ចេញដោយប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដីរាជធានីភ្នំពេញ។

ខ-បង្គាប់ឱ្យសហចុងចម្លើយបំពេញបែបបទនៅចំពោះមុខមន្ត្រីសុរិយោដីតាមនីតិវិធីច្បាប់ ដើម្បីផ្ទេរកម្មសិទ្ធិវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ មកឱ្យដើមចោទ

គ-បង្គាប់ឱ្យមន្ត្រីសុរិយោដី និងអាជ្ញាធរពាក់ព័ន្ធបំពេញបែបបទតាមនីតិវិធីច្បាប់ដើម្បីផ្ទេរសិទ្ធិកម្មសិទ្ធិវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ មកឱ្យដើមចោទ ជាកម្មសិទ្ធិករ។

### **២-ការពន្យល់ត្រួសៗអំពីរឿងក្តី**

កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩ ឈ្មោះ  និងប្រពន្ធឈ្មោះ  បានលក់ដីមួយកន្លែង មានទំហំ ១១៣ (មួយរយដប់បី) ម៉ែត្រការេ មានក្បាលដីលេខ ១៥០ មានទីតាំងស្ថិតនៅភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ (បច្ចុប្បន្នស្ថិតនៅភូមិដីថ្មី សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ) ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ចេញដោយប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដីរាជធានីភ្នំពេញ មកឱ្យឈ្មោះ  និងប្រពន្ធឈ្មោះ  ដោយធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខ ០៣៤ លប ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩ ចេញដោយចៅសង្កាត់ភ្នំពេញថ្មី ។ ក្រោយមកនៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០ ឈ្មោះ  និងឈ្មោះ  បានព្រមព្រៀងលក់ដីខាងលើមកឱ្យឈ្មោះ  ដោយ បានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខ ១១៨ លប ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០ ចេញ ដោយចៅសង្កាត់ភ្នំពេញថ្មី ហើយបន្ទាប់មកទៀតទើបឈ្មោះ  បានលក់ដីខាងលើមកឱ្យដើមចោទនៅថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០១៦ មានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខ ១៧៤៨ លប ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០១៦ ចេញដោយចៅសង្កាត់ភ្នំពេញថ្មី ។

បន្ទាប់ពីបានទទួលកម្មសិទ្ធិលើដីខាងលើ ដើមចោទបានគ្រប់គ្រង ប្រើប្រាស់ និងអាស្រ័យផលជាលើដីនេះរហូតមកដល់សព្វថ្ងៃប៉ុន្តែនៅអំឡុងឆ្នាំ២០២២ នេះដើមចោទមានបំណងផ្ទេរសិទ្ធិកម្មសិទ្ធិក្នុងវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ចេញដោយប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដី រាជធានីភ្នំពេញ មានឈ្មោះខ្លួនជាម្ចាស់កម្មសិទ្ធិនោះ

មិនទាន់អាចធ្វើបាននៅឡើយដោយហេតុថា ឈ្មោះ និងប្រពន្ធឈ្មោះ ដែលមានឈ្មោះជាម្ចាស់កម្ម សិទ្ធិក្នុងវិញ្ញាបនប័ត្រខាងលើ បានទទួលមរណភាព មិនទាន់បានចូលខ្លួនមកបំពេញបែបបទ នៅចំពោះមុខមន្ត្រីសុរិយោដី ដើម្បីផ្ទេរសិទ្ធិកម្មសិទ្ធិមកឱ្យដើមចោទជាម្ចាស់កម្មសិទ្ធិនៅឡើយ ។ឈ្មោះ និងប្រពន្ធឈ្មោះ មានកូនទាំងអស់ចំនួន ០៤នាក់(បួន) ដែលជាសហចុងចម្លើយទាំងអស់។ ដើម្បីអាចឱ្យដើមចោទ ទទួលបានសិទ្ធិ ជាម្ចាស់កម្មសិទ្ធិលើដីទំហំ ១១៣ (មួយរយដប់បី) ម៉ែត្រការេ មានក្បាលដីលេខ ១៥០ មានទីតាំងស្ថិតនៅភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ (បច្ចុប្បន្នស្ថិតនៅភូមិដីថ្មី សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ) មានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ចេញដោយប្រធានមន្ទីររៀបចំដែនដីនគររូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ។

**៣-ការអះអាងរបស់គូភាគី**

**៣.១-ការអះអាងរបស់សហដើមចោទ និងអ្នកតំណាងដោយអាណត្តិ**

**ដើមចោទឈ្មោះ និងឈ្មោះ បានធ្វើសេចក្តីថ្លែងការណ៍ក្នុងនីតិវិធីត្រៀម**សម្រាប់ការទាញហេតុផលថា៖ កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០០៨ ឈ្មោះ និងប្រពន្ធឈ្មោះ បានលក់ពីមួយកន្លែង មានទំហំ ១១៣ ម៉ែត្រការេ មានក្បាលលេខ ១៥០ មានទីតាំងស្ថិតនៅភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ (បច្ចុប្បន្នស្ថិតនៅភូមិដីថ្មី សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានី ភ្នំពេញ) មានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ដោយប្រធានមន្ទីររៀបចំដែនដីនគររូបនីយកម្មសំណង់ និងសុរិយោដីរាជធានីភ្នំពេញ មកឱ្យឈ្មោះ និងប្រពន្ធឈ្មោះ ដោយបានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខ ០៣៣ លប ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩ ចេញដោយចៅសង្កាត់ភ្នំពេញថ្មី។ ក្រោយមកនៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០ ឈ្មោះ និងឈ្មោះ បានព្រមព្រៀងលក់នោះមកឱ្យឈ្មោះ ដោយបានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខ ១១៨ លប ចុះថ្ងៃទី០៩ កុម្ភៈ ឆ្នាំ២០១០ ចេញដោយចៅសង្កាត់ភ្នំពេញថ្មី ហើយបន្ទាប់មកទៀតទើបឈ្មោះ បានលក់ដីខាងលើមកឱ្យដើមចោទនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខ ១៧៥៨ លប ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០១៦ ចេញដោយចៅសង្កាត់ភ្នំពេញថ្មី។ បន្ទាប់ពីទទួលកម្មសិទ្ធិលើដីខាងលើ ខ្ញុំបានគ្រប់គ្រងប្រើប្រាស់ និងអាស្រ័យផលជាលើដីរហូតមកដល់សព្វថ្ងៃ ប៉ុន្តែនៅអំឡុងឆ្នាំ ២០២២ នេះ ខ្ញុំបាទមានបំណងផ្ទេរកម្មសិទ្ធិលើវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ មានឈ្មោះខ្លួនជាម្ចាស់កម្មសិទ្ធិនោះ មិនទាន់អាចធ្វើបាននៅឡើយដោយហេតុថា ឈ្មោះ និងប្រពន្ធឈ្មោះ ដែលមានឈ្មោះនៅក្នុងវិញ្ញាបនប័ត្រខាងលើបានទទួលមរណភាពមិនទាន់បានចូលខ្លួនមកបំពេញបែបបទនៅចំពោះមុខមន្ត្រីសុរិយោដី ដើម្បីផ្ទេរកម្មសិទ្ធិមកឱ្យខ្ញុំបាទជាម្ចាស់កម្មសិទ្ធិនៅឡើយ។ ឈ្មោះ និងប្រពន្ធឈ្មោះ មានកូនទាំងអស់ ៤ នាក់ ដែលជាសហចុងចម្លើយទាំងអស់។ ឈ្មោះ គឺជាពូរបស់ខ្ញុំបាទ។ ខ្ញុំបាទបានទៅសាកសួរខាងសុរិយោដីរួចហើយ តែខាងសុរិយោដីថា លុះត្រាណាមានការប្រគល់សិទ្ធិពីម្ចាស់ដីសិន ហើយនៅក្នុងករណីដែលម្ចាស់ដីខាងលើស្លាប់ទាំងអស់ ត្រូវមានការសម្រេចជាសាលក្រមប្រគល់កម្មសិទ្ធិនៃដីពីខាងតុលាការសិន បានគេអាចធ្វើនីតិវិធីផ្ទេរកម្មសិទ្ធិបាន។

**អ្នកតំណាងដោយអាណត្តិឱ្យដើមចោទបានធ្វើសេចក្ដីថ្លែងការណ៍ថា៖** ខ្ញុំបាទសូមរក្សាខ្លឹមសារនៃពាក្យបណ្ដឹងចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ និងសេចក្ដីថ្លែងការណ៍នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុកាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២ និងកាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ ទុកជាបានការដដែល។ ខ្ញុំបាទសូមបញ្ជាក់ថា កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩ ឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted] បានលក់ដី១កន្លែង មានទំហំ ១១៣ (មួយរយដប់បី) ម៉ែត្រការេ មានក្បាលដីលេខ ១៥០ មានទីតាំងស្ថិតនៅភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ (បច្ចុប្បន្នស្ថិតនៅភូមិដីថ្មី សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ) ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ចេញដោយប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដីរាជធានីភ្នំពេញ មកឱ្យឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted] ដោយបានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខ ០៣៤ លប ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩ ចេញដោយចៅសង្កាត់ភ្នំពេញថ្មី។ ក្រោយមកនៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០ ឈ្មោះ [redacted] និងប្រពន្ធបានព្រមព្រៀងលក់ដីខាងលើមកឱ្យឈ្មោះ [redacted] ដោយបានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខ ១១៨ លប ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០ ចេញដោយចៅសង្កាត់ភ្នំពេញថ្មី ហើយបន្ទាប់មកទៀតទើបឈ្មោះ [redacted] បានលក់ដីខាងលើមកឱ្យកូនក្ដីខ្ញុំនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខ ១៧៤៨ លប ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ចេញដោយចៅសង្កាត់ភ្នំពេញថ្មី។ បន្ទាប់ពីបានទទួលកម្មសិទ្ធិលើដីខាងលើកូនក្ដីខ្ញុំឈ្មោះ [redacted] និងប្រពន្ធ [redacted] បានគ្រប់គ្រងប្រើប្រាស់ និងអាស្រ័យផលជាលើដីនេះរហូតមកដល់សព្វថ្ងៃ ប៉ុន្តែនៅអំឡុងឆ្នាំ២០២២ កូនក្ដីខ្ញុំមានបំណងផ្ទេរសិទ្ធិកម្មសិទ្ធិក្នុងវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ចេញដោយប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដីរាជធានីភ្នំពេញ មានឈ្មោះខ្លួនជាម្ចាស់កម្មសិទ្ធិនោះ មិនទាន់អាចធ្វើបាននៅឡើយដោយហេតុថា ឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted] ដែលមានឈ្មោះជាម្ចាស់កម្មសិទ្ធិ ក្នុងវិញ្ញាបនប័ត្រខាងលើបានទទួលមរណភាព មិនទាន់បានចូលខ្លួនមកបំពេញបែបបទ នៅចំពោះមុខមន្ត្រីសុរិយោដី ដើម្បីផ្ទេរសិទ្ធិកម្មសិទ្ធិមកឱ្យកូនក្ដីខ្ញុំឈ្មោះ [redacted] និង ឈ្មោះ [redacted] ជាម្ចាស់កម្មសិទ្ធិនៅឡើយ។ ឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted] មានកូនទាំងអស់ ចំនួន ០៤នាក់(បួន) ដែលជាសហចុងចម្លើយទាំងអស់។ ក្រោយពីកូនក្ដីខ្ញុំបានដាក់ពាក្យបណ្ដឹងទៅសាលាដំបូងរាជធានីភ្នំពេញរួចមក សហចុងចម្លើយទាំងអស់ បានបញ្ជាក់ចំពោះឆន្ទៈរបស់ខ្លួនថា "មិនមានការប្រកែកតវ៉ាចំពោះតុលាការដែលសម្រេចឱ្យកូនក្ដីខ្ញុំជាម្ចាស់កម្មសិទ្ធិលើដីខាងលើឡើយ"។ មិនតែប៉ុណ្ណោះក៏មានពាក្យសុំចូលជួយអន្តរាគមន៍របស់ឈ្មោះ [redacted] និងឈ្មោះ [redacted] ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៣ ដែលមានខ្លឹមសារ "សុំចូលរួមអន្តរាគមន៍ដល់ភាគីដើមចោទឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted] ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ១៧២០ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ ដោយសំណូមពរឱ្យតុលាការសម្រេច តាមខ្លឹមសារដែលទាមទារដោយ ដើមចោទឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted] ទាំងស្រុង"។ ក្នុងនាមខ្ញុំបាទជាអ្នកតំណាងដោយអាណត្តិឱ្យសហដើមចោទ សូមសំណូមពរដូចខាងក្រោម៖

ក-បង្គាប់ឱ្យសហចុងចម្លើយទទួលស្គាល់ដើមចោទជាម្ចាស់កម្មសិទ្ធិដីមួយកន្លែង មានទំហំ ១១៣ (មួយរយដប់បី) ម៉ែត្រការេ មានក្បាលដីលេខ ១៥០ មានទីតាំងស្ថិតនៅភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ (បច្ចុប្បន្នស្ថិតនៅភូមិដីថ្មី សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ ) មានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ចេញដោយប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដីរាជធានីភ្នំពេញ ។

ខ-បង្គាប់ឱ្យចុងចម្លើយបំពេញបែបបទនៅចំពោះមុខមន្ត្រីសុរិយោដី តាមនីតិវិធីច្បាប់ ដើម្បីផ្ទេរសិទ្ធិកម្មសិទ្ធិវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ មកឱ្យដើមចោទ ។

គ-បង្គាប់ឱ្យមន្ត្រីសុរិយោដី និងអាជ្ញាធរពាក់ព័ន្ធបំពេញបែបបទតាមនីតិវិធីច្បាប់ ដើម្បីផ្ទេរសិទ្ធិកម្មសិទ្ធិវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ មកឱ្យដើមចោទជាម្ចាស់កម្មសិទ្ធិ។

**៣.២-ការអះអាងរបស់អ្នកចូលរួមជួយអន្តរាគមន៍ក្នុងបណ្ដឹងរបស់សហដើមចោទ**

**អ្នកចូលរួមជួយអន្តរាគមន៍ឈ្មោះ** [redacted] បានធ្វើសេចក្តីថ្លែងការណ៍ក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថា៖ នៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០ ខ្ញុំបាទបានទិញដីមួយកន្លែងដែលមានទំហំ ១១៣ ម៉ែត្រការេ មានក្បាលលេខ ១៥០ មានទីតាំងស្ថិតនៅភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ (បច្ចុប្បន្ននៅភូមិដីថ្មីសង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ) ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ដោយប្រធានមន្ទីររៀបចំដែនដីនគររូបនីយកម្មសំណង់ និងសុរិយោដីរាជធានីភ្នំពេញ ពីឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted] ដោយបានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខ ១១៨លប ចុះថ្ងៃទី០៩ កុម្ភៈ ឆ្នាំ២០១០ ចេញដោយចៅសង្កាត់ភ្នំពេញថ្មីតែមិនបានធ្វើការបំពេញបែបបទនៅក្នុងការផ្ទេរកាត់ឈ្មោះមកឱ្យខ្ញុំបាទនោះឡើយ។ បន្ទាប់មកទៀតទើប នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ខ្ញុំបាទបានលក់ដីខាងលើទៅឱ្យឈ្មោះ [redacted] និងឈ្មោះ [redacted] ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខ ១៧៤៨ លប ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ចេញដោយចៅសង្កាត់ភ្នំពេញថ្មី។ ប៉ុន្តែមិនទាន់បានធ្វើនីតិវិធីក្នុងការកាត់ឈ្មោះ និងផ្ទេរកម្មសិទ្ធិនៃដីខាងលើនោះឡើយ។ នៅពេលដែលតុលាការសម្រេចធ្វើការផ្ទេរកម្មសិទ្ធិនៃដីខាងលើឱ្យទៅឈ្មោះ [redacted] និងឈ្មោះ [redacted] គឺខ្ញុំបាទពុំមានការជំទាស់តវ៉ាអ្វីឡើយ ខ្ញុំបាទឯកភាពទាំងស្រុង ព្រោះខ្ញុំបាទពិតជាបានលក់ដីឱ្យទៅឈ្មោះ [redacted] និងឈ្មោះ [redacted] និងមិនទាន់បានទៅបំពេញបែបបទកាត់ឈ្មោះតាមច្បាប់ ប្រាកដមែន។

**អ្នកចូលរួមជួយអន្តរាគមន៍ឈ្មោះ** [redacted] **បានធ្វើសេចក្តីថ្លែងការណ៍ក្នុងនីតិវិធីត្រៀមសម្រាប់**ការទាញហេតុផលថា៖ កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០០៨ ខ្ញុំបាទ និងប្រពន្ធឈ្មោះ [redacted] បានទិញដីមួយកន្លែង ដែលមានទំហំ ១១៣ ម៉ែត្រការេ មានក្បាលលេខ ១៥០ មានទីតាំងស្ថិតនៅភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ (បច្ចុប្បន្នស្ថិតនៅភូមិដីថ្មី សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ) មានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ដោយប្រធានមន្ទីររៀបចំដែនដីនគររូបនីយកម្មសំណង់ និងសុរិយោដីរាជធានីភ្នំពេញ ពីឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted] ដោយបានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខ ០៣៣ លប ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៨ ចេញដោយចៅសង្កាត់ភ្នំពេញថ្មី។ តែក្រោយពេលដែលទិញដីខាងលើរួច ពុំបានធ្វើនីតិវិធីក្នុងការកាត់ឈ្មោះ និងផ្ទេរកម្មសិទ្ធិនៃដីខាងលើនោះឡើយ។ ក្រោយមកទៀត ខ្ញុំបាទក៏បានលក់ដីខាងលើនេះ បន្តទៅឱ្យឈ្មោះ [redacted] ទៀត។ នៅពេលដែលតុលាការសម្រេចធ្វើការផ្ទេរកម្មសិទ្ធិនៃដីខាងលើឱ្យទៅឈ្មោះ [redacted] និងឈ្មោះ [redacted] គឺខ្ញុំបាទពុំមានការជំទាស់តវ៉ាអ្វីឡើយ ខ្ញុំបាទឯកភាពទាំងស្រុង ព្រោះខ្ញុំបាទពិតជាបានលក់ដីឱ្យទៅឈ្មោះ [redacted] និងឈ្មោះ [redacted] និងមិនទាន់បានទៅបំពេញបែបបទកាត់ឈ្មោះតាមច្បាប់ ប្រាកដមែន។

**៣.៣-ការអះអាងរបស់សហចុងចម្លើយ**

ចុងចម្លើយឈ្មោះ …… បានធ្វើសេចក្ដីថ្លែងការណ៍ក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថា៖ ខ្ញុំជាកូនរបស់ឈ្មោះ …… និងម្ដាយឈ្មោះ ……។ ម្ដាយឪពុករបស់ខ្ញុំបានស្លាប់អស់ហើយកាលពីអំឡុងឆ្នាំ២០១៧ ដោយសាររោគាពាធ។ កាលគាត់នៅមានជីវិត ខ្ញុំបានដឹងឮថា ពួកគាត់ពិតជាបានលក់ដីមួយកន្លែងដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលវត្ថុលេខ ១២០៧០៥០៦-០១៥០ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ទៅឱ្យឈ្មោះ …… និងឈ្មោះ …… ហើយឈ្មោះ …… បានលក់បន្តឱ្យទៅឈ្មោះ …… ហើយឈ្មោះ …… បានលក់ឱ្យឈ្មោះ …… បន្តទៀត ប៉ុន្តែខ្ញុំមិនបានដឹងច្បាស់ថាតម្លៃប៉ុន្មានទេ ហើយដីនោះក៏មិនទាន់បានកាត់ឈ្មោះផ្ទេរកម្មសិទ្ធិនៅឡើយទេ ដោយសារថា មិនសូវបានខ្វល់អំពីការផ្ទេរឈ្មោះនេះឡើយ ទើបទុករហូតមកដល់បច្ចុប្បន្ននេះ។ ដូច្នេះនៅក្នុងរឿងក្ដីនេះ ខ្ញុំជាកូនរបស់អ្នកស្លាប់ដែលជាកម្មសិទ្ធិករនៃដីខាងលើ គឺយល់ព្រមផ្ដិតស្រាមមេដៃ និងចូលរួមគ្រប់ដំណើរការនីតិវិធីផ្ទេរកម្មសិទ្ធិនៃដីខាងលើ ឱ្យទៅដើមចោទ ដោយគ្មានការជំទាស់អ្វីឡើយ និងពុំមានការបង្ខិតបង្ខំពីអ្នកណានោះឡើយ។

ចុងចម្លើយឈ្មោះ …… បានធ្វើសេចក្ដីថ្លែងការណ៍ក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថា៖ ខ្ញុំជាកូនរបស់ឈ្មោះ …… និងម្ដាយឈ្មោះ ……។ ម្ដាយឪពុករបស់ខ្ញុំបានស្លាប់អស់ហើយ កាលពីអំឡុងឆ្នាំ២០១៧ ដោយសាររោគាពាធ។ កាលគាត់នៅមានជីវិត ខ្ញុំបានដឹងឮថា ពួកគាត់ពិតជាបានលក់ដីមួយកន្លែងដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលវត្ថុលេខ ១២០៧០៥០៦-០១៥០ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ទៅឱ្យឈ្មោះ …… និងឈ្មោះ …… ហើយឈ្មោះ …… បានលក់បន្តឱ្យទៅឈ្មោះ …… ហើយឈ្មោះ …… បានលក់ឱ្យឈ្មោះ …… បន្តទៀត ប៉ុន្តែខ្ញុំមិនបានដឹងច្បាស់ថាតម្លៃប៉ុន្មានទេ ហើយដីនោះក៏មិនទាន់បានកាត់ឈ្មោះផ្ទេរកម្មសិទ្ធិនៅឡើយទេ ដោយសារថា មិនសូវបានខ្វល់អំពីការផ្ទេរឈ្មោះនេះឡើយ ទើបទុករហូតមកដល់បច្ចុប្បន្ននេះ។ ដូច្នេះនៅក្នុងរឿងក្ដីនេះ ខ្ញុំជាកូនរបស់អ្នកស្លាប់ដែលជាកម្មសិទ្ធិករនៃដីខាងលើ គឺយល់ព្រមផ្ដិតស្រាមមេដៃ និងចូលរួមគ្រប់ដំណើរការនីតិវិធីផ្ទេរកម្មសិទ្ធិនៃដីខាងលើឱ្យទៅដើមចោទ ដោយគ្មានការជំទាស់អ្វីឡើយ និងពុំមានការបង្ខិតបង្ខំពីអ្នកណានោះឡើយ។

ចុងចម្លើយឈ្មោះ …… បានធ្វើសេចក្ដីថ្លែងការណ៍ក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថា៖ ខ្ញុំជាកូនរបស់ឈ្មោះ …… និងម្ដាយឈ្មោះ ……។ ម្ដាយឪពុករបស់ខ្ញុំបានស្លាប់អស់ហើយកាលពីអំឡុងឆ្នាំ២០១៧ ដោយសាររោគាពាធ។ កាលគាត់នៅមានជីវិត ខ្ញុំបានដឹងឮថា ពួកគាត់ពិតជាបានលក់ដីមួយកន្លែងដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលវត្ថុលេខ ១២០៧០៥០៦-០១៥០ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ទៅឱ្យឈ្មោះ …… និងឈ្មោះ …… ហើយឈ្មោះ …… បានលក់បន្តឱ្យទៅឈ្មោះ …… ហើយឈ្មោះ …… បានលក់ឱ្យឈ្មោះ …… បន្តទៀត ប៉ុន្តែខ្ញុំមិនបានដឹងច្បាស់ថាតម្លៃប៉ុន្មានទេ ហើយដីនោះក៏មិនទាន់បានកាត់ឈ្មោះផ្ទេរកម្មសិទ្ធិនៅឡើយទេ ដោយសារថា មិនសូវបានខ្វល់អំពីការផ្ទេរឈ្មោះនេះឡើយ ទើបទុករហូតមកដល់បច្ចុប្បន្ននេះ។ ដូច្នេះនៅក្នុងរឿងក្ដីនេះ ខ្ញុំជាកូនរបស់អ្នកស្លាប់ដែលជាកម្មសិទ្ធិករនៃដីខាងលើ គឺយល់ព្រមផ្ដិតស្រាមមេដៃ និងចូលរួមគ្រប់ដំណើរការនីតិវិធីផ្ទេរកម្មសិទ្ធិនៃដីខាងលើ ឱ្យទៅដើមចោទ ដោយគ្មានការជំទាស់អ្វីឡើយ និងពុំមានការបង្ខិតបង្ខំពីអ្នកណានោះឡើយ។

**៤-ចំណុចវិវាទ៖** គ្មាន។

**៥-ចំណុចគ្មានវិវាទ៖** ភាគីសហចុងចម្លើយបានព្រមព្រៀងគ្នាក្នុងការផ្ទេរកម្មសិទ្ធិនៃដីមួយកន្លែងដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ទៅឱ្យសហដើមចោទ។

## II. ការពិនិត្យភស្តុតាង

**ភស្តុតាងជាឯកសាររបស់ដើមចោទ**

- វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩។
- ពាក្យសុំបូជាសព ឬបញ្ចុះសពចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៧។
- លិខិតអនុញ្ញាតបូជាសព ឬបញ្ចុះសពចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៧។
- សំបុត្រអាពាហ៍ពិពាហ៍ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២២។
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០២០៩៨៥៨៩០ របស់ឈ្មោះ ។
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១១៣៣៦៣២១ របស់ឈ្មោះ ។
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១០៥៤២៥៨១ របស់ឈ្មោះ ប។
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១០៩០០៨៧៦ របស់ឈ្មោះ ។
- សំបុត្របញ្ជាក់កំណើតលេខ ៤៧៤៩ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៥ របស់ឈ្មោះ ។
- សំបុត្របញ្ជាក់កំណើតលេខ ៧៤៥៩ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៥ របស់ឈ្មោះ ។
- សំបុត្របញ្ជាក់កំណើតលេខ ៤៧០០ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៥ របស់ឈ្មោះ ។
- លិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខ ១៧៤៨ ល.ប ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦។
- លិខិតធានាអះអាងចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦។
- កិច្ចសន្យាចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦។
- កំណត់ហេតុស្តីពីការចុះពិនិត្យដីធ្លីចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ របស់ឈ្មោះ ។
- លិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខ ១១៨ ល.ប ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០។
- លិខិតធានាអះអាងចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០។
- កិច្ចសន្យាចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០។
- កំណត់ហេតុស្តីពីការចុះពិនិត្យដីធ្លីចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០។របស់ឈ្មោះ និង ឈ្មោះ ។
- លិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខ ០៣៤ ល.ប ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩។
- លិខិតធានាអះអាងចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩។
- កិច្ចសន្យាចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩។
- កំណត់ហេតុស្តីពីការចុះពិនិត្យដីធ្លីចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩ របស់ឈ្មោះ និងឈ្មោះ ។

## សំអាងហេតុ

តាមលទ្ធផលនៃការពិនិត្យភស្តុតាង នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ តុលាការយល់ឃើញថា៖

១-តាមពាក្យបណ្តឹងចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] និងឈ្មោះ [redacted] ដែលមានកម្មវត្ថុស្នើសុំឱ្យសហចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិលើដីមួយកន្លែងដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ដែលមានទំហំ ១១៣ (មួយរយដប់បី) ម៉ែត្រការេ មានក្បាលដីលេខ ១៥០ មានទីតាំងស្ថិតនៅភូមិរោងចក សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ (បច្ចុប្បន្នស្ថិតនៅភូមិដីថ្មី សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ) ឃើញថា ការទាមទាររបស់សហដើមចោទមានមូលដ្ឋាន និងភស្តុតាងបញ្ជាក់ត្រឹមត្រូវតាមច្បាប់ ហេតុដូចនេះគប្បីតុលាការសម្រេចតាមការទាមទាររបស់សហដើមចោទ។

២-តាមការអះអាងរបស់សហដើមចោទខាងលើ គឺមានភាពស្របគ្នាជាមួយនឹងការអះអាងរបស់សហចុងចម្លើយ ព្រមទាំងភស្តុតាងជាឯកសារ បានបញ្ជាក់ថា ដីមួយកន្លែងដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ពិតជាមានការទិញលក់បន្តគ្នាដោយមិនទាន់មានការចុះបញ្ជីផ្ទេរកម្មសិទ្ធិនៅឡើយ ដោយដំបូងឡើយឈ្មោះ [redacted] និងឈ្មោះ [redacted] បានលក់ដីនេះទៅឱ្យឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted] បន្ទាប់មកឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted] បានលក់ដីនេះបន្តឱ្យទៅឈ្មោះ [redacted]។ បន្ទាប់មកទៀតឈ្មោះ [redacted] បានលក់ដីនេះបន្តឱ្យទៅឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted] ប្រាកដមែន ប៉ុន្តែមិនទាន់បានធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិនៅឡើយទេ ដោយសារតែយល់ថាជាសាច់ញាតិនឹងគ្នា ព្រមទាំងមិនយល់ពីអត្ថប្រយោជន៍តាមផ្លូវច្បាប់ ទើបមិនបានទៅបំពេញបែបបទចុះបញ្ជីផ្ទេរកម្មសិទ្ធិមកដល់បច្ចុប្បន្ននេះ។

៣-តាមការអះអាងរបស់សហដើមចោទ ការអះអាងរបស់សហចុងចម្លើយ បានបញ្ជាក់ឱ្យឃើញថាសហចុងចម្លើយទាំងអស់បានបង្ហាញឆន្ទៈរបស់ខ្លួនថា ខ្លួនមានការឯកភាព ពុំមានការជំទាស់អ្វីក្នុងការចុះបញ្ជីផ្ទេរកម្មសិទ្ធិលើដីមួយកន្លែងដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ១២០៧០៥០៦-០១៥០ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ទៅឱ្យដើមចោទឈ្មោះ [redacted] និងឈ្មោះ [redacted] នោះឡើយ។ មិនតែប៉ុណ្ណោះក៏មានការចូលរួមអន្តរាគមន៍របស់ឈ្មោះ [redacted] និងឈ្មោះ [redacted] ដែលជាអ្នកទិញលក់ដីខាងលើបន្តដែរ ដែលអ្នកទាំងពីរនាក់ក៏បានបង្ហាញឆន្ទៈរបស់ខ្លួនថា ខ្លួនមានការឯកភាព ដោយពុំមានការជំទាស់អ្វីក្នុងការចុះបញ្ជីផ្ទេរកម្មសិទ្ធិលើដីមួយកន្លែងខាងលើ ទៅឱ្យដើមចោទឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted]។

៤-ប្រាក់ប្រដាប់ក្តីត្រូវអនុវត្តតាមបញ្ញត្តិមាត្រា ៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សេចក្តីសម្រេចបញ្ចប់

១-ទទួលស្គាល់សហដើមចោទឈ្មោះ [redacted] និងឈ្មោះ [redacted] ជាម្ចាស់កម្មសិទ្ធិដីមួយកន្លែង ដែលមានទំហំ ១១៣ ម៉ែត្រការេ មានក្បាលដីលេខ ១៥០ មានទីតាំងស្ថិតនៅភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ (បច្ចុប្បន្នស្ថិតនៅភូមិដីថ្មី សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ) មានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ចេញដោយប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដីរាជធានីភ្នំពេញ។

២-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] ឈ្មោះ [redacted], ឈ្មោះ [redacted] និងឈ្មោះ [redacted] បំពេញបែបបទនៅចំពោះមុខមន្ត្រីសុរិយោដីតាមនីតិវិធីច្បាប់ ដើម្បីផ្ទេរកម្មសិទ្ធិវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ មកឱ្យសហដើមចោទឈ្មោះ [redacted] និងឈ្មោះ [redacted]

៣-បង្គាប់ឱ្យមន្ត្រីសុរិយោដី និងអាជ្ញាធរពាក់ព័ន្ធធ្វើនីតិវិធីផ្ទេរកម្មសិទ្ធិលើវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៧០៥០៦-០១៥០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ ទៅឱ្យឈ្មោះ [redacted] និងឈ្មោះ [redacted] តាមនីតិវិធីច្បាប់។

៤-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហដើមចោទ។

ថ្ងៃព្រហស្បតិ៍ ៧រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

រាជធានីភ្នំពេញ.ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣

**ចៅក្រម**

ហត្ថលេខា និងត្រា **ឈុន ដាវី**

---

**បានឃើញ**

**ចៅក្រម**

ឈុន ដាវី

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

ម៉ុន សៀកលីខ